# សម្មាទិដ្ឋិ

## កច្ចានគោត្តសូត្រ

(បិដកលេខ ៣១ ,ទំព័រ ៣៥ )

**សាវត្ថិយំ វិហរតិ អថខោ អាយស្មា កច្ចានគោត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។**

ទ្រង់គង់នៅទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះកច្ចានគោត្រដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

**ឯកមន្តំ និសិន្នោ ខោ អាយស្មា កច្ចានគោត្តោ ភគវន្តំ ឯតទវោច សម្មាទិដ្ឋិ សម្មាទិដ្ឋីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សម្មាទិដ្ឋិ ហោតីតិ ។**

លុះព្រះកច្ចានគោត្រដ៏មានអាយុ គង់អង្គុយក្នុងទីដ៏សមគួរហើយ ក៏ទូលសួរព្រះដ៏មានព្រះភាគដូច្នោះថា បពិត្រព្រះអង្គដ៏



ចម្រើន ព្រះអង្គតែងត្រាស់ថា សម្មាទិដ្ឋិ សម្មាទិដ្ឋិដូច្នោះ បពិត្រព្រះអង្គដ៏ចម្រើន ចុះសម្មាទិដ្ឋិកើតមាន ដោយហេតុប៉ុន្មានយ៉ាង ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

**ទ្វយនិស្សិតោ ខោយំ កច្ចាន លោកោ យេភុយ្យេន អត្ថិតញ្ចេវ នត្ថិតញ្ច ។**

ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវចំណែកពីរយ៉ាង គឺអត្ថិភាព (សស្សតទិដ្ឋិ )១ និងនត្ថិភាព (ឧច្ឆេទទិដ្ឋិ )១ ។

**លោកសមុទយំ ច ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ នត្ថិតា សា ន ហោតិ ។**

ម្នាលកច្ចានៈ នត្ថិភាព (ឧច្ឆេទទិដ្ឋិ) ក្នុងលោក រមែងមិនមានដល់បុគ្គលដែលឃើញនូវហេតុជាទីកើតនៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។

**លោកនិរោធំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ អត្ថិតា សា ន ហោតិ ។**

ម្នាលកច្ចានៈ អត្ថិភាព (សស្សតទិដ្ឋិ) ក្នុងលោក រមែងមិនមានដល់បុគ្គលដែលឃើញនូវទីរលត់នៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។

**ឧបាយុបាទានាភិនិវេសវិនិពន្ធោ ខ្វាយំ កច្ចាន លោកោ យេភុយ្យេន តញ្ចាយំ ឧបាយុបាទានំ ចេតសោ អធិដ្ឋានំ អភិនិវេសានុសយំ ន ឧបេតិ ន ឧបាទិយតិ នាធិដ្ឋាតិ អត្តាមេតិ ។**

ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែជាប់ជំពាក់ដោយឧបាយ ឧបាទាន និងសេចក្តីប្រកាន់មាំ ចំណែកខាងអរិយសាវ័កនេះ រមែងមិនចូលទៅដល់ មិនប្រកៀកប្រកាន់ មិនអធិដ្ឋាន នូវឧបាយនិងឧបាទាន នូវការតាំងទុកនៃចិត្ត នូវសេចក្តីប្រកាន់មាំ និងអនុសយក្កិលេសនោះៗថា ខ្លួនរបស់អាត្មាអញដូច្នេះឡើយ ។

**ទុក្ខមេវ ឧប្បជ្ជមានំ ឧប្បជ្ជតិ ទុក្ខំ និរុជ្ឈមានំ និរុជ្ឈតីតិ ន កង្ខតិ ន វិចិកិច្ឆតិ ។**

ឧបាទានក្ខន្ធទុក្ខ កាលកើត ក៏កើតឡើង ឧបាទានក្ខន្ធទុក្ខ កាលរលត់ ក៏រលត់ទៅ ព្រោះហេតុនោះ ទើបអរិយសាវ័កមិនសង្ស័យ មិនងឿងឆ្ងល់ឡើយ ។

**អបរប្បច្ចយា ញាណមេវស្ស ឯត្ថ ហោតិ ។**

ញាណរបស់អរិយសាវ័កនោះ រមែងមានក្នុងឧបាទានក្ខន្ធទុក្ខនោះ ដោយមិនបាច់ជឿពាក្យបុគ្គលដទៃឡើយ ។

**ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ ។**



ម្នាលកច្ចានៈ សម្មាទិដ្ឋិ កើតមានដោយហេតុប៉ុណ្ណេះឯង។

## អដ្ឋកថា កច្ចានគោត្តសូត្រ

បទថា **សម្មាទិដ្ឋិ** សម្មាទិដ្ឋិ ដោយសេចក្តីថា ទេវតា និងមនុស្សដែលជាបណ្ឌិត ពោលអំពីការឃើញដោយប្រពៃណាៗ ព្រះកច្ចានៈ ទូលសួរដោយសង្ខេបៗ ចំពោះការឃើញដោយប្រពៃនោះៗ ទាំងអស់ចូលក្នុងបទទាំងពីរ ។

បទថា **ទ្វយនិស្សិតោ** គឺអាស្រ័យចំណែកទាំងពីរ ។ ព្រះអង្គ ទ្រង់សម្តែងដល់មហាជនដទៃក្រៅអំពីព្រះអរិយបុគ្គល ដោយបទថា **យេភុយ្យេន** នេះឯង ។

បទថា **អត្ថិតំ** គឺទៀង ។

បទថា **នត្ថិតញ្ច** គឺដាច់សូន្យ ។

សង្ខារលោក ឈ្មោះថា **លោក** ការកើតឡើងនៃសង្ខារ-លោកនោះឯង ឈ្មោះថា **លោកសមុទយ** ។

បទថា **សម្មប្បញ្ញាយ បស្សតោ** ដោយសេចក្តីថា មគ្គប្បញ្ញា ព្រមទាំងវិបស្សនា ។ ឈ្មោះថា សម្មប្បញ្ញា ការដឹងដោយប្រពៃ គឺជាអ្នកពិចារណាឃើញដោយសម្មប្បញ្ញានោះ ។

បទថា **យា លោកេ នត្ថិតា** គឺកាលបុគ្គលពិចារណា

ឃើញដោយបញ្ញា ចំពោះធម៌ដែលកើតឡើងក្នុងសង្ខារលោក ឧច្ឆេទទិដ្ឋិ ដែលយល់ថាមិនមាន ក៏រមែងមិនកើតឡើងឡើយ ។

បទថា **លោកនិរោធំ** បានដល់ការបែកធ្លាយនៃសង្ខារទាំងឡាយ ។

បទថា **យា លោកេ អត្ថិតា** គឺកាលបុគ្គលពិចារណាឃើញដោយបញ្ញា ចំពោះធម៌ដែលកំពុងបែកធ្លាយក្នុងសង្ខារ-លោក សស្សតទិដ្ឋិ ដែលយល់ថាមាន ក៏រមែងមិនកើតឡើងដែរ ។

ម្យ៉ាងទៀត បទថា **លោកសមុទយំ** បានដល់បច្ចយាការដោយអនុលោម ។ បទថា **លោកនិរោធំ** បានដល់បច្ចយាការខាងបដិលោម ។ កាលបុគ្គលពិចារណាឃើញការមិនដាច់សូន្យ នៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការមិនដាច់សូន្យនៃបច្ច័យទាំងឡាយ ឧច្ឆេទទិដ្ឋិ ដែលនឹងគប្បីកើតឡើង រមែងមិនមាន ។ កាលបុគ្គលពិចារណាឃើញការរលត់នៃបច្ច័យ គឺពិចារណាឃើញការរលត់នៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការរលត់ទៅនៃបច្ច័យ សស្សតទិដ្ឋិ ដែលនឹងគប្បីកើតឡើង ក៏រមែងមិនមានដែរ ។ សេចក្ដីនេះ មានដូចពោលមកដូច្នេះឯង ។

ការជាប់ជំពាក់ដោយឧបាយ ឧបាទាន និងអភិនិវេស ឈ្មោះថា **ឧបាយុបាទានាភិនិវេសវិនិពន្ធោ** ។ ក្នុងបទទាំងអស់



នោះ បទថា **ឧបាយ** បានដល់ឧបាយមាន ២ យ៉ាង គឺតណ្ហា-ឧបាយ និងទិដ្ឋិឧបាយ ។ សូម្បី **ឧបាទាន** ជាដើមក៏មានន័យដូចគ្នាដែរ ។ តណ្ហា និងទិដ្ឋិ ព្រះអង្គត្រាស់ហៅថា **ឧបាយ** ព្រោះចូលដល់ គឺចូលទៅដល់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអាការជាដើមថា យើង ថា របស់យើង ។ ម្យ៉ាងទៀត ព្រះអង្គត្រាស់ថា **ឧបាទាន** និង **អភិនិវេស** ព្រោះការប្រកាន់មាំ និងការចាប់តោងមាំ នូវធម៌ទាំងនោះ ។ ដោយលោកនេះ ត្រូវតណ្ហា និងទិដ្ឋិទាំងនោះ ចាប់ចងទុកដូច្នោះឯង ទើបទ្រង់ត្រាស់ថា **ឧបាយុ-បាទានាភិនិវេសវិនិពន្ធោ** ។

បទថា **តញ្ចាយំ** គឺព្រះអរិយសាវ័កនេះ ... ។

បទថា **ន ឧបេតិ** គឺមិនចូលដល់ ។

បទថា **ន ឧបាទិយតិ** គឺមិនប្រកាន់មាំ ។

បទថា **នាធិដ្ឋាតិ** គឺមិនតាំងទុកក្នុងចិត្តមាំ (ដោយឧបាយ និងឧបាទាន ដោយការតាំងមាំនៃចិត្ត ដោយអភិនិវេស និងដោយអនុស័យថាអ្វីជាតួខ្លួនរបស់យើងនោះឡើយ) ។

ដោយអកុសលចិត្ត រមែងតាំងនៅក្នុងតណ្ហានិងទិដ្ឋិ និងព្រោះតណ្ហាព្រមដោយទិដ្ឋិ ក៏តាំងមាំ ហើយដេកសម្ងំនៅក្នុងអកុសលចិត្តនោះ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ធម៌

ទាំងពីរប្រការនេះថា **ចេតសោ អធិដ្ឋានំ អភិនិវេសានុសយំ**។

បទថា **ទុក្ខមេវ** គឺត្រឹមតែឧបាទានក្ខន្ធ ៥ ប៉ុណ្ណោះ ។

បទថា **ន កង្ខតិ** បានដល់ការមិនងឿងឆ្ងល់ថា ទុក្ខនោះឯង រមែងកើតឡើង ទុក្ខនោះឯង រមែងរលត់ ដូចម្តេចហ្ន៎ ។ ដែលឈ្មោះថា សត្វដទៃ ( ក្រៅពីទុក្ខ ) ក្នុងលោកនេះ រមែងមិនមានឡើយ ។

បទថា **ន វិចិកិច្ឆតិ** គឺមិនមានការសង្ស័យក្នុងចិត្តកើតឡើង ។

បទថា **អបរប្បច្ចយា** គឺមិនមែនចេះតែជឿតាមពាក្យអ្នកដទៃនោះទេ នេះគឺជាការឃើញច្បាស់ចំពោះខ្លួនឯង ។

ដោយបទថា **ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ** ព្រះដ៏មានព្រះភាគត្រាស់ដល់សម្មាទិដ្ឋិ ដែលលាយគ្នា[១] ថា ការឃើញដោយប្រពៃមានត្រឹមតែប៉ុណ្ណោះឯង ព្រោះលះនូវសត្តសញ្ញាបានដោយអាការយ៉ាងនេះ ។

១.វិបស្សនាសម្មាទិដ្ឋិ និងមគ្គសម្មាទិដ្ឋិ ព្រះអង្គទ្រង់ត្រាស់សម្តែងក្នុងព្រះសូត្រនេះ ។



## បឋមសុរិយូបមសូត្រ

( បិដកលេខ ៣៩ ,ទំព័រ ២៨១ )

ម្នាលភិក្ខុទាំងឡាយ កាលព្រះអាទិត្យរះឡើង រមែងមានការរះឡើងនៃអរុណ (អរុណពណ៌ប្រាក់ អរុណពណ៌មាស ) ជាប្រធាន ជាបុព្វនិមិត្ត ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ភិក្ខុដែលត្រាស់ដឹងតាមសេចក្តីពិត នូវអរិយសច្ច ៤ រមែងមាននូវសម្មាទិដ្ឋិនោះ ជាប្រធាន ជាបុព្វនិមិត្ត ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ រមែងកើតប្រាកដដល់ភិក្ខុ ដែលប្រកបដោយសម្មាទិដ្ឋិ ដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើសេចក្តីព្យាយាមថា នេះជាទុក្ខ ។ល។ គួរធ្វើសេចក្តីព្យាយាមថា នេះជាបដិបទាទៅកាន់ទីរំលត់ទុក្ខ ។

# នៅក្នុងមហាចត្តារីសកសូត្រ

(បិដកលេខ ២៦ ,ទំព័រ ៣៣៦-៣៣៩)

ម្នាលភិក្ខុទាំងឡាយ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន (ជាប្រធាន) ។ ម្នាលភិក្ខុទាំងឡាយ ឯសម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ ដឹងច្បាស់នូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ។ សេចក្តីដឹងនោះ ជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ។

ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថា :

-ទានដែលបុគ្គលឱ្យហើយមិនមានផល

-ការបូជាតូចមិនមានផល

-ការបូជាធំមិនមានផល

-ផលវិបាករបស់កម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មិនមាន

-លោកនេះមិនមាន

-លោកខាងមុខមិនមាន

-មាតាមិនមានគុណ



-បិតាមិនមានគុណ

-សត្វជាឧបបាតិកកំណើតមិនមាន

-ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងរបស់ខ្លួន ត្រាស់ដឹងនូវលោកនេះ និងលោកខាងមុខ មិនមាន ។ នេះឈ្មោះថា មិច្ឆាទិដ្ឋិ ។

ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងនូវសម្មាទិដ្ឋិថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ គឺសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឱ្យផលជាឧបធិក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គក៏មាន ។

ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឱ្យផលជាឧបធិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថា :

-ទានដែលបុគ្គលឱ្យហើយ មានផល

-ការបូជាតូច មានផល

-ការបូជាធំ មានផល

-ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មាន

-លោកនេះ មាន

-លោកខាងមុខ មាន

-មាតាមានគុណ

-បិតាមានគុណ

-សត្វជាឧបបាតិកកំណើត មាន

-ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងរបស់ខ្លួន ត្រាស់ដឹងនូវលោកនេះ និងលោកខាងមុខក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា សម្មាទិដ្ឋិ ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឱ្យផលជាឧបធិ ។

ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គ សម្មាទិដ្ឋិ អង្គនៃមគ្គ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ ជាអ្នកបរិបូណ៌ដោយអរិយមគ្គ និងជាអ្នកចម្រើននូវអរិយមគ្គ ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ ។

បុគ្គលនោះ ព្យាយាម ដើម្បីលះបង់នូវមិច្ឆាទិដ្ឋិ បំពេញនូវ



សម្មាទិដ្ឋិ ។ សេចក្ដីព្យាយាមនោះ ឈ្មោះថា សម្មាវាយាមៈរបស់បុគ្គលនោះ ។

បុគ្គលនោះ មានសតិលះបង់នូវមិច្ឆាទិដ្ឋិ មានសតិផ្ដេកផ្ដួលចិត្តទៅរកសម្មាទិដ្ឋិ ។ សតិនោះ ជាសម្មាសតិ របស់បុគ្គលនោះ ។

ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាមៈ និងសម្មាសតិ តែងតាមចោមរោមសម្មាទិដ្ឋិដោយប្រការដូច្នេះឯង ។

## ក្នុងអដ្ឋកថាមហាចត្តារីសកសូត្រ

បទថា **សម្មាទិដ្ឋិ បុព្វង្គមា ហោតិ** ដោយសេចក្ដីថា សម្មាទិដ្ឋិដែលជាប្រធានមាន ២ ចំណែកគឺ វិបស្សនាសម្មាទិដ្ឋិដែលជាបុរេចារិក (ប្រព្រឹត្តទៅមុន )១ និងមគ្គសម្មាទិដ្ឋិ ១ ។

វិបស្សនាសម្មាទិដ្ឋិ កំណត់ពិចារណានូវសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអំណាចលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ ចំណែកមគ្គសម្មាទិដ្ឋិបានដកនូវវដ្ដៈ ដែលជាហេតុឱ្យបានភូមិ (លះអនុស័យ ) គឺធ្វើឱ្យស្ងប់រម្ងាប់ កើតឡើងក្នុងទីបំផុតនៃការកំណត់ពិចារណា ដូចយកទឹកត្រជាក់ ១ ពាន់ក្អម ចាក់ស្រោចលើសីសៈដូច្នោះឯង ។

ឧបមាដូចអ្នកចម្ការ កាលធ្វើចម្ការ រមែងកាត់ដើមឈើក្នុងព្រៃជាមុន ក្រោយមកទើបដុត ។ ភ្លើងឆេះដើមឈើដែលកាត់ហើយនោះឯង ឱ្យអស់ទៅមិនមានសល់ យ៉ាងណា វិបស្សនា-សម្មាទិដ្ឋិ ក៏យ៉ាងនោះដែរ រមែងពិចារណាសង្ខារទាំងឡាយដោយអំណាចលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ជាមុន ទើបមគ្គសម្មាទិដ្ឋិកើតឡើងដកនូវសង្ខារទាំងឡាយ តាមក្រោយ មិនឱ្យសង្ខារប្រព្រឹត្តទៅបានទៀត ។ ក្នុងទីនេះសំដៅយកនូវសម្មាទិដ្ឋិទាំងពីរយ៉ាង ។

បទថា **អនុបរិវត្តន្តិ** គឺចោមរោមជាសហជាត ។

នៅក្នុងសេចក្តីនេះ សម្មាវាយាមៈ និងសម្មាសតិ ជាសហជាត ( កើតរួម ) ចោមរោមលោកុត្តរសម្មាទិដ្ឋិ ដូចរាជង្គ-រក្ខកាន់ដាវ និងភ្នាក់ងារកាន់ឆត្រឈរនៅក្នុងរថព្រះទីនាំងតែមួយហែហមព្រះរាជាដូច្នោះ ។ ចំណែកវិបស្សនាសម្មាទិដ្ឋិ ជាបុរេជាត (កើតមុន ) ចោមរោម ដូចទាហានថ្មើរជើងជាដើម ដើរទៅមុខរថព្រះទីនាំងនោះឯង ។



## នៅខាងចុងចហាចត្តារីសកសូត្រ

( បិដកលេខ ២៦ , ទំព័រ ៣៤៧-៣៤៨ )

ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន (ជាប្រធាន ) ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុនតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈកើតមានដល់បុគ្គលមានសម្មាទិដ្ឋិ ។ សម្មាវាចា កើតមានដល់បុគ្គលមានសម្មាសង្កប្បៈ ។ សម្មាកម្មន្តៈ កើតមានដល់បុគ្គលមានសម្មាវាចា ។ សម្មាអាជីវៈ កើតមានដល់បុគ្គលមានសម្មាកម្មន្តៈ ។ សម្មាវាយាមៈ កើតមានដល់បុគ្គលមានសម្មាអាជីវៈ ។ សម្មាសតិកើតមានដល់បុគ្គលមានសម្មាវាយាមៈ ។ សម្មាសមាធិ កើតមានដល់បុគ្គលមានសម្មាសតិ ។ សម្មាញាណ កើតមានដល់បុគ្គលមានសម្មាសមាធិ ។ សម្មាវិមុត្តិ កើតមានដល់បុគ្គលមានសម្មាញាណ។

ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូច្នេះឯង សេក្ខបុគ្គលដែលប្រកបដោយអង្គ ៨ ទើបជាព្រះអរហន្តប្រកបដោយអង្គ១០។

ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន ។

ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាទិដ្ឋិ មិច្ឆាទិដ្ឋិតែងសាបសូន្យទៅ ។ អកុសលធម៌ទាំងឡាយណាដ៏លាមកច្រើនប្រការដែលកើតឡើងព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលនោះ តែងសាបសូន្យ ឯកុសលធម៌ទាំងឡាយដ៏ច្រើន ក៏ដល់នូវការបរិបូណ៌ដោយភាវនាបាន ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។

ព្រះពុទ្ធប្រៀបដូចព្រះចន្ទពេញបូណ៌មី ព្រះធម៌ប្រៀបដូចរស្មីនៃព្រះចន្ទ ព្រះសង្ឃប្រៀបដូចលោកដែលស្រស់បស់ដោយរស្មីនៃព្រះចន្ទពេញបូណ៌មីនោះ ។



## នៅក្នុងសុកសូត្រ

( បិដកលេខ ៣៧ , ទំព័រ ២៣ )

ម្នាលភិក្ខុទាំងឡាយ ដូចចុងស្រូវខ្សាយ ឬចុងស្រូវដំណើប ដែលបុគ្គលតម្កល់ទុកត្រូវ នឹងអាចមុតដៃឬជើង នឹងញុំាងឈាមឱ្យកើតឡើងបាន ដល់បុគ្គលដែលច្រត់ដៃ ឬជាន់ដោយជើង (ចំទៅលើចុងស្រូវនោះ ) ហេតុនោះ រមែងមានជាប្រាកដ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ចុងនៃស្រូវ គេតម្កល់ទុកត្រូវ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះនឹងទម្លាយនូវអវិជ្ជា នឹងញុំាងវិជ្ជាឱ្យកើតឡើង នឹងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានបាន ដោយទិដ្ឋិដែលខ្លួនតម្កល់ត្រូវ ដោយមគ្គភាវនាដែលខ្លួនតម្កល់ត្រូវ ហេតុនេះរមែងមានជាប្រាកដ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ទិដ្ឋិដែលភិក្ខុនោះតម្កល់ត្រូវ ក៏យ៉ាងនោះដែរ ។

## អបរា ឯកធម្មាទិបាលិ

(បិដកលេខ ៤០ , ទំព័រ ៦៩ )

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃសូម្បីតែធម៌មួយ ដែលជាហេតុនាំពួកកុសលធម៌ ដែលមិនទាន់កើត ឱ្យកើតឡើង ឬពួកកុសលធម៌ដែលកើតឡើងហើយ ឱ្យប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដូចសម្មាទិដ្ឋិនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកកុសលធម៌ដែលមិនទាន់កើត រមែងកើតឡើង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដល់បុគ្គលដែលមាននូវសម្មាទិដ្ឋិ ។

ព្រះពុទ្ធប្រៀបដូចដួងអាទិត្យ ព្រះធម៌ប្រៀបដូចរស្មីនៃព្រះអាទិត្យ ព្រះសង្ឃប្រៀបដូចជាលោកដែលដួងអាទិត្យកម្ចាត់ងងឹតហើយ ។



## សម្មាទិដ្ឋិអង្គមគ្គ

(បិដកលេខ ១៧ , ទំព័រ ២៩៧ )

(បិដកលេខ ២០, ទំព័រ ២៣២ )

(បិដកលេខ ៣៧ , ទំព័រ ១៩ )

(បិដកលេខ ៨០ , ទំព័រ ២០៨ )

(បិដកលេខ ៨១ , ទំព័រ ២២៦ )

ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គមានអង្គ ៨ នោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាជាគ្រឿងដឹងក្នុងកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងតណ្ហា ជាដែនឱ្យកើតនូវកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងធម៌ ដែលជាទីរំលត់នៃកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងដំណើរទៅកាន់ទីរំលត់ទុក្ខណា ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាទិដ្ឋិ ។

# សម្មាទិដ្ឋិសូត្រ

( បិដកលេខ ២០ , ទំព័រ ១៥២ )

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលតបពាក្យព្រះសារីបុត្តដ៏មានអាយុ ដោយពាក្យថា ព្រះករុណា លោកដ៏មានអាយុ ។ ព្រះសារីបុត្តដ៏មានអាយុ បានសួរពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ តែងត្រាស់ថា សម្មាទិដ្ឋិ សម្មាទិដ្ឋិ ដូច្នេះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាអ្នកមានសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ។ ភិក្ខុទាំងឡាយនោះ ឆ្លើយតបថា បពិត្រ លោកដ៏មានអាយុ ខ្ញុំព្រះករុណាទាំងឡាយមកអំពីចម្ងាយ ដើម្បីដឹងសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះសារីបុត្តដ៏មានអាយុ ពួកយើងខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្តដ៏មាន



អាយុ សម្តែងនូវសេចក្តីនៃភាសិតនោះឱ្យទាន ភិក្ខុទាំងឡាយ បានស្តាប់ភាសិត របស់ព្រះសារីបុត្តដ៏មានអាយុហើយ នឹងចងចាំទុក ។ ព្រះសារីបុត្តមានថេរវាចាថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរលោកទាំងឡាយប្រុងស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឱ្យប្រពៃចុះ ខ្ញុំព្រះករុណានឹងសម្តែងឥឡូវនេះ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុ ដោយពាក្យថា ព្រះករុណា លោកដ៏មានអាយុ ។

ព្រះសារីបុត្តដ៏មានអាយុ ក៏បានសម្តែងនូវសេចក្តីនេះថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវអកុសលផង ដឹងច្បាស់នូវអកុសលមូលផង ដឹងច្បាស់នូវកុសលផង ដឹងច្បាស់នូវកុសលមូលផង ។ ម្នាលអាវុសោទាំងឡាយ ព្រះអរិយសាវ័ក ជាអ្នកមានសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ក្នុងកាលនោះ ដោយហេតុប៉ុណ្ណេះឯង ។ ម្នាលអាវុសោទាំងឡាយ អកុសលតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បាណាតិបាត ជាអកុសល ១ , អទិន្នាទាន ជាអកុសល ១ , កាមេសុមិច្ឆាចារ ជាអកុសល ១ , មុសាវាទ ជាអកុសល ១ , បិសុណាវាចា ជាអកុសល១ , ផរុសវាចា ជាអកុសល ១ ,

សម្ផប្បលាប ជាអកុសល ១ , អភិជ្ឈា ជាអកុសល ១ , ព្យាបាទ ជាអកុសល ១,មិច្ឆាទិដ្ឋិ ជាអកុសល ១ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា អកុសល ។

ម្នាលអាវុសោទាំងឡាយ អកុសលមូលតើដូចម្ដេច ។ លោភៈ ជាអកុសលមូល ១, ទោសៈ ជាអកុសលមូល ១ , មោហៈ ជាអកុសលមូល ១ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា អកុសលមូល ។

ម្នាលអាវុសោទាំងឡាយ កុសលតើដូចម្ដេច ។ ចេតនាវៀរចាកបាណាតិបាត ជាកុសល ១ , ចេតនាវៀរចាកអទិន្នាទាន ជាកុសល ១ , ចេតនាវៀរចាកកាមេសុមិច្ឆាចារ ជាកុសល ១ , ចេតនាវៀរចាកមុសាវាទ ជាកុសល ១, ចេតនាវៀរចាកបិសុណាវាចា ជាកុសល ១ , ចេតនាវៀរចាកផរុសវាចា ជាកុសល ១ , ចេតនាវៀរចាកសម្ផប្បលាប ជាកុសល ១,ការមិនមានអភិជ្ឈាជាកុសល ១, ការមិនព្យាបាទ ជាកុសល ១, សម្មាទិដ្ឋិ ជាកុសល ១។ ម្នាលអាវុសោទាំងឡាយ នេះហៅថា កុសល ។

ម្នាលអាវុសោទាំងឡាយ កុសលមូលតើដូចម្ដេច។អលោភៈ ជាកុសលមូល ១,អទោសៈ ជាកុសលមូល ១,អមោហៈជាកុសលមូល ១ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា កុសលមូល ។



ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក័ ដឹងច្បាស់នូវអកុសលយ៉ាងនេះ ដឹងច្បាស់នូវអកុសលមូលយ៉ាងនេះ ដឹងច្បាស់នូវកុសលយ៉ាងនេះ ដឹងច្បាស់នូវកុសលមូលយ៉ាងនេះ ។ កាលនោះឯង ព្រះអរិយសាវក័នោះលះបង់នូវរាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យ ដែលប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ ហើយលះបង់នូវអវិជ្ជា ញុំាងវិជ្ជាឱ្យកើតឡើង ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន ដោយសព្វគ្រប់បាន ។

ម្នាលអាវុសោទាំងឡាយ អរិយសាវក័ ជាអ្នកមានសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

## អដ្ឋកថាសម្មាទិដ្ឋិសូត្រ

សម្មាទិដ្ឋិមានពីរយ៉ាង គឺ **លោកិយសម្មាទិដ្ឋិ** ១ និង **លោកុត្តរសម្មាទិដ្ឋិ** ១ ។

**លោកិយសម្មាទិដ្ឋិ** បានដល់ **កម្មស្សកតាញាណ** (បញ្ញាដឹងថា សត្វមានកម្មជារបស់ខ្លួន) និង **សច្ចានុលោមិកញ្ញាណ**

(បញ្ញាប្រព្រឹត្តទៅដ៏សមគួរដល់ការកំណត់ដឹងនូវអរិយសច្ច) ។

**លោកុត្តរសម្មាទិដ្ឋិ** បានដល់ បញ្ញាដែលប្រកបដោយ អរិយមគ្គ និងអរិយផល ។

បុគ្គលដែលមានសម្មាទិដ្ឋិ មានបីប្រភេទ គឺ បុថុជ្ជន ១ សេក្ខបុគ្គល ១ និងអសេក្ខបុគ្គល ១

បុថុជ្ជន មានពីរប្រភេទ គឺពាហិរិកជន (មនុស្សក្រៅព្រះពុទ្ធសាសនា)១ និងពុទ្ធសាសនិកជន ១ ។ ពាហិរកបុថុជ្ជន ជាកម្មវាទី គឺជាសម្មាទិដ្ឋិកបុគ្គល ដោយការឃើញថា សត្វមានកម្មជារបស់ខ្លួន មិនមែនដោយការឃើញនៅក្នុងសច្ចានុលោមិកញ្ញាណនោះឡើយ ។ ចំណែកពុទ្ធសាសនិកបុថុជ្ជន ជាសម្មាទិដ្ឋិកបុគ្គលដោយការឃើញទាំងពីរយ៉ាង ( គឺ កម្មស្សកតាបញ្ញា និងសច្ចានុលោមិកញ្ញាណ នៅមានសក្កាយទិដ្ឋិ ) ។

សេក្ខបុគ្គល ឈ្មោះថាមានការឃើញដ៏ប្រពៃ ព្រោះមានការឃើញត្រូវដ៏ពិតប្រាកដ ។

អសេក្ខបុគ្គល ឈ្មោះថា មានការឃើញដ៏ប្រពៃ ព្រោះមិនមានការសិក្សា (ក្នុងអរិយសច្ចធម៌) ទៀតឡើយ ។

នៅក្នុងព្រះសូត្រនេះ **សម្មាទិដ្ឋិ** សំដៅយក សម្មាទិដ្ឋិដែលជាលោកុត្តរកុសល ដែលជាគ្រឿងនាំសត្វចេញចាកទុក្ខ ។ បុគ្គល



ដែលបានសម្រេចនូវសម្មាទិដ្ឋិនេះ ឈ្មោះថា ជាអ្នកមានការឃើញដ៏ប្រពៃ ។ ព្រោះហេតុនោះឯង ព្រះសារីបុត្តដ៏មានអាយុ ទើបបានសម្ដែងទុកមកថា « ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ » ។

អធិប្បាយសេចក្ដីក្នុងពាក្យដែលព្រះសារីបុត្តដ៏មានអាយុសម្ដែង គឺដោយសេចក្ដីថា សម្មាទិដ្ឋិដែលជាលោកុត្តរប៉ុណ្ណោះ ដែលជាការឃើញត្រង់ ព្រោះទៅតាមផ្លូវត្រង់ រួចផុតពីផ្លូវអមទាំងពីរ ឬកាត់ផ្ដាច់នូវការវៀចវេរ វៀចវាងទាំងឡាយ មានការវៀចដោយកាយកម្មជាដើម ហើយទៅត្រង់ ។ ម្យ៉ាងទៀត បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិនោះឯង ឈ្មោះថា ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ គឺជ្រះថ្លាមិនញាប់ញ័រក្នុងលោកុត្តរធម៌ទាំង ៩ ប្រការ ។ អរិយសាវក កាលលះបង់នូវសេចក្ដីប្រកាន់ដោយមិច្ឆាទិដ្ឋិគ្រប់យ៉ាង និងកិលេសទាំងអស់បានហើយ ក៏ចេញចាកសង្សារគឺជាតិ ចប់កិច្ចបដិបត្តិ ដូច្នេះ លោកហៅថា ជាអ្នកបានមកកាន់ព្រះសទ្ធម្ម ពោលគឺព្រះនិព្វាន នេះគឺជាការចុះកាន់អមតធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ ដោយអរិយមគ្គ ។

ពាក្យថា **អកុសលញ្ច បជានាតិ** ដោយសេចក្ដីថា ដឹង

ច្បាស់នូវអកុសល ពោលគឺ អកុសលកម្មបថ ១០ ប្រការ ។ កាលចាក់ធ្លុះថា នេះជាទុក្ខ ដោយអំណាចនៃកិច្ចញ្ញាណ ឈ្មោះថា ដឹងច្បាស់នូវអកុសល ព្រោះការដឹងច្បាស់ ដែលមាននិរោធជាអារម្មណ៍ ។

ពាក្យថា **អកុសលមូលញ្ច បជានាតិ** ដោយសេចក្ដីថា ដឹងច្បាស់នូវឫសគល់នៃអកុសល ដែលជាឫសគល់ ជាបច្ច័យនៃអកុសលនោះ ។ កាលចាក់ធ្លុះថា នេះជាហេតុឱ្យកើតទុក្ខ ដោយប្រការនោះឯង (ឈ្មោះថា ដឹងច្បាស់នូវឫសគល់នៃអកុសល)។

កុសល និងកុសលមូល មានន័យដូចគ្នា ។

## អរិយសច្ចក្នុងកម្មបថ

ព្រះសារីបុត្តដ៏មានអាយុ កាលដែលសម្ដែងនូវសេចក្ដីនោះទុកហើយ ទាំងដោយសង្ខេប ទាំងដោយពិស្តារ ទើបបានសម្ដែងអប្បនាវារៈ មានជាអាទិ៍ថា **យតោ ខោ អាវុសោ អរិយសាវកោ ឯវំ អកុសលំ បជានាតិ** ។

បណ្ដាបទទាំងនោះ បទថា **ឯវំ អកុសលំ បជានាតិ** ដោយសេចក្ដីថា ដឹងច្បាស់នូវអកុសល បានដល់អកុសលកម្មបថ ១០ តាមដែលបានសម្ដែងទុកហើយយ៉ាងនោះឯង ។ សូម្បីបទដទៃតទៅទៀត មានជាអាទិ៍ថា **ឯវំ អកុសលមូលំ** ក៏មានន័យដូចគ្នានេះដែរ ។



ដោយហេតុត្រឹមតែប៉ុណ្ណេះ គឺដោយន័យជាមួយគ្នា ក្នុងធម៌ដែលព្រះសារីបុត្តបានសម្ដែងដល់ព្រះកម្មដ្ឋាន ជាហេតុនាំសត្វចេញចាកភព រហូតដល់ព្រះអរហត្ត សម្រាប់អ្នកបំពេញនូវព្រះកម្មដ្ឋាន មានចតុរារិយសច្ចជាអារម្មណ៍ ។

តើសម្ដែងទុក (ក្នុងន័យជាមួយគ្នានឹងព្រះកម្មដ្ឋាន ជាហេតុនាំសត្វចេញចាកភព) យ៉ាងណា ?

តាមការពិត អកុសលកម្មបថ ១០ និងកុសលកម្មបថ ១០ វៀរអភិជ្ឈា គឺជាទុក្ខសច្ចៈក្នុងកម្មបថវារៈនេះ ចំណែកអភិជ្ឈា (អង្គធម៌គឺលោភៈជាអកុសលមូល) ជាសមុទយសច្ចៈដោយត្រង់ ។ កម្មបថទាំងអស់ ជាទុក្ខសច្ចៈ ឯកុសលមូល និងអកុសលមូលទាំងអស់ជាសមុទយសច្ចៈដោយអម ។ ការមិនប្រព្រឹត្តទៅនៃកុសលមូល និងអកុសលមូល ជានិរោធសច្ចៈ ។ កាលកំណត់ដឹងទុក្ខ លះសមុទយៈ ជាក់ច្បាស់នូវនិរោធ ដោយអរិយមគ្គ នេះជាមគ្គសច្ចៈ ។

សច្ចៈទាំង ២ (ទុក្ខសច្ចៈ និងសមុទយសច្ចៈ) លោកបានពោលទុកហើយដោយសរុប ដូចដែលពណ៌នាមកនេះ ចំណែក

សច្ចៈ ២ ទៀត (និរោធ និងមគ្គ) គប្បីជ្រាបដោយអំណាចនៃការមិនវិលត្រឡប់ ។

បទថា **សោ សព្វសោ រាគានុសយំ បហាយ** (អរិយសាវកនោះ លះបង់នូវរាគានុស័យ បានដោយប្រការទាំងពួង) ដោយសេចក្ដីថា លោកដឹងច្បាស់នូវអកុសលជាដើម ដោយប្រការយ៉ាងនេះហើយ ក៏លះនូវរាគានុស័យបានដោយអាការគ្រប់យ៉ាង។

បទថា **បដិឃានុសយំ បដិវិនោទេត្វា** (បន្ទោបង់នូវបដិឃានុស័យ) មានពាក្យដែលលោកពោលទុកថា នាំបដិឃានុស័យចេញបាន ដោយប្រការទាំងពួង។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ព្រះថេរៈបានពោលដល់អនាគាមិមគ្គ ។

បទថា **អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា** (ដកចេញនូវមានានុស័យ ប្រហែលគ្នានឹងទិដ្ឋិថា អាត្មាអញមាន) ដោយសេចក្ដីថា ដកចេញនូវទិដ្ឋិមានានុស័យ ដែលប្រព្រឹត្តទៅដោយអាការប្រកាន់រួមគ្នាយ៉ាងនេះថា យើងមាន ។ បណ្ដាបទទាំងនោះ បទថា **ទិដ្ឋិមានានុសយំ** លោកអធិប្បាយទុកថា បានដល់មានានុស័យដែលប្រហែលគ្នានឹងទិដ្ឋិ ព្រោះមានលក្ខណៈប្រព្រឹត្តទៅហើយថា យើងមាន ព្រោះដូច្នោះ លោកទើបបានពោលទុកយ៉ាងនេះឯង ។ បុគ្គលដែលមានបំណងនឹងឱ្យយល់អំពីអស្មិមានៈនេះ



ដោយពិស្ដារ គប្បីត្រួតមើល **ខេមកសូត្រ** ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ (បិដកលេខ ៣៣) តាមសេចក្ដីប្រាថ្នាចុះ ។

បទថា **អវិជ្ជំ បហាយ** ដោយសេចក្ដីថា លះអវិជ្ជាដែលជាឫសគល់នៃវដ្តៈ ។

បទថា **វិជ្ជំ ឧប្បាទេត្វា** ដោយសេចក្ដីថា ឱ្យវិជ្ជាគឺអរហត្តមគ្គដែលមានកិច្ចកម្ចាត់នូវអវិជ្ជា កើតឡើង ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ព្រះសារីបុត្តដ៏មានអាយុ បានពោលដល់អរហត្តមគ្គ ។

ក្នុងចំណុចដែលថា **ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ** (ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះតែម្ដង) ដោយសេចក្ដីថា ជាអ្នកធ្វើការកាត់ផ្ដាច់វដ្តទុក្ខ ក្នុងអត្តភាពនេះតែម្ដង ។

ព្រះសារីបុត្ត បានញ៉ាំងព្រះធម៌ទេសនាឱ្យចប់ដោយពាក្យថា

**ឯត្តាវតាបិ ខោ អាវុសោ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ ឧជុគតាស្ស ទិដ្ឋិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ អាគតោ ឥមំ សទ្ធម្មន្តិ** ។

ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាអ្នកមាននូវសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិន

ញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

អធិប្បាយថា ដោយអំណាចនៃការចាក់ធ្លុះ ដោយមនសិការ ដូចដែលបានពោលហើយក្នុងការសម្តែងនូវកម្មបថ ដូច្នេះ ព្រះសារីបុត្ត ទើបបានបញ្ចប់ព្រះធម៌ទេសនា ដោយអនាគាមិមគ្គ និងអរហត្តមគ្គ ដូចបានពណ៌នាមកនេះឯង ។

ប្រារព្ធព្រះមហាកស្សបត្ថេរ ពិចារណាមើលសត្វលោក

**បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ**
**បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ**
**បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។**

កាលណាបណ្ឌិត បន្ទោបង់នូវសេចក្តីប្រមាទដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក។ ធីរជន តែងពិចារណាឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដីដូច្នោះឯង ។



# សម្មាទិដ្ឋិសូត្រ (ត)

(បិដកលេខ ២០ , ទំព័រ ១៥៥)

ភិក្ខុទាំងឡាយនោះ ត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្តដ៏មានអាយុ ដោយពាក្យថា ល្អប្រពៃហើយលោកដ៏មានអាយុ ។ ទើបសួរប្រស្នាតទៅទៀតនឹងព្រះសារីបុត្តដ៏មានអាយុថា បពិត្រ លោកដ៏មានអាយុ អរិយសាវក័ ជាអ្នកមាននូវសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៀត មានដែរឬ ។

ព្រះសារីបុត្តដ៏មានអាយុ បានឆ្លើយថា ម្នាលអាវុសោទាំងឡាយមានដែរ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក័ ដឹងច្បាស់នូវអាហារផង ដឹងច្បាស់នូវការកើតឡើងនៃអាហារផង ដឹងច្បាស់នូវការរលត់អាហារផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់នូវអាហារផង ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក័ ជាអ្នកមាន នូវសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

ម្នាលអាវុសោទាំងឡាយ អាហារតើដូចម្តេច ការកើតឡើងនៃអាហារតើដូចម្តេច ការរលត់អាហារតើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាហារតើដូចម្តេច ។

ម្នាលអាវុសោទាំងឡាយ អាហារ ៤ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ ដល់ពួកសត្វដែលជាភូតផង ដើម្បីអនុគ្រោះ ដល់ពួកសត្វដែលជាសម្ភវេសីផង ។ អាហារ ៤ យ៉ាងតើដូចម្តេច ។ កវឡិង្ការាហារ គឺអាហារធ្វើជាពំនូតគ្រោតគ្រាតឬល្អិត ជាអាហារទី ១ ផស្សាហារ ជាអាហារទី ២ មនោ-សញ្ចេតនាហារជាអាហារទី ៣ និងវិញ្ញាណាហារជាអាហារទី ៤។

ការកើតឡើងនៃអាហារ ព្រោះការកើតឡើងនៃតណ្ហា ការរលត់អាហារ ព្រោះការរលត់តណ្ហា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិក្នុងដំណើរទៅដើម្បីរំលត់នូវអាហារ គឺសម្មាទិដ្ឋិ ១ , សម្មាសង្កប្បៈ ១ , សម្មាវាចា ១ , សម្មាកម្មន្តៈ ១ , សម្មាអាជីវៈ ១, សម្មាវាយាមៈ ១, សម្មាសតិ ១ និងសម្មាសមាធិ ១ ។

ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ដឹងច្បាស់នូវអាហារយ៉ាងនេះផង ដឹងច្បាស់នូវការកើតឡើងនៃអាហារយ៉ាងនេះផង



ដឹងច្បាស់នូវការរលត់អាហារយ៉ាងនេះផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិជាដំណើរ ដើម្បីរំលត់នូវអាហារយ៉ាងនេះផង ។

ក្នុងកាលណា អរិយសាវកនោះ លះបង់នូវរាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យដែលប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់អវិជ្ជាហើយ ញុំាងវិជ្ជាឱ្យកើតឡើង ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នដោយសព្វគ្រប់ ក្នុងកាលនោះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាអ្នកមាននូវសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

## អដ្ឋកថា

ក្នុងពាក្យថា **សាធាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧលឧ អាគតោ ឥមំ សទ្ធម្មន្តិ** ។

មានពាក្យអធិប្បាយទុកថា ភិក្ខុទាំងនោះ កាលបានស្តាប់ព្រះធម៌ទេសនាអំពីសច្ចៈទាំង ៤ របស់ព្រះសារីបុត្ត ដោយចំពោះគឺកុសលនិងអកុសលយ៉ាងនេះហើយ ទើបនាំគ្នាពោលសរសើរ

ដោយចិត្តត្រេកអរថា « ល្អប្រពៃហើយ លោកដ៏មានអាយុ » និង អនុមោទនា ដោយចិត្តដែលជាសមុដ្ឋាននៃវាចានោះឯង ។

ជាបន្តទៀត ព្រោះហេតុតែព្រះថេរៈ ជាបុគ្គលអាចសម្តែង នូវព្រះធម៌ទេសនា ប្រកាសចតុរារិយសច្ចបាន ដូចដែលព្រះដ៏មាន ព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តអាចសម្តែង ប្រាប់នូវអរិយសច្ចៈទាំង ៤ បានដោយពិស្តារ ។ ម្យ៉ាងទៀត ព្រោះ ហេតុតែព្រះសារីបុត្ត បំណងនឹងសម្តែងនូវព្រះធម៌ឱ្យខ្ពស់ក្រៃ-លែងឡើងទៀត ទើបបានពោលថា **ឯត្តាវតាបិ ខោ អាវុសោ** (ម្នាលអាវុសោទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ) ។ ព្រោះ ហេតុនោះហើយ ទើបភិក្ខុទាំងឡាយនោះ ដែលសុទ្ធតែជាអ្នកមាន បំណងនឹងស្តាប់នូវសច្ចទេសនា ដោយន័យដទៃទៀត ក៏បានសួរ បញ្ហាដ៏ខ្ពង់ខ្ពស់ទៅទៀត ចំពោះព្រះសារីបុត្តដ៏មានអាយុ ។ ភិក្ខុ ទាំងនោះ បានសួរបញ្ហាខ្ពង់ខ្ពស់ទៅទៀត ដោយន័យដូច្នេះថា បពិត្រលោកដ៏មានអាយុ នៅមានទៀតឬ បរិយាយដទៃដែលខ្ពស់ ជាងបរិយាយដែលលោកដ៏មានអាយុ សួរហើយឆ្លើយតបដោយ អង្គឯងនោះ ។

ព្រះថេរៈកាលនឹងព្យាករបញ្ហា ឱ្យភិក្ខុទាំងនោះស្តាប់ ទើប បានពោលមានពាក្យជាអាទិ៍ថា **សិយា អាវុសោ** (ម្នាលអាវុសោ



ទាំងឡាយ មានដែរ ) ដូច្នេះឯង ។

## កថាពណ៌នាអាហារវារៈ

## ភូត និង សម្ភវេសី

ពាក្យថា **អាហារ** បានដល់បច្ច័យ ។ ព្រោះបច្ច័យនាំផល មកឱ្យខ្លួន ដូច្នោះ បច្ច័យទើបហៅថា អាហារ ។

ពួកសត្វដែលកាន់យកកំណើតកើតហើយ ឈ្មោះថា **ភូត** ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **ភូតានំ វា សត្តានំ** ។

ពួកសត្វដែលស្វែងរកសម្ភព គឺការកើត បានដល់ការកើត ឡើង ឈ្មោះថា **សម្ភវេសី** ។

បណ្តាកំណើតទាំង ៤ បែបនោះ ពួកសត្វដែលកើតពីពង ( មានមាន់ជាដើម ) ដែលមិនទាន់ញាស់ក្តី ពួកសត្វកើតពីទឹក (ជលាម្ពុជៈមានមនុស្សជាដើម ) ដែលមិនទាន់ទម្លាយស្រោម សម្រាលក្តី ពួកសត្វកើតពីញើសក្អែល និងពួកសត្វដែលកើតឯង ( ឧបបាតិក ) កំពុងនៅក្នុងខណៈចិត្តជាដំបូងក្តី ទាំងអស់នេះជា **សម្ភវេសី** (ព្រោះកើតមិនទាន់ស្រេច ) ។

ពួកសត្វទាំងនោះ ដែលញាស់ផុតហើយ សម្រាលចេញ ហើយ និងពួកសត្វដែលកើតពីញើសក្អែលក្តី កើតឯងក្តី រាប់តាំងពី

ខណៈចិត្តទី ២ ទៅ ឈ្មោះថា **ភូត** ។

ម្យ៉ាងទៀត ពួកសត្វដែលកើតដោយឥរិយាបថណាក៏ដោយ ដរាបណា នៅមិនទាន់ផ្លាស់ប្តូរឥរិយាបថជាយ៉ាងដទៃទេ ដរាបនោះ ឈ្មោះថា **សម្ភវេសី** លុះបន្តអំពីឥរិយាបថនោះទៅ ទើបឈ្មោះថា **ភូត** ។

និងម្យ៉ាងទៀត ពួកសត្វដែលកើតហើយ គឺកើតឡើងហើយ (សម្រេចហើយ) ឈ្មោះថា **ភូត** ។ ព្រះខីណាស្រពទាំងឡាយណា ដែលឈប់មានជាតិតទៅទៀតនោះ ពាក្យថា **ភូត** នេះគឺជាឈ្មោះនៃព្រះខីណាស្រពទាំងឡាយនោះ ។ ឯពួកសត្វណា ដែលកំពុងស្វែងរកការកើត ពួកសត្វនោះ ឈ្មោះថា **សម្ភវេសី** ។ ពាក្យថា **សម្ភវេសី** នេះ ជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជន ដែលជាអ្នកកំពុងស្វែងរកការកើត តទៅទៀត ព្រោះលះសំយោជនៈក្នុងភពមិនទាន់បាន ។

បទថា **ឋិតិយា** ( ដើម្បីការតាំងនៅ ) គឺដើម្បីមិនឱ្យធម៌ទាំងឡាយ ដែលកើតឡើងហើយដល់សត្វនោះៗ ដាច់តំណគ្នា គឺមិនអាចជាប់តគ្នាបាន ។

បទថា **អនុគ្គហាយ** ( ដើម្បីអនុគ្រោះ ) គឺដើម្បីឱ្យធម៌ដែលនៅមិនទាន់កើត បានកើតឡើង ។



ទាំងពីរបទនេះ (ឋិតិយា និង អនុគ្គហាយ ) គួរប្រើក្នុងសេចក្តីទាំងពីរយ៉ាង គឺថា ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះដល់ភូតទាំងឡាយផង ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះដល់សម្ភវេសីទាំងឡាយផង ។

## កវឡិង្ការាហារជាដើម

អាហារដែលត្រូវធ្វើឱ្យជាដុំៗ រួចហើយបរិភោគលេបចូលទៅ ឈ្មោះថា **កពឡិង្ការាហារ** ។ ពាក្យថា **កពឡិង្ការាហារ** នេះ ជាឈ្មោះរបស់ឱជា មានបាយឆ្អិន និងនំស្រស់ជាដើម ជាទីតាំង ។

ពីរបទថា **ឱឡារិកោ វា សុខុមោ វា** ដោយសេចក្តីថា អាហារ ឈ្មោះថាឱឡារ ព្រោះជារបស់គ្រោតគ្រាត ដោយវត្ថុ និងឈ្មោះថាសុខុម ព្រោះជារបស់ល្អិត ដោយវត្ថុ ។

តាមដោយសភាវៈ (រូបបរមត្ថ ) កវឡិង្ការាហារ ឈ្មោះថាជារបស់ល្អិតស្រេចទៅហើយ ព្រោះជាសភាវៈដែលរាប់បញ្ចូលក្នុងសុខុមរូប ។ ដែលជាអាហារគ្រោតគ្រាត ឬល្អិត ដោយវត្ថុនោះ ព្រោះប្រៀបធៀបគ្នារវាងអាហារសត្វតិរច្ឆាន បន្តមកដល់អាហាររបស់មនុស្ស រហូតដល់អាហាររបស់ទេវតា ។

ក្នុងចំនួនវត្ថុ និងឱជា ទាំង ២ យ៉ាងនោះ វត្ថុគ្របសង្កត់

នូវការក្រវល់ក្រវាយព្រោះឃ្លានបាន តែមិនអាចរក្សាជីវិតទុកបាន ឡើយ ។ ចំណែក ឱជា រក្សាជីវិតទុកបាន តែមិនអាចគ្របសង្កត់នូវការក្រវល់ក្រវាយព្រោះឃ្លានបានទេ ។ ទាំងពីរយ៉ាងនោះ រួមចូលគ្នាហើយ រមែងរម្ងាប់នូវភាពក្រវល់ក្រវាយដោយការស្រេកឃ្លានបានផង និងរក្សាជីវិតបានផង ដូច្នេះឯង ។

បទថា **ផស្សោ ទុតិយោ** ដោយសេចក្ដីថា ផស្សៈទាំង ៦ យ៉ាង មានចក្ខុសម្ផស្សជាដើម គប្បីជ្រាបថា ជាអាហារទី ២ ក្នុងចំនួនអាហារ ៤ យ៉ាងនោះ ។

ចេតនានោះឯង ឈ្មោះថា **មនោសញ្ចេតនាហារ** ។

ចិត្តដួងណាមួយក៏ដោយ ឈ្មោះថា **វិញ្ញាណាហារ** ។

ក្នុងរឿងនេះ ព្រះសារីបុត្តដ៏មានអាយុ បានពោលទុកថា បើមានពាក្យសួរថា សត្វរស់នៅបានព្រោះអាហារ ឋិតនៅបានព្រោះបច្ច័យ កាលបើបច្ច័យដទៃរបស់សត្វទាំងឡាយមានផ្សេងទៀត ព្រោះហេតុអ្វី បានជាព្រះដ៏មានព្រះភាគត្រាស់សម្ដែងអំពីអាហារ មានតែ ៤ យ៉ាងប៉ុណ្ណោះ ។

ខ្ញុំព្រះករុណា ( សារីបុត្ត ) នឹងពោលតបថា ព្រះអង្គត្រាស់ទុក ព្រោះជាបច្ច័យពិសេស នៃសន្តតិខាងក្នុង ។

អធិប្បាយថា កវឡិង្ការាហារ ជាបច្ច័យពិសេស នៃរូបកាយ



របស់សត្វទាំងឡាយ ដែលជាអ្នកមានកវឡិង្ការាហារជាអាហារ ។ ផស្សាហារ ជាបច្ច័យពិសេសនៃវេទនាក្នុងពួកនាមធម៌ ។ មនោ-សញ្ចេតនាហារ ជាបច្ច័យពិសេសនៃវិញ្ញាណ ( អភិសង្ខារជាបច្ច័យនៃវិបាកវិញ្ញាណ ) ។ វិញ្ញាណាហារ ជាបច្ច័យពិសេសនៃនាមរូប។

សួរថា : ក្នុងអាហារវារៈនេះ អាហារអ្វី នាំអ្វីមកឱ្យ ?

ឆ្លើយថា : កវឡិង្ការាហារ នាំរូបមានឱជៈជាគម្រប់ ៨ មកឱ្យ ( បឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ និងឱជា ) ។ ផស្សាហារ នាំវេទនា ៣ មកឱ្យ ។ មនោសញ្ចេតនាហារ នាំភព ៣ មកឱ្យ ។ វិញ្ញាណាហារ នាំនាមរូបក្នុងបដិសន្ធិមកឱ្យ ។

កវឡិង្ការាហារ ជាអាហារដែលតាមរក្សានូវកម្មជរូប និងជាសមុដ្ឋាននៃអាហារជរូប ដូច្នេះរាងកាយទើបឋិតនៅបាន ។

ផស្សាហារ កាលដែលពាល់ត្រូវអារម្មណ៍ ដែលជាទីតាំងនៃសុខវេទនាជាដើម ដូច្នេះឯង ទើបឈ្មោះថា មាននៅ ដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការវិលវល់នៃសុខវេទនា និងទុក្ខវេទនាជាដើមនោះ ។

មនោសញ្ចេតនាហារ កាលដែលប្រមូលទុកដោយអំណាចនៃកុសលកម្ម និងអកុសលកម្មនោះឯង ក៏ឈ្មោះថា មាននៅដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការញ៉ាំងឫសគល់នៃភពឱ្យ

សម្រេច ។

វិញ្ញាណាហារ កាលដឹងច្បាស់នូវអារម្មណ៍នោះឯង ក៏បាន ឈ្មោះថា មាននៅដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការប្រព្រឹត្តទៅនៃនាមរូប ។

## ភ័យក្នុងអាហារ ៤

ក្នុងអាហារទាំង ៤ យ៉ាងនេះ ដែលឱ្យសម្រេចនូវ អាហារកិច្ចដោយអំណាចនៃការឧបត្ថម្ភជាដើម គួរឃើញភ័យ ៤ ប្រការ។ ក្នុងកវឡិង្ការាហារ បានដល់ភ័យគឺ សេចក្តីប្រាថ្នា ។ ក្នុងផស្សាហារ បានដល់ភ័យគឺ ការជាប់ជំពាក់ ។ ក្នុងមនោសញ្ចេតនាហារ បានដល់ភ័យគឺការប្រមូលមក ( ពោលគឺការសន្សំកម្ម ) ។ ឯ វិញ្ញាណាហារ បានដល់ភ័យគឺការធ្លាក់ចុះកាន់កំណើត (ពោលគឺ បដិសន្ធិនោះឯង ) ។

ព្រោះហេតុអ្វី ?

ព្រោះថា សត្វទាំងឡាយសាងភ័យ គឺសេចក្តីប្រាថ្នាក្នុង កវឡិង្ការាហារ ប្រឈមមុខនឹងក្តៅរងាជាដើម ។ ធ្វើការងារផ្សេងៗ ដើម្បីត្រូវការអាហារ រមែងចូលដល់សេចក្តីទុក្ខមិនតិចតួចឡើយ ។ បុគ្គលខ្លះ សូម្បីបានបួសក្នុងព្រះសាសនានេះហើយ



ក៏ដោយ ក៏នៅមានការស្វែងរកអាហារ ដោយការស្វែងរកដែលពុំសមគួរ មានវេជ្ជកម្មជាដើម ។ ព្រោះការចិញ្ចឹមជីវិតខុស ក៏បានទៅជាបុគ្គលដែលត្រូវគេនិន្ទាពោលទោសក្នុងបច្ចុប្បន្ននេះ ដល់ទៅក្នុងភពខាងមុខ ក៏កើតជាសមណប្រេត ដោយន័យដែលបានពោលទុកហើយក្នុងលក្ខណសំយុត្ត មានជាអាទិ៍ថា សូម្បីសង្ឃាដីរបស់អ្នក ក៏ត្រូវភ្លើងឆេះទ្រលោមហើយ សេចក្តីប្រាថ្នាក្នុងកវឡិង្ការាហារនោះឯង គប្បីជ្រាបថាជាភ័យ ព្រោះហេតុនេះឯង ។

ជនទាំងឡាយដែលមានអស្សាទៈ (ត្រេកអរជាប់ចិត្ត ) ក្នុងផស្សៈ ក៏ប្រព្រឹត្តខុសចំពោះភរិយារបស់អ្នកដទៃ ដែលស្វាមីគេរក្សាគ្រប់គ្រង ឬក៏ប្រព្រឹត្តអទិន្នាទានជាដើម កាលដែលម្ចាស់គេចាប់បាន គេកាប់ដាច់ជាកំណាត់ៗ ហើយបោះចោលក្នុងគំនរសំរាម ពុំនោះទេ គេចាប់ប្រគល់ឱ្យដល់ព្រះរាជា ។ តទៅទៀតព្រះរាជាក៏ត្រាស់បង្គាប់ឱ្យធ្វើទណ្ឌកម្ម ដោយប្រការផ្សេងៗ លុះដល់ស្លាប់ទៅ ក៏ត្រូវបានទទួលភ័យ គឺទុគ្គតិ ។ កម្មដែលមានអស្សាទៈក្នុងផស្សៈ ជាឫសគល់ ជាហេតុឱ្យជួបប្រសព្វភ័យទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ដោយប្រការដូច្នេះ ។

ចំណែកឯភ័យក្នុងភពទាំង ៣ ដែលមានកុសល និង

អកុសលកម្មនោះ ជាមូលដ្ឋាន ភ័យនោះនឹងមកដោយសព្វគ្រប់ទាំងអស់ ព្រោះការប្រមូលមក នូវកុសលកម្ម និងអកុសលកម្មនោះឯង ។ ព្រោះហេតុនេះ ការប្រមូលមកក្នុងមនោសញ្ចេតនាហារនោះឯង គប្បីជ្រាបថា ជាភ័យ ។

រីឯបដិសន្ធិវិញ្ញាណវិញ ក៏រមែងទទួលមកនូវបដិសន្ធិនាមរូបនោះឯង កើតឡើងក្នុងទីដែលចាប់កំណើត និងកាលដែលបដិសន្ធិវិញ្ញាណនោះ កើតឡើងហើយ ភ័យគ្រប់យ៉ាងក៏កើតឡើងដូចគ្នា ព្រោះមានបដិសន្ធិនោះជាឫសគល់ ។ ព្រោះហេតុដូចដែលពណ៌នាមកហើយនេះឯង ការចាប់កំណើត គឺបដិសន្ធិវិញ្ញាណ គប្បីជ្រាបថា ជាភ័យក្នុងវិញ្ញាណាហារ ដូច្នេះឯង ។

(ការកំណត់ដឹងនូវអាហារទាំង ៤ ដើម្បីកម្ចាត់បង់នូវភ័យ គប្បីសិក្សាក្នុង **បុត្តមំសសូត្រ** ក្នុងសំយុត្តនិកាយ និទានវគ្គ ជាបន្តទៀត ) ។

| |
|---|
| ព្រះពុទ្ធប្រៀបដូចជាអ្នកដុតព្រៃ ព្រះធម៌ដុតព្រៃគឺ កិលេស ប្រៀបដូចជាភ្លើងដុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាស្រែ ព្រោះដុតព្រៃអស់ហើយ ។ |



# បុត្តមំសសូត្រ

(បិដកលេខ ៣១ , ទំព័រ ២១៤-២២១ )

ទ្រង់គង់នៅទៀបក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែង ។ ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នោះ ប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។ អាហារ ៤ តើដូចម្តេច ។ កវឡីការាហារ ដ៏គ្រោតគ្រាតក្តី ល្អិតក្តីជាទីមួយ ផស្សាហារជាទីពីរ មនោសញ្ចេតនាហារជាទីបី វិញ្ញាណាហារជាទីបួន ។ ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នេះឯង ប្រព្រឹត្តទៅដើម្បីការតាំងនៅបាននៃពួកភូតសត្វផងដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។

ម្នាលភិក្ខុទាំងឡាយ កវឡីការាហារ តើត្រូវយល់ដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ដូចជាភរិយាស្វាមីពីរនាក់ គប្បីនាំយកស្បៀងតិចតួចដើរទៅកាន់ផ្លូវលំបាក ស្វាមីភរិយានោះ មានកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្ត ។ ម្នាលភិក្ខុទាំងឡាយ គ្រាកាលដែលភរិយាស្វាមីទាំងពីរនាក់ កំពុងដើរទៅកាន់ផ្លូវលំបាកនោះ ស្បៀងបន្តិចបន្តួចនោះ អស់រលីងទៅ ផ្លូវលំបាកនោះ នៅសល់ឆ្លងមិនទាន់ផុត ។ ម្នាលភិក្ខុទាំងឡាយ ទើបភរិយាស្វាមីទាំងពីរ

នាក់នោះ ប្រឹក្សាគ្នាយ៉ាងនេះថា ស្បៀងអាហារបន្តិចបន្តួចរបស់យើងនោះ អស់រលីងទៅហើយ ផ្លូវលំបាកនៅសល់ឆ្លងមិនទាន់ផុតឡើយ បើដូច្នោះ យើងត្រូវសម្លាប់កូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តនេះ ធ្វើជាងៀតផង ជាផ្អកផង កាលបើយើងទាំងពីរនាក់ ស៊ីសាច់កូននោះហើយ នឹងឆ្លងផ្លូវលំបាកដែលនៅសល់នោះផុតបាន បើមិនដូច្នោះ យើងទាំងអស់គ្នា មុខជានឹងស្លាប់ទាំងបីនាក់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ភរិយាស្វាមីទាំងពីរនាក់នោះ សម្លាប់កូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តនោះ ធ្វើជាងៀតផង ជាផ្អកផង កាលបើភរិយាស្វាមីទាំងពីរនាក់ស៊ីសាច់កូនហើយ ទើបដើរឆ្លងផ្លូវលំបាកដែលនៅសល់នោះឱ្យផុតបាន ភរិយាស្វាមីនោះ ស៊ីសាច់កូនផង រីតទ្រូងផងថា ហៃកូនប្រុសតែមួយ អ្នកឯងនៅឯណា ហៃកូន ប្រុសតែមួយ អ្នកឯងនៅឯណា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ដំណើរនោះថាដូចម្តេច ភរិយាស្វាមីនោះ លេបអាហារដើម្បីការលេងលេបអាហារដើម្បីការស្រវឹង លេបអាហារដើម្បីការប្រដាប់តាក់តែង លេបអាហារដើម្បីការស្អិតស្អាង ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភរិយាស្វាមីនោះ គ្រែងលេបអាហារ គ្រាន់តែដើម្បីនឹងឆ្លងផ្លូវ



លំបាកឱ្យផុតតែប៉ុណ្ណោះទេឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នករាល់គ្នា យល់កវឡីការាហារក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលកំណត់ដឹងកវឡីការាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងរាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ដែរ កាលបើកំណត់ដឹងរាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ហើយ អរិយសាវ័ក ដែលប្រកបដោយសំយោជនៈណាហើយ ត្រូវត្រឡប់មកកាន់លោកនេះម្តងទៀត សំយោជនៈនោះមិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ ផស្សាហារ តើត្រូវយល់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេគោដែលមិនមានស្បែក បើឈរផ្អែកនឹងជញ្ជាំង ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងជញ្ជាំងនោះខាំ បើឈរផ្អែកនឹងដើមឈើ ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងដើមឈើនោះខាំ បើឈរត្រាំនៅក្នុងទឹក ក៏ត្រូវពួកសត្វដែលអាស្រ័យនៅក្នុងទឹកនោះចឹកប្របិច បើឈរកណ្តាលវាល ក៏ត្រូវពួកសត្វដែលអាស្រ័យនៅនឹងអាកាសនោះខាំ ម្នាលភិក្ខុទាំងឡាយ មេគោដែលមិនមានស្បែកនោះ ឈរនៅក្នុងទីណាៗ ក៏គង់តែពួកសត្វដែលអាស្រ័យនៅក្នុងទីនោះៗ ខាំស៊ី យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នករាល់គ្នាយល់ផស្សាហារ ក៏

យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងផស្សាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងនូវវេទនាទាំងបីដែរ កាលបើកំណត់ដឹងនូវវេទនាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវ័កត្រូវធ្វើតទៅទៀតមិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនាហារ តើត្រូវយល់ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ដូចជារណ្ដៅរងើកភ្លើង មានជម្រៅជាងមួយជួរបុរស ពេញដោយរងើកភ្លើង ឥតមានអណ្ដាត ឥតមានផ្សែង ជួនជាមានបុរសអ្នកប្រាថ្នាចង់រស់នៅ មិនប្រាថ្នាការស្លាប់ ស្រឡាញ់សុខ ខ្ពើមទុក្ខ ដើរមក ស្រាប់តែបុរសពីរនាក់មានកម្លាំងចាប់បុរសនោះ ត្រង់ដើមដៃម្ខាងម្នាក់ ទាញទម្លាក់ទៅក្នុងរណ្ដៅរងើកភ្លើងនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ បុរសនោះ សមជាមានចេតនាគិតចង់ឱ្យឃ្លាត មានប្រាថ្នាចង់ឱ្យឆ្ងាយ មានបំណងចង់ឱ្យឃ្លាងអំពីរណ្ដៅរងើកភ្លើងនោះ ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះបានដឹងជាក់លាក់ថា បើអាត្មាអញនឹងធ្លាក់ទៅក្នុងរណ្ដៅរងើកភ្លើងនេះ អាត្មាអញមុខជានឹងដល់នូវសេចក្ដីស្លាប់ ឬដល់នូវសេចក្ដីទុក្ខស្មើរនឹងស្លាប់ ព្រោះតែការធ្លាក់ទៅក្នុងរណ្ដៅរងើកភ្លើងនោះជាហេតុ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវ



អ្នករាល់គ្នាយល់មនោសញ្ចេតនាហារ ក៏ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងនូវមនោសញ្ចេតនាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងនូវតណ្ហាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវ័កត្រូវធ្វើតទៅទៀត មិនមានឡើយ។

ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណាហារ តើត្រូវយល់ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយដូចជាពួករាជបុរស ចាប់បានចោរដែលប្រព្រឹត្តអំពើអាក្រក់ យកមកថ្វាយដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព បុគ្គលនេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តអំពើអាក្រក់ សូមទ្រង់ដាក់អាជ្ញាដល់ចោរនេះ តាមព្រះរាជបំណង ព្រះរាជាមានព្រះបន្ទូលចំពោះបុរសនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនេះ ១០០ លំពែង ក្នុងវេលាព្រឹក រាជបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងវេលាព្រឹក លុះដល់សម័យថ្ងៃត្រង់ ព្រះរាជាត្រាស់សួរយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បុរសនោះដូចម្ដេចទៅ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះនៅរស់ដដែលទេ ព្រះរាជាមានព្រះបន្ទូលចំពោះបុរសនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃត្រង់ រាជបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យ

ថ្ងៃត្រង់ លុះដល់សម័យថ្ងៃរសៀល ព្រះរាជាត្រាស់សួរយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បុរសនោះដូចម្ដេចទៅ រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះនៅរស់ដដែលទេ ព្រះរាជាមានព្រះបន្ទូលចំពោះបុរសនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយទៅប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃរសៀល រាជបុរសក៏ប្រហារបុរសនោះ ១០០ លំពែង ក្នុងសម័យថ្ងៃរសៀល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្ដីនោះដូចម្ដេច កាលបើបុរសនោះត្រូវគេប្រហារ ៣០០ លំពែងក្នុងមួយថ្ងៃ នឹងរងទុក្ខទោមនស្ស ព្រោះហេតុតែគេប្រហារនោះ ម្នាលភិក្ខុទាំងឡាយ កាលបើបុរសនោះត្រូវគេប្រហារត្រឹម ១ លំពែងប៉ុណ្ណោះ ក៏រងទុក្ខទោមនស្ស ព្រោះតែគេប្រហារ ១ លំពែងនោះទៅហើយ ចុះបើ ត្រូវគេប្រហារដល់ ៣០០ លំពែងនោះ មិនបាច់និយាយទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ត្រូវអ្នករាល់គ្នាយល់វិញ្ញាណាហារក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងវិញ្ញាណាហារហើយ ក៏ឈ្មោះថាបានកំណត់ដឹងនូវនាមនិងរូបដែរ កាលបើកំណត់ដឹងនូវនាម និងរូបហើយ តថាគតពោលថា កិច្ចណាមួយដែលអរិយសាវ័កត្រូវធ្វើតទៅទៀត មិនមានឡើយ ។



## អដ្ឋកថា បុត្តមំសសូត្រ

ក្នុងពាក្យថា **ចត្តារោមេ ភិក្ខវេ អាហារា** ជាដើម មានន័យដូចដែលបានពោលហើយនោះឯង ។ ព្រះសូត្រនេះតាំងឡើងដោយអត្ថុប្បត្តិ តើអត្ថុប្បត្តិអ្វី ? ឆ្លើយថា ដោយរឿងលាភ និងសក្ការៈ ។

បានឮមកថា លាភនិងសក្ការៈជាច្រើនបានកើតឡើងដល់ព្រះដ៏មានព្រះភាគ អាស្រ័យព្រះបារមីដែលព្រះអង្គទ្រង់បំពេញមកអស់កាលដ៏យូរអង្វែង ។ ពិតណាស់ ព្រះបារមីទាំងអស់របស់ព្រះដ៏មានព្រះភាគ ហាក់បីដូចជាប្រមូលគ្នាមកថា យើងនឹងឱ្យផលវិបាក ក្នុងមួយអត្តភាពនេះ ទើបញ៉ាំងនូវអន្លង់ទឹកធំគឺលាភនិងសក្ការៈឱ្យកើតឡើង ដូចជាមហាមេឃបង្អុរភ្លៀង ញ៉ាំងអន្លង់ទឹកធំឱ្យកើតមានដូច្នោះ ។ ជនទាំងឡាយ មានក្សត្រនិងព្រាហ្មណ៍ជាដើម នាំយកបាយ ទឹក យាន សំពត់ កម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើម មកអំពីទីនោះៗ នាំគ្នាគិតថា ព្រះសម្មាសម្ពុទ្ធគង់នៅក្នុងទីណា ព្រះដ៏មានព្រះភាគគង់នៅក្នុងទីណា ព្រះអង្គជាទេវតានៃទេវតា អង់អាចជាងនរៈ ជាមហាបុរស ដូចជារាជសីហ៍ គង់នៅក្នុងទីណា ដូចនេះហើយទើបស្វែងរកនូវព្រះដ៏-

មានព្រះភាគ ។ ជនទាំងនោះ នាំបច្ច័យមក ជាច្រើនរយរទេះ កាលមិនបានឱកាសទើបឈប់នៅ យករទេះដាក់តជាប់គ្នាដោយការប្រមូលផ្តុំ ជុំវិញប្រមាណមួយគាវុត ដូចរឿងអន្ធកវិន្ទព្រាហ្មណ៍ដូច្នោះឯង ។ រឿងទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយក្នុងខន្ធកៈនិងក្នុងព្រះសូត្រនោះ។ ។

លាភសក្ការៈកើតដល់ព្រះដ៏មានព្រះភាគយ៉ាងណា សូម្បីដល់ភិក្ខុសង្ឃក៏យ៉ាងនោះដែរ ។ សមដូចពាក្យដែលលោកពោលទុកថា ក៏ដោយសម័យនោះឯង ព្រះដ៏មានព្រះភាគ ជាបុគ្គលដែលត្រូវបរិស័ទធ្វើនូវសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រះអង្គទ្រង់បាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ សូម្បីព្រះសង្ឃ ក៏ជាបុគ្គលដែលពពួកជន ធ្វើនូវសក្ការៈ គោរព ។ល។ ដូច្នោះដែរ ។ ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ ឥឡូវនេះសង្ឃ ឬគណៈ មានប្រមាណប៉ុន្មានណាកើតឡើងក្នុងលោក ម្នាលចុន្ទ តថាគត សម្លឹងរកមើលមិនឃើញ ក្រុមសង្ឃដទៃ ដែលដល់នូវភាព ជាអ្នកលើសដោយលាភ និងលើសដោយយស ដូចជាភិក្ខុសង្ឃនេះឡើយ ។

លាភ និង សក្ការៈដែលកើតឡើងដល់ព្រះដ៏មានព្រះភាគ



និងដល់សង្ឃនោះ រួមហើយប្រមាណមិនបាន ដូចទឹកនៃមហានទីទាំងពីរ ។ លំដាប់នោះ ព្រះសាស្តាទ្រង់គង់ប្រថាប់នៅក្នុងទីស្ងាត់ ព្រះអង្គទ្រង់ព្រះតម្រិះថា លាភនិងសក្ការៈដ៏ធំ បានជារបស់សមគួរ សូម្បីដល់ព្រះពុទ្ធក្នុងអតីត ទាំងនឹងសមគួរដល់ព្រះពុទ្ធក្នុងអនាគត ។ ភិក្ខុទាំងឡាយប្រកបដោយសតិ និងសម្បជញ្ញៈដែលកំណត់យកអាហារជាអារម្មណ៍ ជាអ្នកតម្កល់ខ្លួនជាកណ្តាលប្រាសចាកឆន្ទរាគៈ មិនមានការត្រេកអរពេញចិត្ត អាចបរិភោគឬហ្ន៎ ឬនឹងមិនអាចបរិភោគ ។

ព្រះអង្គទ្រង់បានឃើញកុលបុត្រពួកខ្លះដែលបួសថ្មី ជាអ្នកមិនពិចារណាហើយ បរិភោគអាហារ កាលព្រះអង្គទ្រង់ឃើញទ្រង់ព្រះតម្រិះថា យើងបំពេញបារមីអស់ ៤ អសង្ខេយ្យ កម្រៃសែនកប្ប នឹងបានបំពេញព្រោះហេតុនៃចីវរប្បច្ច័យជាដើមនោះក៏ទេ ដោយពិត គឺបំពេញដើម្បីប្រយោជន៍ បានដល់ព្រះអរហត្តដែលជាផលដ៏ខ្ពង់ខ្ពស់ ។ ភិក្ខុទាំងអស់នេះបួសក្នុងសំណាក់របស់យើង មិនបានបួសព្រោះហេតុនៃបច្ច័យមានចីវរជាដើមឡើយ គឺបួសដើម្បីប្រយោជន៍ដល់ព្រះអរហត្តនោះឯង ។ ឥឡូវនេះ ភិក្ខុទាំងនោះធ្វើនូវរបស់ដែលមិនជាសារៈ ដោយសំគាល់ថាជាសារៈ និងរបស់ដែលមិនជាប្រយោជន៍នោះឯង សំគាល់ថាជារបស់មាន

ប្រយោជន៍ទៅវិញ ។

ធម្មសង្វេគ បានកើតឡើងដល់ព្រះអង្គដោយប្រការដូច្នេះ។

លំដាប់នោះ ព្រះអង្គទ្រង់ព្រះតម្រិះថា បើនឹងអាចបញ្ញត្តបញ្ញួមបារាជិកឡើងបាន យើងនឹងបញ្ញត្តការបរិភោគអាហារដោយមិនពិចារណា ឱ្យជាបញ្ញួមបារាជិក ប៉ុន្តែមិនអាចនឹងធ្វើយ៉ាងនេះបាន ព្រោះថាអាហារនោះ ជាទីសេពអាស្រ័យជាប្រចាំរបស់សត្វទាំងឡាយ តែកាលបើយើងត្រាស់សម្តែងទុក ភិក្ខុទាំងនោះ ក៏នឹងឃើញចំណុចនោះ ដូចជាបញ្ញួមបារាជិកដែរ ។ កាលបើដូច្នោះ យើងនឹងតាំងការបរិភោគអាហារដែលមិនពិចារណានោះ ឱ្យជាកញ្ចក់ធម៌ [១] ជាចំណុចសំវរ ជាព្រំដែនដែលពួកភិក្ខុក្នុងអនាគតរំលឹកហើយ នឹងពិចារណាបច្ច័យ ៤ ជាមុន ទើបបរិភោគ ។

## ការកំណត់ដឹងក្នុងកវឡីការាហារ [២]

បានឮថា ពីរនាក់ភរិយាស្វាមី បីកូនដើរផ្លូវកន្តារ (ផ្លូវឆ្ងាយហើយមានភ័យ ) ប្រមាណ ១០០ យោជន៍ ដោយស្បៀងបន្តិចបន្តួច ។ គេដើរផ្លូវទៅបាន ៥០ យោជន៍ ត្រូវអស់ស្បៀង ហើយ

១.ឆ្លុះបញ្ចាំងមើលទោសដូចជាអាបត្តិបារាជិក ។ ២.កវឡិង្ការាហារ ក៏បាន ។



ក៏រសាប់រសល់ក្រវល់ក្រវាយព្រោះការឃ្លាន អង្គុយនៅក្នុងម្លប់ឈើ ។

លំដាប់នោះស្វាមីបានពោលទៅកាន់ភរិយាដូច្នេះថា ប្រពន្ធសម្លាញ់ តពីនេះទៅនៅ៥០ យោជន៍ទៀត មិនមានស្រុកភូមិនិគមអ្វីឡើយ ដូច្នោះ ឥឡូវនេះយើងមិនអាចនឹងធ្វើកសិកម្ម និងគោរក្ខកម្មជាដើម ដែលដោយច្រើន បុរសគប្បីធ្វើបាន នោះឡើយ មកចុះ នាងចូរសម្លាប់យើង ហើយបរិភោគព្រមទាំងយកធ្វើស្បៀងឆ្លងផ្លូវកន្តារទៅជាមួយនឹងកូនចុះ ។ ចំណែកភរិយាក៏ពោលថា ប្តីសម្លាញ់ ឥឡូវនេះ ខ្ញុំមិនអាចនឹងធ្វើកម្មមានការរវៃអំបោះជាដើម ដែលដោយច្រើនស្ត្រីគប្បីធ្វើបាន នោះឡើយ មកចុះ បងចូរសម្លាប់ខ្ញុំបរិភោគ និងយកធ្វើស្បៀង ហើយចូរឆ្លងផ្លូវកន្តារទៅព្រមជាមួយនឹងកូនចុះ ។ ស្វាមីពោលនឹងភរិយាទៀតថា ប្រពន្ធសម្លាញ់ សេចក្តីស្លាប់រមែងប្រាកដដល់មនុស្សពីរនាក់ព្រោះម៉ែស្លាប់ហើយ កូនតូចក៏មិនអាចមានជីវិតរស់នៅបានដែរ តែបើយើងទាំងពីរនៅមានជីវិត យើងគង់នឹងបានកូនទៀត ឥឡូវមក យើងនឹងសម្លាប់កូនតូចនេះ យកសាច់បរិភោគ ដើម្បីនឹងឆ្លងផ្លូវកន្តារ (ផ្លូវឆ្ងាយហើយអត់បាយ ... ) ។

លំដាប់នោះ ម៉ែពោលទៅកូនថា កូនសម្លាញ់ កូនចូរទៅ

រកឪពុកចុះ ។ កូនក៏បានទៅរកឪពុក ។ គ្រានោះ ឪពុកនៃក្មេងតូចក៏ពោលថា យើងបានទទួលនូវសេចក្ដីទុក្ខមិនតិចឡើយ ព្រោះកសិកម្ម និងគោរក្ខកម្មជាដើម ដើម្បីចិញ្ចឹមកូនតូច យើងមិនអាចសម្លាប់កូនបានឡើយ នាងហ្នឹងហើយ ចូរសម្លាប់កូនរបស់នាង រួចបានពោលទៅកាន់កូនតូចថា កូនសម្លាញ់ កូនចូរទៅរកម្ដាយរបស់កូនចុះ ។ កូនក៏ត្រឡប់ទៅរកម្ដាយវិញ ។ គ្រានោះ ម៉ែបានពោលថា កាលដែលយើងចង់បានកូន យើងបានទទួលសេចក្ដីទុក្ខមិនតិចឡើយ ដោយការបួងសួងទេវតា និងដោយការប្រព្រឹត្តវត្តផ្សេងៗ មានគោវត្ត ( ធ្វើតាមគោ ) កុក្កុរវត្ត ( ធ្វើតាមឆ្កែ ) ជាដើម មិនចាំបាច់និយាយដល់ការរក្សាគភ៌ឡើយ ខ្ញុំមិនអាចសម្លាប់កូនបានទេ ហើយពោលថា កូនសម្លាញ់ ចូរកូនទៅរកឪពុកចុះ ។ កូនតូចនោះ កាលដែលដើរទៅមកក្នុងរវាងឪពុកនិងម្ដាយ ក៏បានស្លាប់ដោយប្រការដូច្នេះឯង ។ ពីរនាក់ប្ដីប្រពន្ធ ឃើញដូច្នោះហើយ ក៏ខ្សឹកខ្សួលអួលណែនដើមទ្រូង យំរៀបរាប់ រួចក៏បានកាន់យកសាច់កូនបរិភោគ ដើរផ្លូវទៅតាមន័យដែលពោលហើយ ។

អាហារ គឺសាច់កូន ដែលឪពុកម្ដាយជាអ្នកបរិភោគ មិនមែនបរិភោគដើម្បីលេង មិនមែនបរិភោគដើម្បីស្រវឹង មិនមែនបរិភោគដើម្បីប្រដាប់តាក់តែងឡើយ ព្រោះសាច់នោះបដិកូល



ដោយហេតុ ៩ ប្រការ គឺគ្រាន់តែជាអាហារដើម្បីឆ្លងផ្លូវកន្តារតែប៉ុណ្ណោះ ។

ប្រសិនបើសួរថា បដិកូលដោយហេតុ ៩ ប្រការនោះ តើអ្វីខ្លះ ។ គប្បីឆ្លើយថា :

១-ព្រោះជាសាច់មនុស្សរួមជាតិ

២-ព្រោះជាសាច់របស់ញាតិ

៣-ព្រោះជាសាច់របស់បុត្រ

៤-ព្រោះជាសាច់របស់កូនជាទីស្រឡាញ់

៥-ព្រោះជាសាច់ក្មេងតូចទន់ខ្ចី

៦-ព្រោះជាសាច់ឆៅ

៧-ព្រោះមិនជាគោរស

៨-ព្រោះមិនប្រៃ

៩-ព្រោះនៅមិនបានអាំង ។

ពិតណាស់ ភរិយាស្វាមីនោះ បរិភោគសាច់កូនឯង ដែលបដិកូលដោយហេតុ ៩ ប្រការដូច្នេះ ទើបមិនបានបរិភោគដោយការត្រេកអរជាប់ចិត្ត ឋិតនៅក្នុងភាវៈជាកណ្ដាលៗ នោះឯង គឺក្នុងការបរិភោគ ដោយមិនមានការត្រេកអរពេញចិត្ត មានចិត្តហាក់ដូចជាបែកធ្លាយ ។ ក្នុងការបរិភោគនោះ គេមិនបានយក

សាច់ដែលជាប់ឆ្អឹងក្តី សរសៃក្តី និងស្បែកក្តីចោលចេញ ហើយបរិភោគតែចំពោះសាច់ល្អៗ នោះទេ ។ គេបរិភោគនូវសាច់ដែលមានចំពោះមុខតែប៉ុណ្ណោះ មិនបានបរិភោគតាមដែលត្រូវការរហូតដល់ហៀរហូរ ពេញមាត់ពេញកឡើយ គឺគេបរិភោគបន្តិចៗគ្រាន់តែញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅមួយថ្ងៃៗ ប៉ុណ្ណោះ ។ មិនបានហួងហែងគ្នានឹងគ្នា ក្នុងការបរិភោគ គឺបរិភោគដោយចិត្តដែលបរិសុទ្ធពិតៗ ប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ ។ មិនបានបរិភោគដោយការវង្វេងថា ពួកយើងបរិភោគសាច់យ៉ាងណាមួយជាសាច់ម្រឹគ ឬក៏សាច់ក្ងោកជាដើមនោះទេ គឺបរិភោគទាំងដែលដឹងថា ជាសាច់របស់កូនជាទីស្រឡាញ់ ។ មិនបានបរិភោគដោយប្រាថ្នាថា ធ្វើដូចម្តេចហ្ន៎ យើងគប្បីបានបរិភោគនូវសាច់កូនដែលមានសភាពបែបនេះទៀត តាមពិត គឺបរិភោគដោយមិនប្រាថ្នា ។ នឹងបានសន្សំដោយតាំងចិត្តថា យើងបរិភោគប៉ុណ្ណោះក្នុងផ្លូវកន្តារកាលដែលផុតផ្លូវកន្តារហើយ នឹងយកសាច់ដែលសល់ ទៅប្រឡាក់អំបិល ឬក៏ស្ងួតម្ហូរជាដើម ដើម្បីបរិភោគក៏ទេដែរ គឺកាលដែលផុតផ្លូវកន្តារហើយ ក៏គិតថា ពួកជនក្នុងស្រុកនឹងឃើញ ទើបកប់ទុកក្នុងដី ឬយកភ្លើងដុត ។ មិនបានប្រកាន់ខ្លួន ឬអួតអាងថា អ្នកណានឹងបានបរិភោគសាច់កូនឯង ដែលមានសភាពបែបនេះ ដូចជា



យើងនេះឡើយ ផ្ទុយមកវិញ គឺបរិភោគដោយការកម្ចាត់បង់នូវសេចក្តីប្រកាន់ខ្លួន និងអំនួតអួតអាង ។ មិនបានបរិភោគដោយការមើលងាយថា ប្រយោជន៍អ្វីដោយសាច់នេះ ដែលមិនជូរ មិនប្រៃ មិនបានអាំង និងមានក្លិនស្អុយឡើយ គឺបរិភោគដោយប្រាសចាកការមើលងាយ ។ មិនមើលងាយគ្នានឹងគ្នាថា ចំណែករបស់យើង ចំណែករបស់អ្នក កូនរបស់យើង កូនរបស់អ្នក គឺមានការព្រមព្រៀងគ្នា ស្រុះស្រួលក្នុងការបរិភោគ ។

ព្រះសាស្តាទ្រង់ពិចារណាឃើញ ពីរនាក់ប្តីប្រពន្ធ បរិភោគដោយប្រាសចាកឆន្ទរាគៈ មានសភាពបែបនេះ កាលដែលព្រះអង្គទ្រង់នឹងឱ្យភិក្ខុសង្ឃជ្រាបហេតុនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តេ ទវាយ វា អាហារំ អាហរេយ្យុំ មទាយ វា អាហារំ អាហរេយ្យុំ មណ្ឌនាយ វា អាហារំ អាហរេយ្យុំ វិភូសនាយ វា អាហារំ អាហរេយ្យុន្តិ។** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ដំណើរនោះថាដូចម្តេច ភរិយាស្វាមីនោះ លេបអាហារដើម្បីការលេង លេបអាហារដើម្បីការស្រវឹង លេបអាហារដើម្បីការស្អិតស្អាងដែរឬ ។

ក្នុងព្រះបាលីនេះ ដែលមានពាក្យជាដើមថា **ទវាយ វា** បានពោលទុកពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ឯវមេវ ខោ** ដោយសេចក្ដីថា គប្បីឃើញអាហារ ដូចសាច់កូនជាទីស្រឡាញ់ ដោយអំណាចភាពជារបស់បដិកូល ៩ យ៉ាង ។

សួរថា ភាពជារបស់បដិកូល ៩ យ៉ាង បានដល់អ្វីខ្លះ ។

ឆ្លើយថា មានភាពជារបស់បដិកូលក្នុងការទៅជាដើម ។ ពិតណាស់ កាលពិចារណាភាពបដិកូលដោយការទៅក្ដី (ទៅបិណ្ឌបាត ) កាលពិចារណាភាពបដិកូលដោយការស្វែងរកក្ដី កាលពិចារណាភាពបដិកូលដោយការបរិភោគ ដោយទីកប់ទុក (ក្នុងក្រពះ ) ដោយទីអាស្រ័យ (ក្នុងកាយ ) ដោយជារបស់មិនទាន់រលួយ ដោយជារបស់រលួយហើយ ដោយជារបស់ប្រឡាក់ និងដោយជារបស់ហូរចេញក្ដី ឈ្មោះថា រមែងកំណត់កវឡិង្ការាហារ។ ភាពបដិកូលដោយការទៅជាដើម ទាំងអស់នេះ បានពោលទុកដោយពិស្ដារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ពីរនាក់ប្ដីប្រពន្ធនោះ កាលបរិភោគសាច់កូនជាទីស្រឡាញ់ ដែលជារបស់បដិកូល មិនបានបរិភោគដោយសេចក្ដីត្រេកអរ ជាប់ចិត្តឡើយ គឺតាំងនៅក្នុងភាវៈកណ្ដាលៗ នោះឯង យ៉ាងណា ភិក្ខុគប្បីបរិភោគអាហារដោយមិនមានការត្រេកអរពេញចិត្ត ក៏យ៉ាងនោះដែរ ។



ដូចបែបយ៉ាងថា ពីរនាក់ប្ដីប្រពន្ធនោះ នឹងបានយកសាច់ដែលជាប់ឆ្អឹង សរសៃ និងស្បែកចេញ ហើយបរិភោគតែចំពោះសាច់ល្អៗ ប៉ុណ្ណោះក៏ទេ គឺបរិភោគសាច់ដែលចាប់ដល់ (ដោយមិនរើសអើង ) យ៉ាងណា ភិក្ខុ មិនគប្បីប្រើខ្នងដៃកៀរបាយក្រៀម និងបាយរឹងជាដើមចេញ មិនសម្ដែងការចោះចំពោះ ដូចចាប និងមាន់ឡើយ មិនបានជ្រើសរើសយកតែភោជនដែលល្អ ដែលផ្សំដោយទឹកដោះថ្លា និងសាច់ជាដើម អំពីទីនោះៗបរិភោគទេ គប្បីបរិភោគតាមលំដាប់ដូចរាជសីហ៍ យ៉ាងនោះ ។

ដូចបែបយ៉ាងជាបន្តបន្ទាប់ទៀតថា ពីរនាក់ប្ដីប្រពន្ធនោះ មិនបានបរិភោគតាមតែត្រូវការ រហូតហៀរហូរនោះឡើយ គឺបរិភោគបន្តិចៗល្មមនឹងញុំាងជីវិតឱ្យប្រព្រឹត្តទៅបាន ក្នុងមួយថ្ងៃៗ ប៉ុណ្ណោះ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ មិនបរិភោគតាមដែលត្រូវការ រហូតដល់រើមកវិញនោះឡើយ ដូចដែលព្រះសារីបុត្តបន្លឺសីហនាទ បានពោលគាថានេះថា :

ភិក្ខុវៀរចាកការឆាន់នូវដុំបាយ ៤-៥ ដុំ ( មុននឹងឆ្អែត ) ហើយគប្បីឆាន់ទឹក ល្មមដែលនឹងនៅយ៉ាងសប្បាយ សម្រាប់ភិក្ខុដែលមានការបញ្ជូនចិត្តទៅកាន់ព្រះនិព្វាន (មិនអាល័យកាយ មិនអាល័យជីវិត ) ។

ពីរនាក់ប្ដីប្រពន្ធនោះ នឹងបានហួងហែងគ្នានឹងគ្នាក្នុងការបរិភោគ ក៏ទេដែរ គឺបរិភោគដោយចិត្តដ៏បរិសុទ្ធពិត។ ប្រាសចាកមន្ទិលគឺសេចក្ដីកំណាញ់ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានបិណ្ឌបាតហើយ មិនកំណាញ់ឡើយ ដោយគិតថា កាលបើភិក្ខុទទួលបិណ្ឌបាតនេះបានទាំងអស់ យើងក៏នឹងឱ្យទាំងអស់ បើទទួលបានពាក់កណ្ដាល យើងនឹងឱ្យពាក់កណ្ដាល ហើយបើនឹងមានបិណ្ឌបាតសល់អំពីភិក្ខុដែលទទួលទៅនោះ យើងនឹងបរិភោគខ្លួនឯង ភិក្ខុតាំងនៅក្នុងសារាណីយធម៌យ៉ាងមាំមួន ក្នុងការបរិភោគដូច្នេះឯង ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនបានបរិភោគដោយការវង្វេងថា ពួកយើងបរិភោគនូវសាច់យ៉ាងណាមួយ ដែលជាសាច់ម្រឹគ ឬជាសាច់ក្ងោកជាដើម នោះទេ គឺបរិភោគដោយដឹងថាជាសាច់របស់កូនសម្លាញ់ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានបិណ្ឌបាតហើយ មិនគប្បីកើតការវង្វេង គិតឃើញតែពីខ្លួនឯងថា យើងនឹងបរិភោគដូច្នេះឡើយ ។ គប្បីគិតថា កវឡិង្ការាហាររមែងមិនដឹងថា យើងធ្វើកាយដែលអាស្រ័យមហាភូតរូប ៤ នេះ ឱ្យចម្រើនឡើងទេ សូម្បីកាយក៏មិនដឹងថា កវឡិង្ការាហារធ្វើយើងឱ្យចម្រើនដែរ ។ គប្បីលះសេចក្ដីវង្វេងក្នុងការបរិភោគ ដោយអាការយ៉ាងនេះ ។



ពិតណាស់ កវឡិង្ការាហារនេះ ភិក្ខុគប្បីជាអ្នកមិនវង្វេងក្នុងការបរិភោគ អាស្រ័យសតិសម្បជញ្ញៈ ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនបរិភោគ ដោយតាំងសេចក្ដីប្រាថ្នាថា ធ្វើដូចម្ដេចហ្ន៎ យើងគប្បីបានបរិភោគសាច់កូនដែលមានសភាពបែបនេះទៀត ដូច្នេះឡើយ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានភោជនប្រណីតហើយ មិនគប្បីគិតថា ធ្វើយ៉ាងណាហ្ន៎ យើងគប្បីបាននូវភោជនដ៏ប្រណីត ដែលមានសភាពបែបនេះទៀត ក្នុងថ្ងៃស្អែកក្ដី ក្នុងថ្ងៃតទៅទៀតក្ដី ដូច្នេះទេ ។ គ្រាកាលដែលបាននូវភោជនសៅហ្មង ក៏មិនគប្បីគិតថា ថ្ងៃនេះយើងមិនបាននូវភោជនដែលប្រណីតដូចពីម្សិលមិញឡើយដែរ គឺមិនគប្បីធ្វើសេចក្ដីប្រាថ្នា ឬទោមនស្សក្នុងការបរិភោគគប្បីរលឹកដល់ឱវាទនេះថា :

ជនទាំងឡាយ រមែងមិនសោកសៅ ដល់អាហារដែលជាអតីត មិនកង្វល់ដល់អាហារដែលជាអនាគត ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយអាហារដែលជាបច្ចុប្បន្ន ដូច្នោះ ទើបពណ៌សម្បុរផូរផង់ [១] ។

គប្បីបរិភោគដោយគិតថា នឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយអាហារដែលជាបច្ចុប្បន្នប៉ុណ្ណោះ ។

១-បង្ហាញពីចិត្តដែលឥតកង្វល់ ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនបានសន្សំដោយគិតថា យើងនឹងបរិភោគសាច់កូនប៉ុណ្ណេះក្នុងផ្លូវកន្តារ កាលផុតផ្លូវកន្តារទៅហើយ យើងនឹងយកសាច់កូនដែលនៅសល់ ទៅប្រឡាក់អំបិល ស្លម្ងូរ ជាដើម ហើយបរិភោគ ដូច្នេះឡើយ គឺកាលដែលផុតផ្លូវកន្តារទៅហើយ ក៏គិតថា ពួកជនក្នុងស្រុកនេះនឹងឃើញ ទើបកប់ទុកក្នុងផែនដី ឬក៏យកភ្លើងដុត យ៉ាងណា ភិក្ខុក៏គប្បីដូច្នេះដែរ រលឹកដល់ឱវាទនេះថា :

បានបាយ ឬទឹកក៏ដោយ បានរបស់បរិភោគផ្សេងៗ ឬបានសំពត់ក៏ដោយ មិនគប្បីសន្សំ ។ កាលមិនបានរបស់ទាំងនោះ ក៏មិនគប្បីតក់ស្លុត ។ កាន់យកល្មមប្រមាណនឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ អំពីបច្ច័យ ៤ តាមដែលបាននោះៗ ចំណែកដែលសល់ក៏ចែកចាយដល់មិត្តសព្រហ្មចារី ពោលគឺវៀរចាកការសន្សំក្នុងការបរិភោគ ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនមានប្រកាន់ខ្លួន ឬអួតអាងថា អ្នកដទៃណានឹងបានបរិភោគសាច់កូន ដែលមានសភាពបែបនេះដូចជាយើង ដូច្នេះឡើយ គឺបរិភោគដោយមិនមានការប្រកាន់ខ្លួន កម្ចាត់បង់នូវអំនួតអួតអាងបាន យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បាននូវភោជនដ៏ប្រណីតហើយ មិនគប្បីប្រកាន់ខ្លួន ឬមានអំនួត



អួតអាងថា យើងបានចីវរ និងបិណ្ឌបាតជាដើម ដូច្នេះទេ ។ គប្បីពិចារណាថា ការបួសនេះមិនមែនព្រោះហេតុនៃចីវរជាដើមឡើយ ការបួសនេះ ព្រោះហេតុនៃព្រះអរហត្តទេតើ ។ ភិក្ខុគប្បីបរិភោគដោយប្រាសចាកការប្រកាន់ខ្លួន និងអំនួតអួតអាងយ៉ាងនេះឯង ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនបានបរិភោគដោយមើលងាយថា ប្រយោជន៍អ្វីដោយសាច់ដែលមិនប្រៃ មិនបានអាំង មានក្លិនស្អុយ ដូច្នេះឡើយ គឺបរិភោគដោយប្រាសចាកការមើលងាយ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានបិណ្ឌបាតហើយ មិនគប្បីមើលងាយបិណ្ឌបាតថា ប្រយោជន៍អ្វីដោយភត្តដែលសៅហ្មង មិនមានរស-ជាតិ ដូចជាអាហារសេះ អាហារគោ ចូរយកវាទៅដាក់ក្នុងចានឆ្កែទៅ ហើយក៏មិនមើលងាយទាយកយ៉ាងនេះថា អ្នកណានឹងបរិភោគភត្តនេះបាន ចូរឱ្យដល់ក្អែក និងសុនខជាដើមទៅ ដូច្នេះទេ ។ គប្បីរលឹកដល់ឱវាទនេះថា :

ភិក្ខុបីបាត្រត្រេចទៅ មិនគ ក៏ធ្វើជាគ មិនគប្បីមើលងាយទានដែលតិច និងមិនគប្បីមើលងាយអ្នកឱ្យ ដូច្នេះឯង ។

ពីរនាក់ប្ដីប្រពន្ធនោះ មិនបានមើលងាយគ្នានឹងគ្នាថា ចំណែករបស់អ្នកឯង ចំណែករបស់យើង បុត្ររបស់អ្នកឯង បុត្ររបស់យើង ដូច្នេះឡើយ មានតែការព្រមព្រៀងគ្នាក្នុងការបរិភោគ

យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានបិណ្ឌបាតហើយ មិនគប្បីមើលងាយអ្នកណាៗទេ តួយ៉ាងដូចជាភិក្ខុពួកខ្លះ មើលងាយសព្រហ្មចារី ជាអ្នកមានសីលថា អ្នកណានឹងឱ្យដល់មនុស្ស ដូចជាពួកលោក ពួកលោកជាមនុស្សមិនមានហេតុ ... សូម្បីមាតាដែលជាអ្នកបង្កើតក្បាលលោកមក ក៏មិនសម្គាល់នូវរបស់ដែលគួរនឹងឱ្យដែរ ប៉ុន្តែពួកយើង រមែងបានចីវរជាដើម ដែលប្រណីត ក្នុងទីដែលទៅហើយនោះៗ ដូច្នេះជាដើម ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់ថា ភិក្ខុនោះ មើលងាយ ភិក្ខុដទៃដែលមានសីលជាទីស្រឡាញ់ ដោយលាភសក្ការៈ និងសរសើរនោះ ម្នាលភិក្ខុទាំងឡាយ ហេតុនោះរមែងមានដល់មោឃបុរសនោះ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខរហូតអស់កាលយូរ ។ ដូច្នេះគប្បីជាបុគ្គលព្រមព្រៀងគ្នាក្នុងការបរិភោគ ជាមួយនឹងសព្រហ្មចារីទាំងពួង ។

បទថា **បរិញ្ញាតេ** បានដល់ ការកំណត់ដឹងដោយបរិញ្ញាបីយ៉ាងនេះគឺ ញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ។ តើកំណត់យ៉ាងណា ។ គឺភិក្ខុក្នុងធម្មវិន័យនេះ រមែងដឹងច្បាស់ថា កវឡិង្ការាហារនេះ ជារូបមានឱជា ជាគម្រប់ ៨ (ឱជដ្ឋមករូប ) ដោយអំណាចរូបដែលមានវត្ថុ ។



ឱជដ្ឋមករូប ប៉ះខ្ទប់ក្នុងទីណា។គឺប៉ះខ្ទប់កន្លែងជិវ្ហាបសាទ។ ជិវ្ហាបសាទអាស្រ័យអ្វី ។ អាស្រ័យមហាភូតរូប ៤ ។ រូបមានឱជាជាគម្រប់ ៨ ផង ជិវ្ហាបសាទផង មហាភូតរូប ដែលជាបច្ច័យដល់ជិវ្ហាបសាទផងនោះ ធម៌ទាំងអស់នេះ ឈ្មោះថា រូបក្ខន្ធ ។ កាលភិក្ខុកំណត់រូបក្ខន្ធ ធម៌ដែលមានផស្សៈជាគម្រប់ ៥ (ធម៌ពួក ៥ ក្រុមរបស់ផស្សៈ គឺផស្សៈ វេទនា សញ្ញា ចេតនា ចិត្តំ ) ដែលកើតឡើង ឈ្មោះថា អរូបក្ខន្ធ ៤ ។

ធម៌ទាំងអស់នេះ ឈ្មោះថាខន្ធ ៥ ដោយសង្ខេប គ្រាន់តែជានាមរូប ។ ភិក្ខុនោះ កាលកំណត់នូវធម៌ទាំងនេះ ដោយលក្ខណៈព្រមដោយកិច្ច ហើយស្វែងរកបច្ច័យ របស់ធម៌ទាំងនេះ រមែងឃើញបដិច្ចសមុប្បាទដែលជាអនុលោម ។ ដោយទៅតាមលំដាប់ ត្រឹមតែប៉ុណ្ណេះ គឺភិក្ខុនោះកំណត់ដឹងកវឡិង្ការាហារ ដោយញាតបរិញ្ញា ព្រោះឃើញនាមរូបព្រមដោយបច្ច័យ ដោយមុខគឺកវឡិង្ការាហារ តាមសេចក្តីពិត ។

ភិក្ខុនោះ លើកនាមរូបព្រមដោយបច្ច័យនោះៗឯង ឡើងកាន់ត្រៃលក្ខណ៍ ឃើញថាមិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាឃើញដោយអនុបស្សនា ៧។ ដោយលំដាប់ត្រឹមប៉ុណ្ណេះ គឺជាការកំណត់ដឹងកវឡិង្ការាហារនោះ ពោលគឺញាណជាគ្រឿង

ចាក់ឆ្លុះ និងពិចារណាឃើញត្រៃលក្ខណ៍ ដោយតីរណបរិញ្ញា ។

ក៏កវឡិង្ការាហារនោះ ដែលភិក្ខុកំណត់ដឹងដោយបហាន-បរិញ្ញា ព្រោះកំណត់ដឹងដោយអនាគាមិមគ្គ ដែលកម្ចាត់បង់នូវឆន្ទរាគៈក្នុងនាមរូបនោះឯង ។

បទថា **បញ្ចកាមគុណិកោ** គឺជាការដែលកំណត់ដឹង នូវការកើតឡើងនៃកាមគុណ ៥ ។ តែក្នុងទីនេះ បរិញ្ញា ៣ បានដល់ **ឯកបរិញ្ញា** ១ **សព្វបរិញ្ញា** ១ និង **មូលបរិញ្ញា** ១ ។

សួរថា **ឯកបរិញ្ញា** តើដូចម្តេច ។

ឆ្លើយថា ភិក្ខុណាកំណត់ដឹងនូវតណ្ហាក្នុងរសារម្មណ៍ តែ-ម្យ៉ាងក្នុងជិវ្ហាទ្វារ ភិក្ខុនោះឈ្មោះថា បានកំណត់នូវរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ព្រោះហេតុអ្វី ។ ព្រោះតណ្ហានោះឯង កើតឡើងក្នុងទីនោះ ។ ពិតណាស់ តណ្ហានោះ កើតឡើងក្នុងចក្ខុទ្វារ ឈ្មោះថារូបរាគៈ កើតក្នុងសោតទ្វារជាដើម ក៏ឈ្មោះថាសទ្ទរាគៈជាដើមដែរ ដូចនោះ រាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ គឺភិក្ខុនោះកំណត់ដឹងហើយ ដោយការកំណត់ដឹងរសតណ្ហាក្នុងជិវ្ហាទ្វារ ។ ដូចកាលរាជបុរសចាប់ចោរម្នាក់ ដែលជាអ្នកសម្លាប់មនុស្សក្នុងផ្លូវទាំង ៥ គឺចាប់បានក្នុងផ្លូវណាមួយ ហើយកាត់ក្បាលចោល ។ ដូច្នេះផ្លូវទាំង ៥ រមែងជាផ្លូវរួចផុតចាកភ័យ ។ នេះ



ឈ្មោះថា ឯកបរិញ្ញា ។

សួរថា **សព្វបរិញ្ញា** តើដូចម្តេច ។

ឆ្លើយថា តាមសេចក្តីពិត កាលបិណ្ឌបាតដែលគេដាក់ចុះក្នុងបាត្រ តែម្យ៉ាងប៉ុណ្ណោះ រមែងបាននូវសេចក្តីត្រេកអរ ដែលប្រកបដោយកាមគុណ ៥ ។ គឺមុនដំបូង កាលភិក្ខុនោះសម្លឹងមើលពណ៌ដ៏បរិសុទ្ធ សេចក្តីត្រេកអរក្នុងរូប រមែងមាន ។ កាលដែលស្រោចទឹកដោះថ្លាដែលក្តៅចុះទៅក្នុងទីនោះ សំឡេងលាន់ឡើង ឬក៏សំឡេងនៅពេលទំពាជាដើម កាលត្រេកអរនៅក្នុងសំឡេងនោះ សេចក្តីត្រេកអរក្នុងសំឡេងរមែងកើតឡើង ។ កាលត្រេកអរចំពោះក្លិនដែលគេផ្សំគ្រឿងផ្សេងៗ សេចក្តីត្រេកអរក្នុងក្លិនរមែងកើតឡើង ។ សេចក្តីត្រេកអរក្នុងរស ដោយអំណាចរសដែលល្អ រមែងកើតឡើង ។ កាលត្រេកអរថា ភោជនទន់ល្មើយគួរដល់សម្ផស្ស សេចក្តីត្រេកអរក្នុងផោដ្ឋព្វៈរមែងកើតឡើង ។ ដូច្នោះកាលភិក្ខុកំណត់នូវអាហារ ដោយសតិនិងសម្បជញ្ញៈហើយបរិភោគដោយការបរិភោគដែលប្រាសចាករាគៈ ការបរិភោគទាំងអស់នោះ ឈ្មោះថា ភិក្ខុកំណត់ដឹងហើយ ។ ការកំណត់ដឹងដូចពោលមកនេះ ឈ្មោះថា សព្វបរិញ្ញា ។

សួរថា **មូលបរិញ្ញា** តើដូចម្តេច ។

ការពិត កវឡិង្ការាហារ ជាមូលនៃសេចក្តីត្រេកអរ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ព្រោះហេតុអ្វី ។ ព្រោះកាលកវឡិង្ការាហារនៅមាន សេចក្តីត្រេកអរក្នុងអាហារនោះ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ក៏កើតឡើង ។ បានឮថា ពីរនាក់ភរិយាស្វាមី មិនបានមានចិត្តគិតសម្លឹង ( មើលគ្នាដោយរាគៈ ) រហូត ១២ ឆ្នាំ ព្រោះភ័យកើតពីតិស្សព្រាហ្មណ៍។ ព្រោះហេតុអ្វី ។ ព្រោះហេតុមានអាហារតិច ប៉ុន្តែលុះដល់ភ័យស្ងប់រម្ងាប់ កោះតម្ពបណ្ណិទ្វីប ប្រមាណ ១០០ យោជន៍ បានមាននូវមង្គលជាមួយគ្នា ដោយមង្គលដែលកើតឡើងដល់អ្នកធ្វើ (មានបាយបរិភោគឆ្អែត កើតការសប្បាយ រាគៈប្រាកដឡើង ) ។ ដូច្នោះ កាលកំណត់ដឹងនូវអាហារដែលជាមូលបានហើយ ឈ្មោះថា ភិក្ខុកំណត់ដឹងរាគៈ សេចក្តីត្រេកអរដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ផង ។ ដូចពោលមកនេះ ឈ្មោះថា មូលបរិញ្ញា ។

បទថា **នត្ថិ តំ សំយោជនំ** ដោយសេចក្តីថា សំយោជនៈនោះមិនមាន ព្រោះអរិយសាវក័ លះធម៌ដែលមានទីតាំងជាមួយគ្នានឹងធម៌ដែលគួរលះ ព្រមទាំងរាគៈនោះបាន ។

ព្រះធម៌ទេសនានេះ ព្រះដ៏មានព្រះភាគ ត្រាស់ទុករហូតដល់អនាគាមិមគ្គ ដោយប្រការដូច្នេះ ។ ប៉ុន្តែគួរចម្រើននូវ



វិបស្សនាក្នុងខន្ធ ៥ ដោយអំណាចនៃរូបជាដើម ទាំងអស់នោះឯង ។ ជាបន្តទៅ ព្រះអង្គត្រាស់រហូតដល់ព្រះអរហត្ត ដោយទ្រង់ព្រះតម្រិះថា ភិក្ខុទាំងឡាយកុំគប្បីបានដល់នូវទីបំផុត(នៃគុណធម៌) ត្រឹមតែប៉ុណ្ណេះឡើយ ។

## ការកំណត់ដឹងក្នុងផស្សាហារ

បទថា **និច្ចម្មា** បានដល់ស្បែកដែលត្រូវបកចេញពីសរីរៈទាំងអស់ តាំងតែពីទ្រូង ដល់គល់ស្នែង មានពណ៌ដូចជាគំនរនៃផ្កាចារ ។ សួរថា ព្រោះហេតុអ្វី ឧបមានេះ ទើបព្រះអង្គទ្រង់មិនកាន់យកឧបមា ដោយដំរី សេះ និងគោឈ្មោលជាដើម ព្រះអង្គទ្រង់កាន់យកចំពោះឧបមា ដោយមេគោដែលមិនមានស្បែក ។ ឆ្លើយថា ព្រោះដើម្បីព្រះអង្គទ្រង់សម្តែងនូវភាវៈដែលមិនអាចនឹងអត់ធន់បាន ។ ពិតណាស់ មាតុគ្រាម មិនអាចអត់ធន់ មិនអាចទ្រាំទ្រ ចំពោះទុក្ខវេទនា ដែលកើតឡើងបានឡើយ ។ ដើម្បីព្រះអង្គសម្តែងអំពីផស្សាហារ ដែលមិនមានកម្លាំង ប្រៀបដូចជាការមិនមានកម្លាំងសាច់ដុំភ្លៅរបស់មេគោនោះ ទើបទ្រង់នាំឧបមា ដូច្នេះមក ។

បទថា **កុឍ្ឌំ** បានដល់ជញ្ជាំង មានជញ្ជាំងសិលាជាដើម យ៉ាងណាមួយ ។ ចំពូកសត្វដែលអាស្រ័យនឹងជញ្ជាំង បានដល់ ពីងពាង តឹកកែ និងកណ្តុរជាដើម ។

បទថា **រុក្ខនិស្សិតា** បានដល់សត្វតូចៗ ដែលអាស្រ័យនឹង ដើមឈើនោះ ។

បទថា **ឧទកនិស្សិតា** បានដល់សត្វទឹក មានត្រី និងក្រពើ ជាដើម ។

បទថា **អាកាសនិស្សិតា** បានដល់របោម មូស ក្អែក និង ត្មាតជាដើម ។

បទថា **ខាទេយ្យុំ** បានដល់ ចឹកប្របិច ខាំ ស៊ី ។

មេគោនោះ ពិចារណាឃើញទីនោះៗ ថាជាភ័យ គឺភ័យ ព្រោះការចឹកខាំអំពីសត្វទាំងឡាយ ដែលមានទីជំនុំ អាស្រ័យកាយ ជាមូល មិនបានប្រាថ្នាសក្ការៈ និងការរាប់អានសម្រាប់ខ្លួន ទាំង មិនប្រាថ្នាការគក់ច្របាច់ដល់រូបកាយ និងទឹកក្តៅ (សម្រាប់ឱ្យ ស្រួលខ្លួន ) ។ ភិក្ខុក៏ដូច្នោះដែរ ពិចារណាឃើញភ័យដែលកើត អំពីការខាំទំពានៃសត្វគឺកិលេសដែលមានផស្សាហារជាមូល រមែង មិនមានសេចក្តីត្រូវការដោយផស្សៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឡើយ ។



បទថា **ផស្សេ តិក្ខេទេ អាហារេ បរិញ្ញាតេ** គឺកាល កំណត់ដឹងដោយបញ្ញា ៣ ។ ក្នុងបរិញ្ញា ៣ នោះ ការឃើញ នូវកិច្ចរបស់នាមរូបព្រមទាំងបច្ច័យ តាមសេចក្តីពិតយ៉ាងនេះថា ផស្សៈចាត់ជាសង្ខារក្ខន្ធ វេទនា ដែលសម្បយុត្តជាមួយនឹងផស្សៈ នោះចាត់ជាវេទនាខន្ធ សញ្ញាចាត់ជាសញ្ញាខន្ធ ចិត្តជាវិញ្ញាណក្ខន្ធ អារម្មណ៍ដែលជាវត្ថុនៃខន្ធទាំងនោះ ចាត់ជារូបក្ខន្ធ ឈ្មោះថា **ញាតបរិញ្ញា** ។ ក្នុងបរិញ្ញា ៣ នោះឯង ការដែលភិក្ខុលើកនាមរូប ឡើងកាន់ត្រៃលក្ខណ៍ហើយ ពិចារណាឃើញដោយជារបស់មិន ទៀងជាដើម ដោយអំណាចនៃអនុបស្សនា ៧ ឈ្មោះថា **តីរណ-បរិញ្ញា** ។ ឯព្រះអរហត្តមគ្គ ដែលកម្ចាត់បង់នូវឆន្ទរាគៈក្នុងនាមរូប នោះឯង ឈ្មោះថា **បហានបរិញ្ញា** ។

បទថា **តិស្សោ វេទនា** ដោយសេចក្តីថា កាលកំណត់ដឹង ផស្សាហារ ដោយបរិញ្ញា ៣ យ៉ាងនេះហើយ វេទនា ៣ ក៏រមែង បានកំណត់ដឹងហើយដូចគ្នាដែរ ព្រោះមានផស្សាហារនោះ ជា មូល និងព្រោះសម្បយុត្តដោយផស្សាហារនោះឯង ។ ដោយ ប្រការដូច្នេះឯង ដែលព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា រហូត ដល់ព្រះអរហត្ត ដោយអំណាច ផស្សាហារ ។

## **ការកំណត់ដឹងក្នុងមនោសញ្ចេតនាហារ**

បទថា **អង្គារកាសុ** បានដល់រណ្ដៅរងើកភ្លើង ។ បទថា **កាសុ** លោកពោលសំដៅដល់សេចក្ដីថា កងគំនរ ឬក៏រណ្ដៅ ។ ក្នុងទីនេះ សំដៅយកសេចក្ដីថា រណ្ដៅ ។

បទថា **សាធិកបោរិសា** បានដល់លើសជាងមួយជួរបុរស គឺ ប្រមាណ ៥ ហត្ថ ។

បទថា **វីតច្ចិកានំ វីតធូមានំ** នេះ លោកសម្ដែងថា រណ្ដៅរងើកភ្លើងនោះ មានកម្ដៅខ្លាំងណាស់ (ប្រាសចាកអណ្ដាតភ្លើង ប្រាសចាកផ្សែង) ។

ក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបទៅនឹងឧបមា ដូចតទៅនេះ គឺ

គប្បីឃើញវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចរណ្ដៅរងើកភ្លើង ។ បុថុជ្ជនល្ងង់ខ្លៅ ជាអ្នកអាស្រ័យក្នុងវដ្ដៈ ដូចបុរសដែលប្រាថ្នាការរស់នៅ ។ កុសលកម្ម និងអកុសលកម្ម ដូចបុរស ២ នាក់ ដែលមានកម្លាំងខ្លាំង ។ ពេលដែលបុថុជ្ជនធ្វើកម្ម ដូចពេលដែលបុរសពីរនាក់ ចាប់បុរសនោះ ត្រង់ដើមដៃ ម្ខាងម្នាក់ ទាញមកកាន់រណ្ដៅរងើកភ្លើង ។ ពិតណាស់ កម្មដែលបុថុជ្ជនល្ងង់ខ្លៅបានធ្វើ រមែងទាញទៅរកបដិសន្ធិ ។



វដ្ដទុក្ខ ដែលមានកម្មជាហេតុ គប្បីជ្រាបដូចជាសេចក្ដីទុក្ខដែលមាន (ការទាញទម្លាក់ទៅក្នុង) រណ្ដៅរងើកភ្លើងជាហេតុ ។

បទថា **បរិញ្ញាតេ** គឺការកំណត់ដឹងដោយបរិញ្ញា ៣ ។ ឯការប្រកបសេចក្ដីនៃបរិញ្ញាក្នុងទីនេះ គប្បីជ្រាបតាមន័យ ដែលពោលហើយក្នុងផស្សៈនោះឯង ។

បទថា **តិស្សោ តណ្ហា** បានដល់ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ តណ្ហាទាំងនេះ រមែងបានកំណត់ដឹងហើយដូចគ្នា ព្រោះហេតុអ្វី ព្រោះមនោសញ្ចេតនា មានតណ្ហាជាមូល គឺថា កាលបើលះហេតុនៅមិនទាន់បាន ក៏លះផលមិនបានដែរ ។ ដោយប្រការដូច្នេះឯង ដែលព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា រហូតដល់ព្រះអរហត្ត ដោយអំណាចមនោសញ្ចេតនាហារ ។

## **ការកំណត់ដឹងក្នុងវិញ្ញាណាហារ**

បទថា **អាគុចារឹ** បានដល់អ្នកប្រព្រឹត្តអាក្រក់ គឺជាអ្នកមានទោស ។

ដោយបទថា **កថំ សោ បុរិសោ** ព្រះរាជាត្រាស់សួរថា បុរសនោះដូចម្ដេច ចិញ្ចឹមជីវិតយ៉ាងណាដែរ ។

បទថា **តថេវ ទេវ ជីវតិ** ដោយសេចក្ដីថា សូម្បីឥឡូវ

នេះ គេក៏ចិញ្ចឹមជីវិត (រស់នៅ) ដូចមុននោះឯង ។

ក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបទៅនឹងឧបមា ដូចតទៅនេះ គឺ

ពិតណាស់ កម្មគប្បីឃើញដូចជា ព្រះរាជា ។ បុថុជ្ជនល្ងង់ខ្លៅ ជាអ្នកអាស្រ័យក្នុងវដ្តៈ ដូចបុរសអ្នកប្រព្រឹត្តអាក្រក់ ។ បដិសន្ធិវិញ្ញាណ ដូចលំពែង ៣០០ ដើម ។ ពេលដែលព្រះរាជា គឺកម្មចាប់បុថុជ្ជននោះ បោះទៅក្នុងបដិសន្ធិ ដូចពេលដែលព្រះរាជាចាប់បុរសអ្នកប្រព្រឹត្តអាក្រក់ ត្រាស់បង្គាប់ថា ចូរប្រហារដោយលំពែង ៣០០ ដើម ។ ក្នុងឧបមានេះ បដិសន្ធិវិញ្ញាណប្រៀបដូចលំពែង ៣០០ ដើម ។ សេចក្តីទុក្ខរបស់អ្នកទោសនោះ ដែលកើតឡើងព្រោះ មុខរបួសដែលត្រូវនឹងលំពែង សូម្បីតែមុខរបួសមួយក៏រកប្រមាណមិនបានទៅហើយ ចាំបាច់ពោលថ្វី ដល់ទៅទុក្ខដែលកើតឡើង ព្រោះ មុខរបួសទាំង ៣០០ នោះ ។

បណ្តាហេតុការណ៍ទាំងនោះ បដិសន្ធិដូចគ្នានឹងពេលដែលលំពែងធ្លាក់ត្រូវ ។ ការកើតឡើងនៃខន្ធ ដូចគ្នានឹងការកើតមាននូវមុខរបួស ។ ការកើតឡើងនៃទុក្ខផ្សេងៗ គ្រប់បែបយ៉ាង ដែលមានវដ្តៈជាមូល មានក្នុងខន្ធទាំងឡាយដែលកើតហើយ ដូចជាការកើតឡើងនៃទុក្ខវេទនាក្នុងរបួសទាំងឡាយនោះ ។



ព្រោះហេតុនោះ ភិក្ខុណា ឃើញវិញ្ញាណាហារ ដូចគ្នានឹងការចាក់ដោយលំពែង ៣០០ ដើមយ៉ាងនេះ ភិក្ខុនោះ នឹងគ្រប់សង្កត់នូវសេចក្តីត្រេកអរក្នុងវិញ្ញាណាហារបាន [១] ។

បទថា **បរិញ្ញាតេ** គឺការកំណត់ដឹងដោយបរិញ្ញា ៣ ។ ក្នុងទីនេះគប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងផស្សាហារនោះឯង ។

បទថា **នាមរូបំ** ដោយសេចក្តីថា ព្រោះមានវិញ្ញាណជាបច្ច័យ ទើបកើតមាននាមរូប ។ កាលកំណត់ដឹងនូវវិញ្ញាណ រមែងជាការកំណត់ដឹងនូវនាមរូបនោះដូចគ្នាដែរ ព្រោះនាមរូបមានវិញ្ញាណជាបច្ច័យ និងព្រោះកើតព្រមគ្នា ។ ដោយប្រការដូច្នេះឯង ដែលព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា រហូតដល់ព្រះអរហត្តដោយអំណាចវិញ្ញាណាហារ ។

ព្រះពុទ្ធប្រៀបដូចជាមហាមេឃ ដែលឱ្យនូវភ្លៀង ព្រះធម៌ប្រៀបដូជាទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់នូវល្អងកិលេស ប្រៀប ដូចជាជនបទ ដែលរម្ងាប់នូវល្អងធូលី ព្រោះភ្លៀងធ្លាក់

១-អធិប្បាយអំពីឧបមានៃវិញ្ញាណាហារក្នុងទីនេះ យកអំពីអដ្ឋកថា សម្មាទិដ្ឋិសូត្រ ។

# ទ្វយតានុបស្សនាសូត្រ

( បិដកលេខ ៥៤ , ទំព័រ ២៤៦-២៦៣ )

ពួកជនណា មិនដឹងច្បាស់នូវទុក្ខ ទាំងនូវហេតុនាំឱ្យកើតទុក្ខ នូវព្រះនិព្វានជាទីរំលត់ទុក្ខ មិនសេសសល់ដោយសព្វគ្រប់ ទាំងមិនដឹងនូវផ្លូវ ទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះ សាបសូន្យហើយចាកចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកជននោះ មិនគួរដើម្បីនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ ចូលទៅកាន់ជាតិ និងជរាតែម្យ៉ាង ។ ពួកជនណា ដឹងច្បាស់នូវទុក្ខ នូវហេតុនាំឱ្យកើតទុក្ខ នូវព្រះនិព្វាន ជាទីរំលត់ទុក្ខ ឥតសេសសល់ដោយសព្វគ្រប់ ទាំងដឹងច្បាស់នូវផ្លូវដែលទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះ បរិបូណ៌ដោយចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកជននោះ ទើបគួរនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ មិនចូលទៅកាន់ជាតិ និងជរាឡើយ ។

ទុក្ខទាំងឡាយ រមែងកើតឡើង ព្រោះមានឧបធិ ( កម្ម ) ជាបច្ច័យ ពួកសត្វណានីមួយក្នុងលោក មានរូបច្រើនប្រការ (រមែងទទួលនូវទុក្ខនោះ ) បុគ្គលពាលណា មិនស្គាល់ច្បាស់ហើយធ្វើនូវឧបធិ បុគ្គលពាល (នោះ) តែងបាននូវទុក្ខរឿយៗ ព្រោះ



ហេតុនោះ អ្នកប្រាជ្ញពិចារណាឃើញនូវឧបធិ ជាហេតុឱ្យកើតទុក្ខ កាលស្គាល់ច្បាស់ មិនគប្បីធ្វើនូវឧបធិឡើយ ។

ពួកសត្វ រមែងទៅកាន់ជាតិមរណៈ និងការអន្ទោលទៅក្នុងភពថ្មីរឿយៗ (ដោយអវិជ្ជាគតិណា ) អវិជ្ជាគតិនោះ មិនដឹងនូវសភាព ជាមនុស្សនេះផង និងភាពនៃនិកាយដទៃផង ។ ការអន្ទោលទៅ (ក្នុងភព ) អស់កាលដ៏វែងនេះ ក៏ព្រោះតែអវិជ្ជា គឺមោហៈធំនេះឯង ពួកសត្វណាដែលមានវិជ្ជាគតិ ពួកសត្វនោះ រមែងមិនទៅកាន់ភពថ្មីទៀតឡើយ ។

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះសង្ខារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ទៅនៃសង្ខារទាំងឡាយ។ អ្នកប្រាជ្ញជ្រាបនូវទោសនោះថា ទុក្ខកើតឡើង ព្រោះសង្ខារជាបច្ច័យ ព្រោះរម្ងាប់នូវសង្ខារទាំងពួង ព្រោះរំលត់ទៅនៃកាមសញ្ញាជាដើមបាន ព្រោះជ្រាបនូវកងទុក្ខនោះតាមពិត ។ បណ្ឌិតទាំងឡាយ អ្នកដល់នូវវេទ ឃើញដោយប្រពៃ ជ្រាបដោយប្រពៃ គ្របសង្កត់នូវមារសំយោគ គឺវដ្តៈក្នុងភូមិទាំង ៣ ហើយ រមែងមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ

ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់វិញ្ញាណ ។ អ្នកប្រាជ្ញដឹងនូវទោសនេះថា ទុក្ខ (កើតឡើង ) ព្រោះវិញ្ញាណជាបច្ច័យ ភិក្ខុមិនមានតណ្ហា បានបរិនិព្វាន ព្រោះរម្ងាប់នូវវិញ្ញាណ ។

ការអស់សំយោជនៈ រមែងនៅឆ្ងាយអំពីពួកជនទាំងនោះ ដែលមានផស្សៈគ្របសង្កត់ហើយប្រព្រឹត្តតាមខ្សែតណ្ហាក្នុងភព ជាអ្នកប្រតិបត្តិតាមផ្លូវខុស។ពួកជនណាកំណត់ដឹងនូវផស្សៈ ត្រេកអរក្នុងព្រះនិព្វានជាទីរម្ងាប់ (សង្ខារទាំងពួង ) ដោយបញ្ញា ពួកជននោះ មិនមានតណ្ហា រមែងបរិនិព្វាន ព្រោះរំលត់បង់នូវផស្សៈ ។

អ្នកប្រាជ្ញជ្រាបថា ធម្មជាតនីមួយ ទោះបីជាសុខ ឬជាទុក្ខព្រមទាំងមិនទុក្ខមិនសុខ ដែលមានខាងក្នុងក្តី ខាងក្រៅក្តី ដែលសត្វទទួលហើយ ធម្មជាតនោះសុទ្ធតែជាទុក្ខ មានសេចក្តីវិនាសនិងសេចក្តីទ្រុឌទ្រោមទៅជាធម្មតា ។ បានពាល់ត្រូវ (ដោយឧទយព្វយញ្ញាណ ) ឃើញនូវការសូន្យទៅ ដឹងច្បាស់វេទនានោះដោយប្រការដូច្នេះ ។ ការកើតឡើងនៃទុក្ខមិនមាន ព្រោះអស់ទៅនៃវេទនាទាំងឡាយ ។

បុរសដែលមានតណ្ហាជាគម្រប់ពីរ ( និងខ្លួន ) រមែងអន្ទោលទៅកាន់អត្តភាពនេះ និងអត្តភាពដទៃ អស់កាលយូរអង្វែង មិនងាយនឹងប្រព្រឹត្តកន្លងសង្សារបានឡើយ ។ ភិក្ខុលុះដឹងទោស



នៃតណ្ហានោះដ៏ជាហេតុឱ្យកើតទុក្ខ គប្បីជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ មានសតិវៀរចេញ(ចាកតណ្ហាឧបាទាន )។

ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ សត្វដែលកើតហើយ រមែងបាននូវទុក្ខ មរណៈក៏កើតមានដល់សត្វដែលកើតហើយដែរ នេះជាសភាវៈ កើតឡើងព្រមនៃទុក្ខ ។ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ មិនត្រឡប់មកកាន់ភពថ្មីវិញទៀត ព្រោះអស់ឧបាទាន ព្រោះដឹងត្រូវ ព្រោះជ្រាបច្បាស់នូវព្រះនិព្វានជាទីអស់ទៅនៃជាតិ ។

ទុក្ខនីមួយ ទាំងអស់ តែងកើតឡើង ព្រោះព្យាយាម (ប្រកបជាមួយកម្ម ) ជាបច្ច័យ ការមិនកើតឡើងនៃទុក្ខ ព្រោះរលត់នូវព្យាយាម ។ អ្នកប្រាជ្ញជ្រាបនូវទោសនោះថា ទុក្ខកើតឡើង ព្រោះព្យាយាមជាបច្ច័យ ហើយក៏លះចោលនូវព្យាយាមទាំងពួងចេញ កាលភិក្ខុជឿស៊ប់ក្នុងព្រះនិព្វានជាដែនមិនមានព្យាយាម បានផ្តាច់-ផ្តិលនូវតណ្ហាក្នុងភព មានចិត្តស្ងប់រម្ងាប់ហើយ ការអន្ទោលទៅកាន់ជាតិក៏អស់រលីង ភិក្ខុនោះមិនមានភពថ្មីទៀតឡើយ ។

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះអាហារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់អាហារ ។ អ្នកប្រាជ្ញលុះជ្រាបនូវទោសនោះថា ទុក្ខ (កើតឡើង ) ព្រោះអាហារ

ជាបច្ច័យ ហើយមិនអាស្រ័យនូវអាហារទាំងពួងដោយតណ្ហា ព្រោះកំណត់ដឹងនូវអាហារទាំងពួង ជាអ្នកពិចារណាហើយទើបសេព (បច្ច័យ ៤ ) តាំងនៅក្នុងសច្ចធម៌ មិនដល់នូវការរាប់ (ថាជាមនុស្ស ឬទេវតា ) ព្រោះជ្រាបច្បាស់ដោយប្រពៃ នូវព្រះនិព្វានជាដែនមិនមានរោគ ព្រោះអស់នូវអាសវៈទាំងឡាយ ។

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះសេចក្ដីញាប់ញ័រ (តណ្ហា មានះ ទិដ្ឋិ កម្ម និងកិលេស ) ជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់នូវសេចក្ដីញាប់ញ័រ ។ ភិក្ខុដឹងនូវទោសនោះថា ទុក្ខ (កើតឡើង ) ព្រោះសេចក្ដីញាប់ញ័រជាបច្ច័យ ព្រោះហេតុនោះ ភិក្ខុគប្បីលះបង់តណ្ហា រំលត់សង្ខារទាំងឡាយ ជាអ្នកមិនមានតណ្ហា មិនមានឧបាទាន វៀរស្រឡះចាកសេចក្ដីញាប់ញ័រ ។

បុគ្គលមិនអាស្រ័យ (តណ្ហាមានះទិដ្ឋិ) រមែងមិនរន្ធត់ បុគ្គលអ្នកអាស្រ័យនូវការប្រកាន់ រមែងមិនប្រព្រឹត្តកន្លងនូវការអន្ទោលទៅកាន់អត្តភាពនេះ និងអត្តភាពដទៃ ។ ភិក្ខុដឹងនូវទោសនោះថាជាភ័យធំ ព្រោះការអាស្រ័យ (តណ្ហាមានះទិដ្ឋិ ) គប្បីជាបុគ្គលមិនអាស្រ័យ(តណ្ហាមានះទិដ្ឋិ) មិនមានឧបាទាន មានសតិវៀរស្រឡះ។

ពួកសត្វណា តាំងនៅក្នុងរូបភពក្ដី ពួកសត្វណា តាំងនៅក្នុងអរូបភពក្ដីពួកសត្វទាំងនោះ កាលមិនស្គាល់ច្បាស់នូវព្រះនិព្វាន



ក៏ជាអ្នកត្រឡប់មក កាន់ភពថ្មីទៀត ចំណែក ពួកជនណាកំណត់ដឹងក្នុងរូប មិនឋិតនៅក្នុងរូប មានចិត្តចុះស៊ប់ក្នុងព្រះនិព្វាន ជនទាំងនោះឈ្មោះថា មានមច្ចុសាបសូន្យហើយ ។

អ្នកចូរមើលនូវលោក ព្រមទាំងទេវលោក ដែលតាំងនៅក្នុងនាម និងរូប បុគ្គលមានសេចក្ដីសម្គាល់ថា ខ្លួនក្នុងរបស់ដែលមិនមែនខ្លួន តែងសម្គាល់ថា នេះពិត ។ ពួកសត្វតែងសម្គាល់ដោយរូបជាដើមណាៗថា (រូបរបស់អញ វេទនារបស់អញ ) នាមនិងរូបនោះ ទៅជារបស់ដទៃអំពីការសម្គាល់នោះ ព្រោះនាម និងរូបនោះរបស់សត្វនោះ ជារបស់មិនពិត ជាធម៌សោះសូន្យទទេ ។ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះ ដែលជាធម៌មិនសោះសូន្យដោយពិត ទើបព្រះអរិយៈទាំងនោះ មិនមានតណ្ហាបានដល់ព្រះនិព្វាន ព្រោះបានត្រាស់ដឹងនូវធម៌ពិត ។

រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ទាំងអស់ ជាទីប្រាថ្នា ជាទីស្រឡាញ់ និងជាទីពេញចិត្ត លោកពោលថាមាននៅដរាបណា អារម្មណ៍ទាំងនោះ សត្វលោក ព្រមទាំងទេវលោកសន្មតថាជាសុខ (ដរាបនោះ ) អារម្មណ៍ទាំងនោះតែងរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។ ការរលត់នូវសក្កាយ គឺខន្ធទាំង ៥ ព្រះអរិយៈ

ទាំងឡាយ ឃើញថាជាសុខពិត ការឃើញ (របស់ព្រះអរិយៈ) អ្នកយល់នេះ ជាទំនាស់នឹងសត្វលោកទាំងពួង ។ ពួកជនពាលដទៃពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះថាជាទុក្ខ ពួកជនពាលដទៃ ពោលនូវព្រះនិព្វានណាថាជាទុក្ខ ព្រះអរិយៈទាំងឡាយដឹងច្បាស់នូវព្រះនិព្វាននោះថាជាសុខ អ្នកចូរឃើញនូវនិព្វានធម៌ ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹងវង្វេងហើយក្នុងធម៌នោះ ។ សេចក្តីងងឹតធ្វើនូវភាពខ្វាក់ តែងប្រាកដដល់ពួកជនពាល ដែលអវិជ្ជាបិទបាំង មិនឃើញនូវព្រះ-និព្វាន ឯព្រះនិព្វានដូចជាពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌គឺព្រះនិព្វាន រមែងមិនដឹងច្បាស់ (នូវព្រះនិព្វាន សូម្បីមាន ) ក្នុងទីជិតឡើយ ។ ព្រះ-និព្វាននេះ ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅ តាមខ្សែក្នុងភព កើតហើយក្នុងកន្លែងរបស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ។ នរណាហ្ន៎ វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន ព្រះអរហន្តទាំងឡាយមិនមានអាសវធម៌ បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃនូវព្រះនិព្វាន ។



# អាសីវិសូបមសូត្រ

(បិដកលេខ ៣៥ , ទំព័រ ៣៩៤-៤០០ )

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏-មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ដូចជាអាសីរពិស ៤ ពួក មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក ។ កាលណោះ មានបុរសចង់រស់ មិនចង់ស្លាប់ ប្រាថ្នាសុខខ្ពើមទុក្ខ ដើរមក ពួកជនដទៃគប្បីនិយាយនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អាសីរពិស ទាំង ៤ ពួកនេះ មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក អ្នកត្រូវឱ្យក្រោកឡើងតាមកាលដ៏គួរ ត្រូវឱ្យងូតទឹកតាមកាលដ៏គួរ ត្រូវឱ្យបរិភោគតាមកាលដ៏គួរ ត្រូវឱ្យចូលទៅដេកតាមកាលដ៏គួរ ។ ម្នាលបុរសដ៏ចម្រើន បណ្តាអាសីរពិសទាំង ៤ ពួក មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹកទាំងនោះ អាសីរ-ពិសណាៗក៏ដោយ នឹងខឹងដល់អ្នក ក្នុងកាលណា ម្នាលបុរសដ៏ចម្រើន ក្នុងកាលណោះ អ្នកនឹងដល់នូវសេចក្តីស្លាប់ ឬទុក្ខវេទនាស្មើរនឹងស្លាប់ ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរ

អ្នកធ្វើកិច្ចនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង បុរសនោះមានសេចក្ដីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក ហើយក៏រត់គេចទៅក្នុងទីដទៃ ពួកជនដទៃគប្បីនិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះជាពេជ្ឈឃាតទាំង ៥ ជាសត្រូវដេញតាមពីខាងក្រោយខ្នង១ អ្នក ដោយគិតគ្នាថា យើងទាំងឡាយឃើញបុរសនោះ ក្នុងទីណា នឹងផ្ដាច់ជីវិត ក្នុងទីនោះឯង ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមានសេចក្ដីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក មានសេចក្ដីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ ហើយក៏រត់គេចទៅក្នុងទីដទៃ ពួកជនដទៃគប្បីនិយាយនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះជាពេជ្ឈ-ឃាត អ្នកចាំស្ពាត់ខាងក្នុងជាគម្រប់ ៦ មានដាវងាឡើង ដេញតាមពីខាងក្រោយខ្នង១អ្នក ដោយគិតថា អញឃើញបុរសនោះក្នុងទីណា នឹងកាត់ក្បាលក្នុងទីនោះឯង ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។



ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ បុរសនោះមានសេចក្ដីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក មានសេចក្ដីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ មានសេចក្ដីភិតភ័យនឹងពេជ្ឈឃាតអ្នកចាំស្ពាត់ខាងក្នុងជាគម្រប់ ៦ មានដាវងាឡើង ហើយក៏រត់គេចទៅក្នុងទីដទៃ បុរសនោះឃើញស្រុកដ៏ស្ងាត់ ក៏ចូលទៅរកផ្ទះណាមួយ ផ្ទះនោះក៏ទទេស្អាតស្ងាត់សូន្យសុង លូករាវរកភាជន៍ណាមួយ ភាជន៍នោះក៏ទទេស្អាតរលីងសោះសូន្យដែរ ។ ពួកជនដទៃគប្បីនិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ឥឡូវនេះ ពួកចោរ ធ្លាប់សម្លាប់អ្នកស្រុក តែងចូលមករកស្រុកស្ងាត់នេះ ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកគួរធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមានសេចក្ដីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក មានសេចក្ដីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ មានសេចក្ដីភិតភ័យនឹងពេជ្ឈឃាតអ្នកចាំស្ពាត់ខាងក្នុងជាគម្រប់ ៦ ដែលមានដាវងាឡើង មានសេចក្ដីភិតភ័យនឹងពួកចោរជាអ្នកសម្លាប់អ្នកស្រុក ហើយក៏រត់គេចទៅក្នុងទីដទៃ បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយ ប្រកបដោយ

សេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ មានត្រើយខាងនាយដ៏ក្សេម ឥតមានភ័យចំពោះមុខ ទូក ក្បូន ស្ពានឆ្លង ដើម្បីឆ្លងអំពីត្រើយអាយទៅត្រើយខាងនាយ ក៏មិនមានសោះ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងហើយជាអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយ ប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ មានត្រើយខាងនាយដ៏ក្សេម ឥតមានភ័យចំពោះមុខ ទូក ក្បូន ស្ពានឆ្លង ដើម្បីឆ្លងអំពីត្រើយអាយទៅត្រើយខាងនាយក៏មិនមាន បើដូច្នោះ មានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើមែកឈើ ស្លឹកឈើ ចងជាក្បូន អាស្រ័យក្បូននោះហើយ អុំដោយដៃនិងជើងទាំងឡាយ ទើបដល់ទៅត្រើយដោយសួស្តីបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង បុរសនោះប្រមូលស្មៅ កំណាត់ឈើមែកឈើ ស្លឹកឈើ មកចងជាក្បូន អាស្រ័យក្បូននោះហើយ អុំដោយដៃនិងជើងទាំងឡាយ ទើបដល់ទៅត្រើយ ដោយសួស្តី បានឈ្មោះថាជាព្រាហ្មណ៍ឆ្លងដល់ត្រើយ ហើយឋិតនៅលើគោក ។

ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើសេចក្តីឧបមានេះ ដើម្បីបញ្ជាក់នូវសេចក្តីអធិប្បាយ ឯសេចក្តីអធិប្បាយ ក្នុងសេចក្តីឧបមានោះដូច្នេះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាសីរពិស ៤ ពួក ដែល



មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹកនោះ ជាឈ្មោះនៃមហាភូតរូបទាំង ៤ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោ-ធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថាពេជ្ឈឃាតទាំង ៥ ជាសត្រូវនោះ ជាឈ្មោះនៃឧបាទានក្ខន្ធទាំង ៥ ។ គឺអ្វីខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយពាក្យថា ពេជ្ឈឃាតអ្នកចាំស្កាត់ខាងក្នុងជាគម្រប់ ៦ ដែលមានដាវងាឡើងនោះ ជាឈ្មោះនៃនន្ទិរាគ ។ ម្នាលភិក្ខុទាំងឡាយពាក្យថា ស្រុកស្ងាត់នោះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។

ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃ មានប្រាជ្ញាកំណត់នូវអាយតនៈខាងក្នុង ៦ នោះ ចក្ខុនោះប្រាកដជារបស់ទទេប្រាកដជារបស់រលីងធេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃ មានប្រាជ្ញា កំណត់នូវអាយតនៈខាងក្នុង ៦ នោះ សោតៈនោះ ប្រាកដជារបស់ទទេប្រាកដជារបស់រលីងធេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃ មានប្រាជ្ញា កំណត់នូវអាយតនៈខាងក្នុង ៦ នោះ ឃានៈនោះប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងធេង ប្រាកដជារបស់សូន្យសោះ ។

ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃ មានប្រាជ្ញា កំណត់នូវអាយតនៈខាងក្នុង៦នោះ ជិវ្ហា កាយ មនោនោះប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងធេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពួកចោរអ្នកសម្លាប់អ្នកស្រុកនោះ ជាឈ្មោះ នៃអាយតនៈខាងក្រៅ ៦ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុរមែងបៀតបៀនដោយរូបទាំងឡាយ ជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ សោតៈ ។ល។ ម្នាលភិក្ខុទាំង-ឡាយ ឃានៈ ។ល។ ម្នាលភិក្ខុទាំងឡាយ ជិវ្ហារមែងបៀតបៀនដោយ រសទាំងឡាយ ជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាយ ។ល។ ម្នាលភិក្ខុទាំងឡាយ មនោរមែងបៀតបៀនដោយធម្មារម្មណ៍ទាំងឡាយ ជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អន្លង់ទឹកធំនោះ ជាឈ្មោះនៃឱឃៈទាំង ៤ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ត្រើយអាយប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខនោះ ជាឈ្មោះនៃសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ត្រើយនាយដ៏ក្សេមឥតមានភ័យចំពោះមុខនោះ ជាឈ្មោះនៃព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ក្បូននោះ ជាឈ្មោះនៃមគ្គមានអង្គ ៨ ដ៏



ប្រសើរ ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អុំដោយដៃនិងជើងទាំងឡាយនោះ ជាឈ្មោះនៃការប្រារព្ធសេចក្តីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ឆ្លងដល់ត្រើយ ឋិតនៅលើគោកនោះ ជាឈ្មោះនៃព្រះអរហន្ត ។

ប្រារព្ធអនាថបិណ្ឌិកសេដ្ឋីនាំទេវតាចូលគាល់ព្រះសម្មាសម្ពុទ្ធ

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ(បាបោ)បាបានិ បស្សតិ ។**
**ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ(ភទ្រោ)ភទ្រានិ បស្សតិ ។**

បាប មិនទាន់ឱ្យផលត្រឹមណា មនុស្សធ្វើបាប ក៏នៅឃើញ តែសេចក្តីចម្រើនត្រឹមនោះ (ឃើញបាបថាល្អ) លុះកាលណាបាបឱ្យផល មនុស្សធ្វើបាបទើបឃើញបាបថាអាក្រក់ក្នុងកាលនោះ ។ អំពើល្អ មិនទាន់ឱ្យផលត្រឹមណា មនុស្សធ្វើល្អ នៅឃើញតែបាបត្រឹមនោះ (ឃើញអំពើល្អថាអាក្រក់) លុះកាលណាអំពើល្អឱ្យផល មនុស្សធ្វើល្អ ទើបឃើញអំពើល្អថាល្អ ក្នុងកាលនោះ ។

# ធម៌គួរយល់ដឹង

១.គ្រប់ទីកន្លែង គ្រប់ពេលវេលា លោកនេះ មានតែ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ តែប៉ុណ្ណោះ ។

២.ចិត្តគិត បានសាងប្រឌិតនូវលោក និងសាងគ្រប់រឿង-រ៉ាវទាំងអស់ ដូចក្នុងសុបិន ។

៣.រូបារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈឃើញ ។ សទ្ទារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈឮ ។ គន្ធារម្មណ៍ ជាលោកនៃការរស់នៅក្នុងខណៈដឹងក្លិន ។ រសារម្មណ៍ជាលោកនៃការរស់នៅក្នុងខណៈដឹងរស ។ ផោដ្ឋព្វារម្មណ៍ ជាលោកនៃការរស់នៅ ក្នុងខណៈដឹង ផោដ្ឋព្វៈ ។ ធម្មារម្មណ៍ ជាលោកនៃការរស់នៅ ក្នុងខណៈដឹងធម្មារម្មណ៍នោះឯង ។



៤.អ្វីៗគ្រប់យ៉ាង ជាអារម្មណ៍របស់ចិត្ត ។ ចិត្តកើតឡើង ចិត្តរស់នៅ ចិត្តបែកធ្លាយ ។ ការរស់នៅជាប្រក្រតី គឺចិត្តដឹងអារម្មណ៍ បុគ្គលអ្នករស់នៅដទៃផ្សេងទៀតក្រៅពីចិត្តដឹងអារម្មណ៍ កើតហើយរលត់ទៅ មិនមានទេ ។

៥.រូបជាធាតុមិនដឹង ដូចសាកសព ។ ចិត្តបច្ចុប្បន្នកំពុងដឹងអារម្មណ៍ មិនមែនជាចិត្តមកពីអតីតទេ ចិត្តដឹងអារម្មណ៍ហើយក៏រលត់បាត់ទៅ មិនមានឋិតនៅក្នុងទីណាឡើយ ។

៦.អ្វីៗក៏ល្មមសម្រាប់ចិត្តជាបច្ចុប្បន្ននេះដែរ ។ អ្វីៗដែលជាអារម្មណ៍របស់ចិត្តគឺស្មើគ្នាទាំងអស់សម្រាប់ចិត្តដឹង ។ អារម្មណ៍អ្វីក៏បាន ល្មមគ្រប់គ្រាន់សម្រាប់ចិត្តដែលកំពុងដឹងក្នុងខណៈនោះ មិនទាមទារ មិនត្រូវការចំពោះអារម្មណ៍ដទៃ ស្ងប់តណ្ហា មិនមានកង្វល់នឹងខ្លួនឯងថាត្រូវបានអ្វី ។

៧.ជីវិតរស់នៅ មានតែចិត្តដឹងអារម្មណ៍ និងអារម្មណ៍របស់ចិត្ត តៗគ្នា ។ នេះជាការកើតឡើងនៃសង្ខារធម៌សុទ្ធ និងជាគំណនៃសង្ខារធម៌សុទ្ធនោះ ។

៨.ខន្ធទាំងឡាយកើត ខន្ធទាំងឡាយរលត់ មិនមានអ្វីដទៃទៀតកើតរលត់ឡើយ ។

៩.ព្រោះខន្ធទាំងឡាយបែកធ្លាយ ទើបមានពាក្យហៅថាស្លាប់ ។ មិនមានអ្នកស្លាប់ផ្សេងពីខន្ធដែលបែកធ្លាយទៀតទេ ។

១០.ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលឃើញរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលជារបស់មិនទៀង ថាមិនទៀង ការឃើញរបស់បុគ្គលនោះ ជាសម្មាទិដ្ឋិ ។ កាលដែលបុគ្គលបានឃើញត្រូវដូច្នេះ ក៏រមែងនឿយណាយ ... ។

១១.ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលឃើញចក្ខុ សោត ឃាន ជិវ្ហា កាយ មនោ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលជារបស់មិនទៀង ថាមិនទៀង ការឃើញរបស់បុគ្គលនោះ ជាសម្មាទិដ្ឋិ ។

១២.កាលបើមានខន្ធ (រូបក្ខន្ធជាដើម ) សេចក្ដីស្លាប់ក្ដី សត្វដែលត្រូវគេសម្លាប់ក្ដី ក៏មានដែរ ឬសត្វណាតែងស្លាប់ សត្វនោះក៏មានដែរ ។

១៣.ព្រះអង្គទ្រង់ត្រាស់ថា អ្នកចូរឃើញខន្ធ ៥ ថាជាមារ ឃើញថា ជាសត្វដែលត្រូវគេសម្លាប់ ឃើញថា រមែងស្លាប់ ឃើញថាជារោគ ឃើញថាជាបូស ឃើញថាជាសរ ឃើញថាជាទុក្ខ ឃើញថាជារបស់មានទុក្ខ។ ពួកជនណាឃើញនូវខន្ធ ៥ យ៉ាងនេះ ពួកជននោះ ឈ្មោះថា ឃើញដោយល្អប្រពៃ ។ ការឃើញដោយល្អប្រពៃ មានប្រយោជន៍ឱ្យកើតសេចក្ដីនឿយណាយ ។ សេចក្ដីនឿយណាយ មានប្រយោជន៍ឱ្យកើតការប្រាសចាកតម្រេក ។ ការប្រាសចាកតម្រេក មានប្រយោជន៍ឱ្យកើតការផុតស្រឡះ ។ ការផុតស្រឡះមានប្រយោជន៍ឱ្យបានព្រះនិព្វាន ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានព្រះនិព្វានជាទីតាំង មានព្រះនិព្វានជាបរិយោសាន ។

១៤.ព្រះអង្គទ្រង់ត្រាស់ថា ដូចពួកកុមារក្ដី ពួកកុមារីក្ដី នាំគ្នាលេងកូនផ្ទះដែលធ្វើពីអាចម៍ដី កាលមិនទាន់ប្រាសចាកសេចក្ដីត្រេកអរ មិនទាន់ប្រាសចាកសេចក្ដីពេញចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់

ប្រាសចាកសេចក្ដីឆ្អែតឆ្អា មិនទាន់ប្រាសចាកសេចក្ដីប្រាថ្នា ក្នុងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ កំណត់ត្រឹមណា ពួកគេតែងអាល័យ តែងប្រកាន់លេង តែងប្រកាន់ថាជាទ្រព្យ ប្រកាន់ថាជារបស់ខ្លួន ចំពោះកូនផ្ទះធ្វើពីអាចម៍ដី កំណត់ត្រឹមនោះ ។ កាលណាបើពួកកុមារក្ដី ពួកកុមារីក្ដី លែងត្រេកអរ លែងពេញចិត្ត លែងស្រឡាញ់ លែងស្រេកឃ្លាន លែងឆ្អែតឆ្អា លែងប្រាថ្នា ក្នុងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះហើយ យកដៃនិងជើងទៅកម្ចាយចោល ឈូសចោល កម្ចាត់ចោល នូវកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ ធ្វើឱ្យជារបស់លេងមិនកើត ក្នុងកាលនោះ ។ យ៉ាងណាមិញ អ្នកទាំងឡាយ ចូរកម្ចាយចោល ឈូសចោល កម្ចាត់ចោល នូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីការអស់ទៅនៃតណ្ហា យ៉ាងនោះឯង ។ **តណ្ហក្ខយោ ហិ រាធ និព្វានន្តិ** ម្នាលរាធៈ ព្រោះថា ការអស់ទៅនៃតណ្ហា ឈ្មោះថាព្រះនិព្វាន ។

១៥.វិបស្សនា មិនប្រព្រឹត្តទៅដើម្បីបាន ចិត្ត ចេតសិក រូប ណាមួយនោះទេ ។ បើមិនចាប់យកធម៌ជាបច្ចុប្បន្នមកប្រកាន់ថាជាតួខ្លួនហើយនោះ ក៏មិនចាំបាច់ខ្វល់រកអ្វីមកឱ្យខ្លួនឯងដែរ មាន



តែការកំណត់ដឹងនូវទុក្ខ គឺនាមរូបដែលកើតរលត់ប៉ុណ្ណោះ ។

១៦.កាលមុនខំរកទ្រព្យសម្បត្តិ មាសប្រាក់ ផ្ទះសំបែង។ល។ ឥឡូវខំរកធម៌ ... ។ កាលមុន និងឥឡូវ គឺដើម្បីឱ្យខ្លួនឯងជាអ្នកបាន ជាអ្នកសម្រេច ដូចតែគ្នា ។ ប៉ុន្តែ បញ្ញាកំណត់ដឹងខន្ធជាបច្ចុប្បន្ន ទើបមិនមានត្រូវការអ្វីឱ្យខ្លួនឯងឡើយ នេះទើបជាលក្ខណៈនៃការឃើញធម៌ពិត១ ។

១៧.ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្លឹងឃើញលោកដោយសភាពជារបស់សូន្យ ព្រោះបុគ្គលដកអត្តានុទិដ្ឋិចេញដូច្នេះ ទើបឆ្លងផុតចាកមច្ចុ ។ បុគ្គលសម្លឹងឃើញលោកយ៉ាងនេះឯង មច្ចុរាជទើបមើលមិនឃើញ ។

១៨.ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគាមិណិ កាលបុគ្គលឃើញតាមពិត នូវការកើតឡើងនៃធម៌ដ៏បរិសុទ្ធ[១] និងការជាប់តគ្នានៃសង្ខារធម៌សុទ្ធ[២] នោះ ភ័យនោះ រមែងមិនមាន ។

---

១-២-បរិសុទ្ធ សុទ្ធ គឺមិនមានសត្វបុគ្គលលាយឡំ ។

១៩.ព្រះអង្គទ្រង់ត្រាស់ជាបន្តថា ក្នុងកាលណា បុគ្គលឃើញលោកទុកស្មើនឹងស្មៅ ឬកំណាត់ឈើដោយប្រាជ្ញា ក្នុងកាលនោះ បុគ្គលរមែងមិនប្រាថ្នា របស់ដទៃណាមួយឡើយ វៀរលែងតែព្រះនិព្វាន ដែលមិនមានបដិសន្ធិ ។

២០.ក្នុងគម្ពីរវិសុទ្ធិមគ្គ កង្ខាវិតរណវិសុទ្ធិ បានសម្ដែងថា វិបាកទាំងឡាយ រមែងប្រព្រឹត្តទៅព្រោះកម្ម ។ វិបាកមានកម្មជាដែនកើត ។ ភពថ្មី រមែងមាន ព្រោះកម្ម ។ លោករមែងវិលទៅដូច្នេះឯង ។

កាលព្រះយោគាវចរ ពិចារណាឃើញយ៉ាងនេះហើយ សេចក្ដីសង្ស័យប្រារព្ធក្នុងចំណែកខាងដើម មានជាអាទិ៍ដែលបានពោលដោយន័យថា អតីតកាល យើងបានមានដែរឬហ្ន៎ ដូច្នេះ សេចក្ដីសង្ស័យទាំងពួងនោះ លោករមែងលះបង់បាន ។ ប្រាកដតែនាមរូប ដែលប្រព្រឹត្តទៅក្នុងកំណើត គតិ ឋិតិ និងនិវាសទាំងពួង ដោយអំណាចការបន្តគ្នា នៃហេតុនិងផលប៉ុណ្ណោះ ។

ព្រះយោគាវចរ មិនបានឃើញអ្នកសាងដទៃក្រៅពីហេតុ ។ មិនឃើញអ្នកសោយផលដទៃក្រៅអំពី ការប្រព្រឹត្តទៅនៃវិបាកឡើយ ។ លោកមានការឃើញដ៏ល្អ ដោយប្រាជ្ញាដ៏ប្រពៃថា កាល



ហេតុមាន បណ្ឌិតទាំងឡាយ បានពោលដោយសន្មតថា « អ្នកសាង » កាលដែលមានការប្រព្រឹត្តទៅនៃវិបាក បណ្ឌិតទាំងឡាយបានពោលដោយសន្មតថា « អ្នកសោយ » ប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទាំងឡាយ ទើបបានពោលទុកមកថាៈ

អ្នកសាងកម្មមិនមាន អ្នកសោយផលក៏មិនមាន គឺធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅ ។ ការឃើញដូច្នេះ ជាការឃើញដោយប្រពៃ ។

កាលកម្មនិងវិបាក ព្រមទាំងហេតុប្រព្រឹត្តទៅយ៉ាងនោះ អ្នកណាៗ ក៏មិនអាចដឹងបាននូវខាងដើមនិងខាងចុងនៃវដ្តៈដែរ ដូចជាគ្រាប់ពូជ និងដើមឈើជាដើម ដែលអ្នកណាៗ ក៏មិនអាចដឹងបាន (ថាមានពីត្រឹមណាមក) ដូច្នោះឯង ។

សូម្បីក្នុងអនាគតកាល កាលបើសង្សារវដ្តនៅមាន ការដែលមិនប្រព្រឹត្តទៅ (នៃកម្មនិងវិបាក ) ក៏មិនអាចដឹងបានដែរ (គឺវាចេះតែប្រព្រឹត្តទៅដោយមិនមានទីបំផុតឯងៗឡើយ ) ។

ពួកអន្យតិរ្ថិយ មិនដឹងសេចក្ដីនេះ ទើបមិនមានអំណាចក្នុងខ្លួន (រមែងធ្លាក់ទៅក្នុងអំណាចនៃសេចក្ដីប្រកាន់ខុសផ្សេងៗ ) កាន់យកនូវសត្តសញ្ញា (សម្គាល់ថាជាសត្វបុគ្គល ) ហើយក៏មានការយល់ខុសថា ទៀងខ្លះ ដាច់សូន្យខ្លះ ប្រកាន់នៅក្នុងទិដ្ឋិ ៦២ [១]

---

១.ទិដ្ឋិ ៦២ មានក្នុងបិដកលេខ ១៤ ព្រហ្មជាលសូត្រ ។

ហើយឈ្លោះទាស់ទែងគ្នា ។ ពួកគេទាំងនោះ ត្រូវគ្រឿងចងគឺទិដ្ឋិ ចងទុក និងអណ្តែតទៅតាមក្រសែទឹកគឺតណ្ហា ទើបមិនរួចផុតចាកទុក្ខទៅបានឡើយ ។

ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ បានដឹងដោយប្រាជ្ញាដ៏ប្រពៃក្រៃលែងនូវអត្ថ ដូចដែលបានពោលមកយ៉ាងនេះហើយ ទើបចាក់ផ្ទុះនូវបច្ច័យ ដ៏ល្អិតល្អន់ជ្រាលជ្រៅទៅបាន (ព្រមទាំងចាក់ផ្ទុះនូវផលនៃបច្ច័យនោះៗ ) ដោយនូវសភាពសូន្យទទេ (គឺសូន្យចាកខ្លួន និងចាកវត្ថុជារបស់ខ្លួន ) ។

កម្មមិនមាននៅក្នុងវិបាក រីឯវិបាកវិញ ក៏មិនមាននៅក្នុងកម្មដែរ ទាំងពីរយ៉ាងសូន្យចាកគ្នានឹងគ្នា តែថា បើវៀរចាកកម្មហើយ ផលក៏មិនមានដែរ ។

តាមពិត ក្នុងសង្សារប្បវត្តិនេះ អ្នកសាងសង្សារគឺជាទេវតា ឬព្រហ្មក៏ដោយ រមែងមិនមានឡើយ ។ នេះជាធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅ ព្រោះការរួមចូលគ្នានៃហេតុ និងបច្ច័យនោះឯង ។

២១.ប្រក្រតីនៃជីវិត សុទ្ធតែមានធម៌ត្រូវសិក្សា ត្រូវរលឹក ត្រូវដឹង តាមសេចក្តីពិត ។ យ៉ាងនេះឯងទើបអាចចូលដល់សច្ចធម៌ ដោយសច្ចញ្ញាណបាន ។



២២.ប្រក្រតីនៃជីវិតគ្រប់គ្នា មានសុទ្ធតែធម៌ទាំងអស់ ។ រៀនស្តាប់ រៀនគិតឱ្យយល់ រួចហើយនឹងមានឱកាស លះបង់នូវសក្កាយទិដ្ឋិ[1] ដោយ **តទង្គប្បហាន** រឿយៗ ។

២៣.មនុស្សយើងខ្វល់រវល់នឹងខ្លួនឯងសព្វថ្ងៃ ព្រោះហេតុតែមិនដឹងសភាវធម៌ជាប្រក្រតីហ្នឹងឯង ។ ការមិនដឹងនាំឱ្យសេចក្តីប្រកាន់កើតឡើង ម្ល៉ោះហើយចិត្តក៏បានសាងរឿងសម្រាប់ឱ្យខ្វល់ដ៏សន្ធឹកសន្ធាប់ ។

២៤.ចិត្តចង់បដិបត្តិធម៌ ហើយនិងការយល់ដឹងធម៌ដែលកំពុងប្រាកដ ទាំងពីរផ្នែកនេះគឺមិនដូចគ្នាទេ ។

២៥.វិហារធម៌នៃការរស់នៅ ដោយឡែកផ្សេងអំពី ការទៅធ្វើធម៌ ។ ការទៅធ្វើធម៌ ហើយនិងការរលឹកដឹងធម៌ដែលកំពុងប្រាកដជាបច្ចុប្បន្ន ទាំងពីរមុខនេះ គឺផ្ទុយគ្នា មួយផ្នែកនៅជាប់រវល់ មួយផ្នែកទៀតកំពុងលះរវល់ ។ រីឯវិហារធម៌នៃការរស់នៅ គឺជាប្រក្រតីនៃធម៌ដែលកើតរលត់ កើតរលត់ តៗគ្នា ។

១.វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ **ជួន ណាត** :សកាយទិដ្ឋិ

២៦.ការរស់នៅ ងាយៗ ជាមួយនឹងធម្មជាតិនោះៗ ធ្វើឱ្យយល់ដឹងពីធម្មជាតិច្បាស់ឡើង ហើយបព្រាសពីតណ្ហា ត្រឡប់មកកាន់ធម្មជាតិ ដែលធម្មជាតិគ្រប់យ៉ាងមិនខ្វល់នឹងខ្លួនឯង ព្រោះអ្វីៗ គឺជាផលនៃបច្ច័យ ។

២៧.ជីវិតដែលពិតប្រាកដ កើតរលត់ កើតរលត់ តៗគ្នានៃនាមរូប មិនមានអ្វីឱ្យហួងហែងឡើយ ដូច្នេះ ទើបគួររស់នៅដោយងាយៗជាមួយនឹងធម្មជាតិ ទទួលទានអាហារងាយៗ ទទួលទានដំណេកងាយៗ ស្លៀកពាក់ក៏ងាយៗ ... ហើយមិនប្រកាន់ខ្លួនជាមួយនឹងបុគ្គលទូទៅ មានសន្តោស មានមេត្តា និងអត់ធន់បាន។ ប៉ុន្តែ តណ្ហាបាននាំជីវិតចូលទៅកាន់សេចក្តីលំបាក និងឱ្យឆ្ងាយពីការយល់ដឹងនូវធម្មជាតិ ព្រោះប្រកបដោយការប្រកាន់ខ្លួន មានះទិដ្ឋិ ... ។

២៨.លោកអនាថបិណ្ឌិកសេដ្ឋី បានពោលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ របស់ណាមួយកើតហើយ បច្ច័យតាក់តែងហើយ គិតហើយ អាស្រ័យគ្នាកើតហើយ របស់នោះ មិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ



ខ្ញុំយល់ក្នុងរបស់នោះ ដោយប្រពៃ ដោយប្រាជ្ញាដ៏ត្រឹមត្រូវ តាមសេចក្តីពិតយ៉ាងនេះថា នោះមិនមែនរបស់អញ នោះមិនមែនជាអញ នោះមិនមែនជាខ្លួនរបស់អញឡើយ ទាំងខ្ញុំដឹងច្បាស់អំពីការរលាស់ចេញនូវរបស់នោះ តទៅទៀត តាមសេចក្តីពិត ។

២៩.សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅជិតឆ្នេរទន្លេគង្គា ទៀបក្រុងអជ្ឈេយៈ ។ ព្រះដ៏មានព្រះភាគទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹក ក្នុងឆ្នេរទន្លេគង្គា ។ លុះទតហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញកំណាត់ឈើឯណោះ កំពុងអណ្តែតតាមខ្សែទឹកទន្លេគង្គាដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បើកំណាត់ឈើ មិនអណ្តែតមកកាន់ត្រើយអាយ មិនទៅកាន់ត្រើយនាយ មិនលិចចុះត្រង់កណ្តាល មិនរសាត់ឡើងទៅលើគោក មិនមានមនុស្សចាប់យក មិនមានអមនុស្សចាប់យក មិនមានទឹកវល់កួចយក និងមិនស្អុយខាងក្នុងទេ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ កំណាត់ឈើនោះ នឹងរសាត់ទៅរកសមុទ្រ រេទៅរកសមុទ្រ ងាកទៅរកសមុទ្រ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ខ្សែទឹកទន្លេគង្គា ហូរទៅ

រកសមុទ្រ  រេទៅរកសមុទ្រ  ងាកទៅរកសមុទ្រ  យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ  បើអ្នកទាំងឡាយ  មិនឡើងកាន់ត្រើយខាងអាយ  មិនឆ្លងទៅកាន់ត្រើយខាងនាយ  មិនលិចចុះត្រង់កណ្តាល មិនរសាត់ឡើងលើគោក  មិនមានមនុស្សចាប់យក  មិនមានអមនុស្សចាប់យក មិនមានទឹកវល់កួចយក និងមិនស្អុយខាងក្នុងទេ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ អ្នកទាំងឡាយ នឹងឱនទៅរកព្រះនិព្វាន រេទៅរកព្រះនិព្វាន ងាកទៅរកព្រះនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុ ទាំងឡាយ  ព្រោះថាសម្មាទិដ្ឋិតែងឱនទៅរកព្រះនិព្វាន រេទៅរកព្រះនិព្វាន ងាកទៅរកព្រះនិព្វាន យ៉ាងនោះឯង ។

កាលបើព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ  ភិក្ខុមួយអង្គបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ  ដូច្នេះថា  បពិត្រព្រះអង្គដ៏ចម្រើន  អ្វីជាត្រើយអាយ  អ្វីជាត្រើយនាយ  អ្វីដែលលិចចុះត្រង់កណ្តាល  អ្វីដែលរសាត់ទៅលើគោក  អ្វីជាមនុស្សចាប់យក  អ្វីជាអមនុស្សចាប់យក អ្វីជាទឹកវល់កួចយក អ្វីជាសភាពស្អុយក្នុង ។

ម្នាលភិក្ខុ ពាក្យថាត្រើយអាយ នេះជាឈ្មោះនៃ អាយតនៈខាងក្នុង ៦ ។ ម្នាលភិក្ខុ ពាក្យថាត្រើយនាយ នេះជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលភិក្ខុ ពាក្យថាលិចចុះត្រង់កណ្តាល



នេះជាឈ្មោះនៃនន្ទិរាគ ។ ម្នាលភិក្ខុ ពាក្យថារសាត់ទៅលើគោក នេះជាឈ្មោះនៃអស្មិមានះ ។ ម្នាលភិក្ខុ ចុះមនុស្សចាប់យក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅច្រឡូកច្រឡំដោយពួកគ្រហស្ថ មានសេចក្តីរីករាយជាមួយគ្នា មានសេចក្តីសោយសោកជាមួយគ្នា  កាលបើពួកគ្រហស្ថបានសុខ  ក៏បានសេចក្តីសុខ កាលបើពួកគ្រហស្ថបានទុក្ខ ក៏បានសេចក្តីទុក្ខ កាលបើកិច្ចដែលត្រូវធ្វើកើតឡើង  ក៏ខំប្រឹងប្រែងធ្វើដោយខ្លួនឯង  ។ ម្នាលភិក្ខុ នេះហៅថា មនុស្សចាប់យក ។ ម្នាលភិក្ខុ ចុះអមនុស្សចាប់យក តើដូចម្តេច ។ ម្នាលភិក្ខុ ភិក្ខុពួកខ្លះ ក្នុងសាសនានេះបានប្រព្រឹត្តព្រហ្មចរិយធម៌  ដើម្បីប្រាថ្នាទៅកើត  ក្នុងទេវតាណាមួយថា អាត្មាអញសូមបានជាទេវតា ឬជាទេវតាណាមួយ ដោយសីល ឬដោយវត្ត ដោយតបៈ ឬដោយព្រហ្មចរិយធម៌នេះ ។ ម្នាលភិក្ខុ  នេះហៅថាអមនុស្សចាប់យក  ។ ម្នាលភិក្ខុ ពាក្យថាទឹកវល់កួចយក នេះជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុ ចុះបុគ្គលមានសភាពស្អុយខាងក្នុង  តើដូចម្តេច  ។  ម្នាលភិក្ខុ  ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មិនស្អាត មានមារយាទដែលបុគ្គលដទៃគប្បីរង្កៀស  មានអំពើបិទបាំងទុក  មិនមែនជាសមណៈ  តែប្តេជ្ញាថា  ជាសមណៈ  មិនមែនជាព្រហ្មចារី

ប្ដេជ្ញាថា ជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានសេចក្ដីស្មោកគ្រោក ដោយកិលេស ។ ម្នាលភិក្ខុ នេះហៅថា បុគ្គលមានសភាពជាអ្នកស្អុយខាងក្នុង ។

សម័យនោះឯង នន្ទៈគោបាល (នាយគោបាលឈ្មោះនន្ទៈ) ឋិតនៅក្នុងទីជិត ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ នន្ទៈគោបាល បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឡើងមកកាន់ត្រើយអាយ មិនឆ្លងទៅកាន់ត្រើយនាយ មិនលិចចុះត្រង់កណ្ដាល មិនរសាត់ទៅលើគោក មិនមានមនុស្សចាប់យក មិនមានអមនុស្សចាប់យក មិនមានទឹកវល់កួចយក និងមិនស្អុយខាងក្នុងទេ បពិត្រព្រះអង្គដ៏ចម្រើន សូមមេត្តាប្រោស ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។

ម្នាលនន្ទៈ បើដូច្នោះអ្នកចូរប្រគល់គោទាំងឡាយ ឱ្យដល់ម្ចាស់គេវិញចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន មេគោទាំងឡាយដែលជាប់ជំពាក់ដោយកូនគោ នឹងទៅតាមកូនគោ ។ ម្នាលនន្ទៈ ណ្ហើយចុះ អ្នកចូរប្រគល់គោ ឱ្យម្ចាស់គេចុះ ។

លំដាប់នោះ នន្ទៈគោបាល ប្រគល់គោទាំងឡាយឱ្យដល់ម្ចាស់ហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់



ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គោទាំងឡាយ ខ្ញុំព្រះអង្គបានប្រគល់ឱ្យម្ចាស់គេហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។ នន្ទៈគោបាល ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។ លុះព្រះនន្ទៈដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ ... ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះនន្ទៈដ៏មានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។

៣០.កិលេស ត្រេកអរនឹងរបស់ដែលនាំទុក្ខមកឱ្យ ក្នុងសង្សារវដ្ដ ។

៣១.បញ្ញា ដែលចូលដល់សច្ចធម៌ បានធ្វើឱ្យអ្វីៗទាំងអស់ក្នុងលោក មិនជាបញ្ហាក្នុងជីវិត សន្តិភាពក្នុងចិត្ត មិនបៀតបៀនខ្លួនឯង មិនបៀតបៀនអ្នកដទៃ ... ។ បុគ្គលដែលមិនដឹង យល់ថា ព្រះពុទ្ធសាសនា មិនបានជួយអ្វី ដល់សង្គមជាតិ ។

៣២.លក្ខណៈសំខាន់របស់ព្រះនិព្វាន ដែលមានឈ្មោះថា

និរោធ ប្រែថា ការរលត់នោះ គួរឱ្យពុទ្ធបរិស័ទយើងយល់ដឹងនិងជ្រះថ្លាគឺមានបីយ៉ាង :

(១)-**ការរលត់អវិជ្ជា** សំដៅដល់ការកើតឡើងនៃញាណ-ទស្សនៈដ៏ខ្ពង់ខ្ពស់ ត្រាស់ដឹងនូវសច្ចធម៌ ។

(២)-**ការរលត់កិលេស** សំដៅដល់ការកម្ចាត់សេចក្តីអាក្រក់និងភាព សៅហ្មងផ្សេងៗក្នុងចិត្ត អស់ហេតុដែលសម្រាប់បង្កនូវបញ្ហាបង្កសេចក្តី ក្តៅក្រហាយផ្សេងៗដល់ជីវិតក្នុងសង្គម ។

(៣)-**ការរលត់ទុក្ខ** សំដៅដល់ការអស់ទុក្ខ គឺជាការបានសម្រេចសេចក្តីសុខដ៏ខ្ពង់ខ្ពស់ ។

៣៣-សេចក្តីសុខមានសេចក្តីសំខាន់ណាស់ ក្នុងបដិបត្តិធម៌នៃព្រះពុទ្ធសាសនា ។ បដិបត្តិធម៌ មិនចែកផ្សេងគ្នាអំពីសេចក្តីសុខឡើយ ចាប់ផ្តើមតាំងអំពីដំបូងក្នុងការធ្វើល្អទូទៅ ដែលហៅថាបុណ្យ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា «អ្នកទាំងឡាយចូរកុំខ្លាចបុណ្យ ព្រោះបុណ្យជាឈ្មោះនៃសេចក្តីសុខ »។

ក្នុងការបំពេញព្យាយាមផ្លូវចិត្ត ឬចម្រើនភាវនា សេចក្តី-សុខក៏ជាបច្ច័យដ៏សំខាន់ក្នុងការជួយឱ្យកើតសមាធិ ( អ្នកមានសុខចិត្តរមែងតាំងមាំ ) លុះដល់ចិត្តជាសមាធិសម្រេចឈានហើយ



សេចក្តីសុខក៏ជាអង្គប្រកបរបស់ឈាន ដូចដែលយើងហៅថាអង្គឈាន រហូតដល់ឈានទី៤ (បញ្ចកន័យ ) ។ ឈានសមាបត្តិដែលខ្ពស់ជាងនោះតទៅ សូម្បីមិនមានសុខជាអង្គប្រកបក៏ដោយគឺរឹងរឹតតែសុខយ៉ាងប្រណីតក្រៃលែងទៅទៀត ។

ចំណុចទិសដៅដ៏ខ្ពង់ខ្ពស់របស់ព្រះពុទ្ធសាសនា បានដល់ព្រះនិព្វានជាបរមសុខ គឺសុខដ៏ខ្ពង់ខ្ពស់ដ៏ក្រៃលែងបំផុត ។

៣៤-ក្រៅពីចំណុចទិសដៅដ៏ខ្ពង់ខ្ពស់របស់ព្រះពុទ្ធសាសនាដែលជាបរមសុខគឺព្រះនិព្វាននោះ នៅមានសុខដែលជាធម៌បដិ-បត្តិទៀត ដើម្បីឱ្យបានសម្រេចនូវចំណុចទិសដៅដ៏ខ្ពង់ខ្ពស់នោះ ។

បរមសុខគឺ ព្រះនិព្វាន មិនមែនសម្រេចដោយទុក្ខ ឬធម៌បដិបត្តិដែលជាទុក្ខឡើយ ។

ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា « តថាគតបានសម្រេចដល់សេចក្តីសុខដែលមិនអាស្រ័យកាម ទើបប្តេជ្ញាថា នឹងមិនត្រឡប់មករកកាមទៀត » ។ ព្រមជាមួយគ្នានោះ ព្រះអង្គបានត្រាស់សម្តែងដាស់តឿនអ្នកប្រព្រឹត្តធម៌ ឱ្យចាំទុកថា : បើអរិយសាវ័ក បានឃើញច្បាស់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មាន

សេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនក្រៃពេក ។ អរិយសាវ័កនោះឯងបានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលធម៌ទាំងឡាយហើយ តែមិនទាន់បាននូវ បីតិ និង សុខ ឬគុណជាតិដទៃដែលល្អិតលើសជាង បីតិ និង សុខ នោះទេ កាលបើដូច្នេះ អរិយសាវ័កនោះ នឹងឈ្មោះថា មិនវិលត្រឡប់មករកកាមទាំងឡាយវិញនោះ មិនមែនឡើយ ។

សេចក្តីដែលលើកមកបញ្ជាក់នេះ ក្រៅអំពីការសម្តែងឱ្យឃើញថា ព្រះពុទ្ធសាសនាកាន់យកសេចក្តីសុខជារឿងសំខាន់ហើយ នៅធ្វើឱ្យយើងមានការសិក្សាសង្កេតតទៅទៀតថា ការដែលអរិយសាវ័ក លះកាមនោះ មិនមែនព្រោះកាមមិនមានសេចក្តីសុខនោះទេ ឬថាព្រោះព្រះពុទ្ធសាសនាប្រដៅឱ្យវៀរចាកសេចក្តីសុខក៏មិនមែនដែរ ។

ព្រះពុទ្ធសាសនាព្រមទទួលថា សុខតាមសេចក្តីពិតទូន្មានឱ្យបដិបត្តិ ដើម្បីសម្រេចនូវសេចក្តីសុខ និងព្រមទទួលថាកាមមានសេចក្តីសុខ ប៉ុន្តែអរិយសាវ័ក លះកាមព្រោះឃើញថា កាមមានសេចក្តីសុខក៏ពិតមែនហើយ តែនៅលាយឡំដោយទុក្ខច្រើន និងចំណុចសំខាន់ក៏គឺ នៅមានសេចក្តីសុខដទៃ ដែលសុខជាងជ្រៅល្អិត ប្រណីតជាងសុខដែលកើតអំពីកាម ។



៣៥-ចាកការសិក្សា ក្នុងមហាសតិប្បដ្ឋានសូត្រ បានឃើញថា សតិប្បដ្ឋានវិបស្សនា មិនមែនជាធម៌ដែលចាំបាច់ត្រូវគេចខ្លួនចេញទៅបដិបត្តិនៅខាងក្រៅពីសង្គមមនុស្សឡើយ ឬថាចាំបាច់ចំពោះក្នុងវេលាណាមួយក៏មិនមែនដែរ ។

ពោលដោយសារៈសំខាន់ ក្នុងគោលសតិប្បដ្ឋាន៤ បានបង្ហាញឱ្យឃើញថា ជីវិតរបស់យើងនេះ មានគោលចំណុចដែលគួរអប់រំចម្រើនសតិ គ្រប់គ្រងទាំងអស់ត្រឹមតែ៤ ផ្នែកប៉ុណ្ណោះឯងគឺ

(១)-រូបដែលប្រាកដមានឡើងគ្រប់ពេលនៃការប្រព្រឹត្តទៅនៃកាយ ។

(២)-វេទនា គឺ សេចក្តីដឹងខ្លួនជាសុខ ជាទុក្ខផ្សេងៗ ។

(៣)-សភាពនៃចិត្តដែលប្រាកដលក្ខណៈ ដឹងច្បាស់នូវអារម្មណ៍ ។

(៤)-ពួកធម៌ផ្សេងៗ ដែលប្រកបជាមួយនឹងការនឹកគិត និងពួកធម៌ផ្សេងៗទៀតដែលបានប្រាកដឡើង ។

បើការប្រព្រឹត្តទៅនៃជីវិត មានសតិគ្រប់គ្រងក្នុងគោលចំណុចទាំង៤ នេះហើយ ក៏នឹងជួយឱ្យជីវិតរស់នៅប្រាសចាកភ័យប្រាសចាកទុក្ខ មានចិត្តស្អាតប្រកបដោយសុខ និងស្ថិតនៅក្នុងបដិបទាដែលនាំទៅកាន់ ការដឹងច្បាស់នូវអរិយសច្ចធម៌ ។

អត្ថន័យ សេចក្ដីក្នុងការសម្ដែងសតិប្បដ្ឋានសូត្រ បាន បញ្ជាក់ប្រាប់ឱ្យដឹងថា ក្នុងពេលបដិបត្តិនោះ មិនមែនមានសតិតែ ម្យ៉ាងប៉ុណ្ណោះទេ គឺមានធម៌ផ្សេងៗទៀត ដែលត្រូវអប់រំចម្រើន ព្រមជាមួយគ្នា ។

ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្ដែងក្នុងគោលសតិប្បដ្ឋាន នីមួយៗគឺ

(១)-**អាតាបី** មានសេចក្ដីព្យាយាម បានដល់សម្មាវាយាមៈ (ព្យាយាមសង្រួម និងព្យាយាមលះនូវសេចក្ដីអាក្រក់ ព្រមទាំង ព្យាយាមចម្រើន និងព្យាយាមរក្សានូវសេចក្ដីល្អ) ។

(២)-**សម្បជានោ** មានសម្បជញ្ញៈ បានដល់បញ្ញា ។

(៣)-**សតិមា** មានសតិ បានដល់តួសតិហ្នឹងឯង ។

ចំណុចដែលគួរសង្កេតគឺ សម្បជានោ ដែលប្រែថា មាន សម្បជញ្ញៈ ។ សម្បជញ្ញៈនេះ យើងឃើញថា ជាធម៌ច្រើនតែជាគូ នឹងសតិ ។ សម្បជញ្ញៈ ក៏គឺបញ្ញា ដូច្នេះការហ្វឹកហាត់អប់រំសតិនេះ ទើបជាផ្នែកបដិបត្តិមួយ ក្នុងការចម្រើនបញ្ញានោះឯង ។

បញ្ញាគឺ ការដឹង ការយល់ច្បាស់ក្នុងសភាវធម៌ ដែលសតិ បានកំណត់ទុក មិនមានការវង្វេង ឬការយល់ខុសណាៗ ទៅក្នុង សភាវធម៌ឡើយ ។



**អាតាបី សម្បជានោ សតិមា** ប្រែថា មានព្យាយាម មាន សម្បជញ្ញៈ មានសតិ គឺសម្មាវាយាមៈ សម្មាទិដ្ឋិ និងសម្មាសតិ ដែលជាអង្គមគ្គ ។ អង្គមគ្គជាប្រចាំ ៣ នេះ អប់រំចម្រើនគូបគ្នា ទៅជាមួយគ្នាជានិច្ច ក្នុងការចម្រើននូវសតិប្បដ្ឋានវិបស្សនា ។

**សម្មាវាយាម** គឺព្យាយាមដាស់ចិត្ត ជំរុញចិត្ត មិនឱ្យទម្រន់ មិនឱ្យរួញរា ដូច្នេះទើបមិនបើកឱកាសឱ្យអកុសលធម៌កើតឡើង ។ សម្មាវាយាមៈ រមែងញ៉ាំងកាយ ញ៉ាំងចិត្ត ឱ្យស្ថិតនៅក្នុងផ្លូវបដិបត្តិ ជានិច្ច ញ៉ាំងកុសលធម៌ផ្សេងៗ ឱ្យចម្រើនឡើងៗ ។

**សម្មាសតិ** គឺជាតួកំណត់ចាប់អារម្មណ៍ តាមទាន់ ដឹងទាន់ មិនភាន់ភាំង មិនប្រហែស មិនបណ្ដោយ មិនឱ្យកម្លាំងដល់បាប អកុសល (អត់សតិ ដូចជាការដេកលក់) ។

សេចក្ដីក្នុងគោលសតិប្បដ្ឋានជាចុងក្រោយគឺ

**វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ប្រែថា កម្ចាត់ អភិជ្ឈា និងទោមនស្សក្នុងលោកបាន ។

ដោយសេចក្ដីថា កាលបដិបត្តិយ៉ាងនេះ ចិត្តក៏ផុតស្រឡះ មិនមានជាប់ជំពាក់ចង់បាន និងមិនមានការអាក់អន់ខ្វួចចិត្ត ចូល មកគ្របសង្កត់ រំខានក្នុងជីវិតឡើយ ។ នេះគឺជា ផលនៃការ ព្យាយាម មានសតិសម្បជញ្ញៈ ។

**អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ ។**

ប្រែថា : ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។

ដោយសេចក្តីថា មានសតិកំណត់ច្បាស់លាស់ ត្រង់តាមសេចក្តីពិតថា មានតែកាយ មិនមានសត្វបុគ្គល បុរសស្ត្រី ខ្លួនរបស់ខ្លួន ឬរបស់គេឡើយ ។ កាយមាន គឺមានដើម្បីត្រឹមតែឱ្យចម្រើនប្រាជ្ញាស្មារតីប៉ុណ្ណោះ ពោលគឺ ជាទីតាំងនៃសតិសម្បជញ្ញៈ មិនមែនដើម្បីសេចក្តីប្រកាន់មាំជាដើមឡើយ ។

**អនិស្សិតោ ច វិហរតិ** ប្រែថា ភិក្ខុមានចិត្ត មិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំងបួនផង ។

ដោយសេចក្តីថា មានចិត្តជាឥស្សរៈ គឺមិនមានតណ្ហា និងទិដ្ឋិជាទីអាស្រ័យ មិននៅក្នុងអំណាចនៃកិលេស ។

**ន ច កិញ្ចិ លោកេ ឧបាទិយតិ** ប្រែថា មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**កាយេ កាយានុបស្សី វិហរតិ** ប្រែថា ពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ។



ដោយសេចក្តីថា ឃើញដោយបញ្ញាទៅក្នុងកាយថា មានតែកាយហ្នឹងឯង គឺមើលឃើញកាយតាមសភាវធម៌ ដែលជាទីប្រជុំ ឬប្រកបបចូលគ្នា នៃសភាវរូបផ្សេងៗ ។ មិនមែនមើលឃើញកាយជាយើង ជាគេ ឬជារបស់យើង របស់គេជាដើមឡើយ ។

ជាការឃើញត្រង់តាមសេចក្តីពិត ត្រង់តាមសភាវៈ គឺមើលកាយក៏ឃើញកាយ មិនមែនមើលកាយ ទៅជាឃើញអ្នកនេះ អ្នកនោះ ឬអ្នកដែលស្អប់ អ្នកដែលស្រឡាញ់ជាដើមនោះឡើយ ។

**៣៦-យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ តំ ន បស្សតិ អបស្សំ ពជ្ឈតេ មូឡ្ហោ ពជ្ឈមានោ ន មុច្ចតិ ។**

ប្រែថា : បុគ្គលឃើញរបស់ណា របស់នោះគេមិនបានមើលឡើយ របស់ណាដែលគេបានមើល របស់នោះគេមិនបានឃើញ ។ បុគ្គលវង្វេង កាលមិនបានឃើញ នូវរបស់ដែលមើលរមែងជាប់ជំពាក់ កាលជាប់ជំពាក់ហើយ ក៏មិនអាចរួចផុតទៅបាន ( អដ្ឋកថា មគ្គសច្ចនិទ្ទេស បដិសម្ភិទាមគ្គ ) ។

ដោយសេចក្តីថា របស់ដែលមើល មើលមិនឃើញ ត្រឡប់ទៅជាឃើញ របស់ដែលមិនបានមើលទៅវិញ ។

ឧទាហរណ៍ មើលកាយ បែរជាឃើញមនុស្ស សត្វ បុគ្គល (ជាបញ្ញត្តិ) ។

ការចម្រើនសតិប្បដ្ឋាន គឺនាំមកនូវការឃើញត្រូវនូវសភាវៈពិត គឺឱ្យរបស់ដែលមើលត្រូវគ្នានឹងរបស់ដែលឃើញ ឬបានឃើញត្រឹមត្រូវចំទៅលើរបស់ដែលមើល ។

**៣៧. ខន្ធា និរុជ្ឈន្តិ ន ចត្តិ អញ្ញោ**
**ខន្ធាន ភេទោ មរណន្តិ វុច្ចតិ**
**តេសំ ខយំ បស្សតិ អប្បមត្តោ**
**មណឹវ វិជ្ឈំ វជិរេន យោនិសោ ។**

ប្រែថា : ខន្ធទាំងឡាយរមែងរលត់ មិនមានអ្វីៗដទៃ (គឺមិនមានសត្វបុគ្គល) ការបែកធ្លាយនៃខន្ធលោក ហៅថាមរណៈ បុគ្គលមិនប្រមាទ ឃើញការអស់ទៅនៃខន្ធទាំងនោះ ដោយយោនិសោមនសិការ ដូចជាងកែវមណីយកចិត្តទុកដាក់ចោះកែវមណី ដោយកែវវជិរ គឺពេជ្រ ដូច្នោះឯង ។

**៣៨.ទុក្ខមាន ៣ ពួក :**

(១).ទុក្ខវេទនា គឺការសោយអារម្មណ៍ជាទុក្ខ ។



(២).ទុក្ខលក្ខណៈក្នុងត្រៃលក្ខណ៍ គឺ របស់ណាមិនទៀង របស់នោះជាទុក្ខ ( **យទនិច្ចំ តំ ទុក្ខំ** ) បានដល់សង្ខារធម៌ទាំងពួង ។

(៣).ទុក្ខអរិយសច្ចៈ គឺទុក្ខដែលមានសេចក្តីពិតយ៉ាងប្រសើរ ទុក្ខដែលជាបញ្ហារបស់សត្វលោក ទុក្ខដែលជាប់ដោយឥន្ទ្រិយ ទុក្ខដែលអាស្រ័យកម្មក្កិលេស ទុក្ខដែលត្រូវកំណត់ដឹង និងទុក្ខព្រោះជាអណ្តូងទុក្ខ ។

### អធិប្បាយទុក្ខអរិយសច្ចៈ

-ទុក្ខដែលមានសេចក្តីពិតយ៉ាងប្រសើរ គឺជាសច្ចធម៌ប្រចាំឧបាទានក្ខន្ធ ៥ ដែលបុគ្គលណាបានកំណត់ដឹងដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះរមែងលះបង់នូវហេតុនៃទុក្ខ បានជាក់ច្បាស់នូវទីរំលត់ទុក្ខ បាននូវមគ្គដ៏ប្រសើរ ជាព្រះអរិយបុគ្គល ។

-ទុក្ខដែលជាបញ្ហារបស់សត្វលោក គឺជាទុក្ខក្នុងត្រៃលក្ខណ៍នោះឯង តែមិនជាទូទៅទាំងអស់ចំពោះទុក្ខលក្ខណៈនោះឡើយ សំដៅត្រឹមតែទុក្ខដែលមានការប៉ះខ្ទប់ដល់ជីវិត ជាទុក្ខដែលធ្លាក់ចុះក្នុងឧបាទានក្ខន្ធប៉ុណ្ណោះ ។

-ទុក្ខដែលជាប់ដោយឥន្ទ្រិយ គឺជាប់ដោយជីវិត ជាបញ្ហារបស់សត្វលោក ។

-ទុក្ខដែលអាស្រ័យកម្មក្កិលេស គឺជាទុក្ខដែលមានតណ្ហាជាដែនកើត ជាទុក្ខដែលត្រូវដោះស្រាយ ព្រោះជាបញ្ហា ។

-ទុក្ខដែលត្រូវកំណត់ដឹង គឺត្រូវកំណត់ដឹងតាមសភាពពិតរបស់ទុក្ខ ជាកិច្ចដែលអ្នកអប់រំបញ្ញា ត្រូវធ្វើចំពោះអរិយសច្ចទីមួយនេះ ពោលគឺ ត្រូវយល់ដឹងចំពោះបញ្ហាក្នុងដំណើរជីវិតរបស់ខ្លួន ។

-ទុក្ខព្រោះជាអណ្តូងទុក្ខ គឺជាទីតាំងនៃទុក្ខឬជាទីទទួលរងនូវទុក្ខ។

៣៩-កាយនេះបើជារបស់យើងមុខតែមិនមានទុក្ខយ៉ាងនេះឡើយ ព្រោះតែទុក្ខពិត ទើបត្រូវឃើញថា មិនមែនជាយើង មិនមែនជារបស់យើង ។

-បានអ្វីមិនស្មើនឹងបានការលះបង់ ។

-តាំងនៅក្នុងធម៌ហើយ មិនខ្លាចបរលោកឡើយ ។

-បើខ្លួនយើងមិនមានហើយ តើមានអ្វីជារបស់យើង ។

-វ័យអស់ទៅតាមយប់ និងថ្ងៃ ។

-សង្ខារទាំងពួងសុទ្ធតែប្រាសចាកខ្លឹម ។



-រូបធ្វើកិច្ចរបស់រូប វេទនាធ្វើកិច្ចរបស់វេទនា សញ្ញាធ្វើកិច្ចរបស់សញ្ញា សង្ខារធ្វើកិច្ចរបស់សង្ខារ វិញ្ញាណធ្វើកិច្ចរបស់វិញ្ញាណ ។ ខន្ធប្រាំ សុទ្ធតែធ្វើកិច្ចរៀង១ខ្លួន អាយតនៈ ក៏ធ្វើកិច្ចរបស់អាយតនៈ ។ល។ ដូច្នេះមិនគួរចូលទៅប្រកាន់មាំឡើយ ។

-បើសោកសៅដល់មនុស្ស ដែលមិនមាននៅនឹងខ្លួន គឺមនុស្សដែលស្លាប់ទៅហើយ ក៏គួរតែសោកសៅដល់ខ្លួនឯង ដែលធ្លាក់នៅក្នុងអំណាចនៃមច្ចុរាជគ្រប់ពេលវេលា ។

-ការប្រព្រឹត្តទៅនៃសង្ខារធម៌ ប្រសិនបើមានសត្វបុគ្គលតួខ្លួនបង្កប់នៅខាងក្នុង សង្ខារធម៌ពិតជាមិនអាចប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យបានឡើយ ។

-ក្បួននៃការប្រព្រឹត្តទៅរបស់សង្ខារ បញ្ជាក់ពីការមិនមានអ្វីជាអ្នកបណ្តាល និងមិនមានអ្វីបង្គាប់បញ្ជាឡើយ ។

-សេចក្តីប្រាថ្នាមិនមែនជាតួសត្វបុគ្គលទេ គឺជាសភាវធម៌មួយបែប ទាំងមិនមែនជាតួឱ្យសម្រេចនូវអ្វី១ តាមដែលប្រាថ្នានោះឡើយ ។ អ្វី១ក្នុងលោករមែងប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។

៤០-មនុស្សយើងនេះ ដែលនឹងអាចមាននូវសេចក្តីសុខ

យ៉ាងពិតប្រាកដទៅបាននោះ គឺត្រូវមានដំណើរជីវិតយ៉ាងត្រឹមត្រូវ ពោលគឺត្រូវបដិបត្តិឱ្យបានត្រឹមត្រូវចំពោះជីវិតរបស់ខ្លួន និងត្រូវបដិបត្តិឱ្យបានត្រឹមត្រូវចំពោះអ្វីៗ ដែលមាននៅជុំវិញខ្លួន ទាំងផ្នែកវត្ថុ ទាំងផ្នែកធម្មជាតិ ។ មានសេចក្ដីអធិប្បាយដូចតទៅ :

-ដំណើរជីវិតរបស់មនុស្សយើង គឺការងារផ្សេងៗ ដែលសម្ដែងចេញតាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ និងដែលមិនបានសម្ដែងចេញមកខាងក្រៅ តែធ្វើការខាងក្នុងដែលជាការងាររបស់ចិត្តខ្លះ និយាយឱ្យងាយមក គឺការធ្វើ ការនិយាយ និងការគិត ។ បុគ្គលដែលធ្វើកម្មទាំង ៣ យ៉ាងនេះ បានត្រឹមត្រូវល្អ រមែងមានដំណើរជីវិត ប្រព្រឹត្តទៅបានយ៉ាងប្រពៃ ។

-ដំណើរជីវិតមួយផ្នែកទៀត គឺការទទួលដឹងអារម្មណ៍ និងការសោយរសនៃអារម្មណ៍តាមទ្វារទាំង៦ ។ បើការទទួលនូវអារម្មណ៍ប្រព្រឹត្តទៅដោយការស្រឡាញ់ ឬស្អប់ នេះជាប្រភពនៃបញ្ហា តែបើទទួលដោយបញ្ញា ដឹងតាមសេចក្ដីពិត ឬដឹងទៅតាមហេតុផល ដំណើរជីវិតរមែងរួចផុតពីបញ្ហាប្រព្រឹត្តទៅដោយសេចក្ដីសុខស្ងប់ ។

-ផ្នែកមួយផ្សេងទៀតនៃដំណើរជីវិត គឺការចូលទៅទាក់ទងជាមួយនឹងរបស់ទាំងឡាយ ដើម្បីកាន់យកនូវប្រយោជន៍អំពីរបស់



នោះ ។ ការសេពគប់ ការបរិភោគ ការមើល ការអាន និងការស្ដាប់ជាដើម នេះគឺជាដំណើរជីវិត ដែលមានទំនាក់ទំនងជាមួយនឹងសង្គមមនុស្សសត្វ និងវត្ថុ ។ ការគប់រកក្ដី ការបរិភោគក្ដី ការប្រើប្រាស់ក្ដី បើមិនអាស្រ័យការឆ្លាតទេ វាអាចធ្វើឱ្យជីវិតលិចលង់ទៅបាន តែបើឆ្លាត ដំណើរជីវិតនឹងដល់គោលដៅ ។ ទឹកអាចឱ្យទូកដល់គោលដៅ តែក៏អាចឱ្យទូកលិចបានដែរ ។

②-សមុទ្រតែងមានរលក ជីវិតតែងមានបញ្ហា ប៉ុន្តែបញ្ញាអាចដោះស្រាយនូវបញ្ហាបាន ម្យ៉ាងទៀត អ្នកមានបញ្ញារមែងរៀបចំដំណើរជីវិតឱ្យគេចផុតពីបញ្ហា ហើយបានជួបប្រសព្វនូវផលសម្រេចក្នុងជីវិតរបស់ខ្លួន រស់នៅដោយប្រាសចាកទុក្ខកង្វល់ ។

៤១-ដំណើរជីវិតដ៏ត្រឹមត្រូវនឹងបានសម្រេចនូវផលល្អនោះ រមែងមានការប្រព្រឹត្តទៅដោយល្អជាច្រើនផ្នែក ពោលដោយសរុបគឺ

(១)-ក្នុងផ្នែកនៃការធ្វើកម្ម បានដល់ការពូកែគិត ការពូកែនិយាយ និងការពូកែធ្វើ ទាំងដែលជាសុចរិតទៀតផង ។

(២)-ក្នុងផ្នែកនៃការទទួលដឹង បានដល់ការពូកែមើល និងការពូកែស្ដាប់ជាដើម ។

(៣)-ក្នុងផ្នែកទំនាក់ទំនងដ៏ប្រសើរជាមួយនឹងអ្វីៗ ដែលនៅជុំវិញខ្លួន បានដល់ការពូកែបរិភោគ ការពូកែប្រើប្រាស់ និងការពូកែក្នុងការសេពគប់ ឬគប់រក ។

ពាក្យថា « ការពូកែ » ក្នុងទីនេះ គឺសំដៅដល់ភាពឆ្លាតឈ្លាស ប្រព្រឹត្តទៅជាកុសល និងច្រើនដោយសតិសម្បជញ្ញៈ ។

(៤)-មានបញ្ញាសម្រាប់ដោះស្រាយនូវបញ្ហា និងចេះរៀប-ចំដំណើរជីវិតបញ្ចៀសអំពីបញ្ហា ។

②-មនុស្សឆ្លាត គឺជាមនុស្សដែលចេះជួយខ្លួនឯងឱ្យរួចពីបាបកម្មទៅបាន ។

៤២-ព្រះសម្មាសម្ពុទ្ធ គឺជាបុគ្គលដែលបានត្រាស់ដឹងនូវធម៌ ឃើញការកើតឡើងនៃលោកនេះ តាមហេតុ តាមបច្ច័យ ស្រាវ-ជ្រាវរាវរកហើយ បានជួបផ្លូវទៅកាន់ទីមិនមានទុក្ខ ព្រះអង្គមានប្រាជ្ញារកទីបំផុតគ្មាន ។ បំពេញខ្លួនព្រះអង្គជាកល្យាណមិត្ត អង្គដំបូង ទ្រង់ប្រៀនប្រដៅធម៌ ចង្អុលប្រាប់ផ្លូវដែលព្រះអង្គរកឃើញ ហើយនោះឱ្យដល់សត្វលោក ម្យ៉ាងទៀត ព្រះអង្គជាតួយ៉ាង ដែលសម្រាប់អះអាងដល់សមត្ថភាព និងសេចក្តីល្អដ៏ខ្ពង់ខ្ពស់ ដែលអាចហ្វឹកហាត់ឱ្យសម្រេចបានក្នុងភាពជាមនុស្ស ។



ព្រះបច្ចេកពុទ្ធ និងព្រះអរហន្ត មានញាណគ្រាន់តែជាចំណែកខ្លះប៉ុណ្ណោះ រមែងដឹងច្បាស់ដោយប្រពៃ ក្នុងវិស័យរបស់ខ្លួន ឯចំណែកក្នុងអារម្មណ៍ ដែលមិនមែនជាវិស័យ ក៏ដូចជាចូលទៅក្នុងទីងងឹតដូច្នោះឯង ។

ព្រះសម្មាសម្ពុទ្ធ ពុំមានធម៌អ្វីណា ដែលព្រះអង្គមិនបានជ្រាប មិនបានដឹងនោះឡើយ ។ ព្រះអង្គទ្រង់ឃើញធម៌ដែលប្រព្រឹត្តទៅក្នុងកាលទាំងបី និងផុតចាកកាល (និព្វាន និងបញ្ញត្តិ)។ ក្នុងសង្សារវដ្ត ដែលមិនប្រាកដខាងដើម និងខាងចុងព្រមទាំងលោកធាតុ ដែលច្រើនរកទីបំផុតមិនបាន ព្រះអង្គទ្រង់ជ្រាបដោយសព្វគ្រប់ទាំងអស់ បីដូចកែវមណីក្នុងព្រះហស្តដូច្នោះឯង ។

ដោយសេចក្តីថា « ធម៌ទាំងពួង រមែងមកប្រាកដក្នុងសំណាញ់ព្រះញាណរបស់ព្រះដ៏មានព្រះភាគ » ។

៤៣-ព្រះធម៌ដែលព្រះអង្គទ្រង់សម្តែង គឺជាគោលនៃសេចក្តីពិត ជាគោលនៃសេចក្តីល្អ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានរកឃើញហើយ ណែនាំទូន្មានប្រៀនប្រដៅ ។

អ្នកមាននូវសទ្ធាគប្បីស្តាប់ដោយល្អ រៀនដោយល្អ យកមកពិចារណាដោយយោនិសោមនសិការ ឱ្យបានយល់ត្រឹមត្រូវ តាម

សេចក្តីពិត ដើម្បីនឹងបដិបត្តិឱ្យជាផ្លូវ (មគ្គ) និងឱ្យសម្រេចជាផលតទៅ ។ ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្តែង គឺជាបរិយត្តិធម៌ ពាក្យថាធម៌ គឺជាអរិយសច្ចធម៌ គឺគោលនៃសេចក្តីពិត ។

ធម្ម គឺសភាវៈទ្រទ្រង់

-សួរ : ទ្រទ្រង់អ្នកណា ?

-ឆ្លើយ : ទ្រទ្រង់អ្នកដែលតាំងនៅក្នុងធម៌ ដូចព្រះពុទ្ធវចនៈថា « **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** = ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ » ។

-សួរ : ទ្រទ្រង់យ៉ាងណា ?

-ឆ្លើយ : ទ្រទ្រង់មិនឱ្យធ្លាក់ទៅអបាយភូមិបួន និងទុក្ខក្នុងវដ្តៈ ដូចព្រះពុទ្ធវចនៈថា « **ន ទុគ្គតឹ គច្ឆតិ ធម្មចារី** អ្នកប្រព្រឹត្តធម៌ នឹងមិនទៅកាន់ទុគ្គតិ ។ **ធម្មចារី សុខំ សេតិ** អ្នកប្រព្រឹត្តធម៌រមែងនៅជាសុខ ។ **ធម្មោ សុចិណ្ណោ សុខមាវហាតិ** ធម៌ដែលប្រព្រឹត្តល្អហើយ រមែងនាំសុខមកឱ្យ » ។

-សួរ : អ្វីជាការទ្រទ្រង់ ?

-ឆ្លើយ : ការកម្ចាត់នូវកិលេស ដែលកិលេសនោះធ្វើឱ្យសត្វធ្លាក់ក្នុងអបាយភូមិ និងឱ្យស្ថិតនៅក្នុងទុក្ខនៃវដ្តៈ ។

ក្នុងសេចក្តីដូចដែលសម្តែងហើយនេះ អរិយមគ្គ និង



ព្រះនិព្វាន ឈ្មោះថា **ធម្ម** ព្រោះអរិយមគ្គ មានព្រះនិព្វានជាអារម្មណ៍ ក្នុងការកម្ចាត់បង់នូវកិលេស ។

ធម៌ ៥ យ៉ាង គឺមគ្គ ៤ និងព្រះនិព្វាន ១ នេះ ឈ្មោះថា **ធម្ម** ជាសភាវៈទ្រទ្រង់ដោយត្រង់ ។

ព្រះបរិយត្តិធម៌ជាហេតុនៃការទ្រទ្រង់ ឯអរិយផល ៤ ជាផលនៃការទ្រទ្រង់ ។ ធម៌ទាំង ៥ យ៉ាង គឺផល ៤ និងព្រះបរិយត្តិធម៌ ១ នេះ ឈ្មោះថា **ធម្ម** សភាវៈទ្រទ្រង់ដោយបរិយាយ ។

ម្យ៉ាងទៀត **ធម្ម** គឺ សភាវៈដែលបុគ្គលគប្បីទ្រទ្រង់ទុកពោលគឺគួរដល់ការទ្រទ្រង់ ។

-សួរ : ព្រោះហេតុអ្វីទើបគួរដល់ការទ្រទ្រង់ ?

-ឆ្លើយ : ព្រោះ **ធម្ម** ជាសភាវៈរំដោះ នូវអ្នកដែលតាំងនៅក្នុងទុក្ខ ឱ្យផុតចាកទុក្ខ បានដល់ផលសុខ និងនិព្វានសុខ ។

-សួរ : ធម៌នោះជាអ្វី ?

-ឆ្លើយ :គឺមគ្គ៤ ផល៤ ព្រះនិព្វាន១ និងព្រះបរិយត្តិធម៌១។

ពួកធម៌ខ្លះ (មគ្គ ៤) បុគ្គលគប្បីទ្រទ្រង់ដោយការអប់រំចិត្ត ពួកធម៌ខ្លះ (ព្រះនិព្វាន) បុគ្គលគប្បីទ្រទ្រង់ដោយការធ្វើឱ្យជាក់ច្បាស់ ពួកធម៌ខ្លះ (ផល ៤) បុគ្គលគប្បីទ្រទ្រង់ដោយការនៅជាសុខក្នុងអត្តភាពបច្ចុប្បន្ន ពួកធម៌ខ្លះ (ព្រះបរិយត្តិធម៌) បុគ្គល

ទ្រទ្រង់ដោយការសិក្សារៀនសូត្រចាំទុក ។

បដិបត្តិធម៌ ជាបដិបទាដើម (បុព្វភាគ ) នៃមគ្គ ចាត់ចូលក្នុងមគ្គ ដូចបុព្វចេតនានៃទាន ដែលរាប់ចូលក្នុងទាន ដូច្នោះឯង ។

៤៤-ព្រះសង្ឃ គឺពួកជនអ្នកបដិបត្តិតាមមគ្គ និងអ្នកសម្រេចផល ដែលអ្នកមានសទ្ធាទុកចិត្តថា ជាសង្គមដ៏ប្រសើរ ឬជាពួកជនដ៏ប្រសើរ ដែលគួរសាងឱ្យកើតមានឡើង និងដែលខ្លួនមានចំណែករួមផងបានដែរ ដោយការបដិបត្តិតាមមគ្គ និងការសម្រេចផលនោះ ។ ផ្តើមដោយការបដិបត្តិជាលក្ខណៈគំរូ តាមលក្ខណៈវិនិច្ឆ័យធម៌វិន័យ ប្រាកដខាងក្រៅ គឺ វិន័យ ការព្រមព្រៀង និងភាពជាកល្យាណមិត្តដល់គ្នា ។ ការមានកល្យាណមិត្តក្តី ការមាននូវយោនិសោមនសិការក្តី ការបដិបត្តិតាមមគ្គក្តី រមែងចម្រើនរុងរឿងបានផលល្អ គឺស្ថិតនៅក្នុងសង្គមដែលប្រព្រឹត្តទៅតាមគតិនៃសង្ឃនេះឯង ។

៤៥-អរិយសច្ចៈ ៤ គឺ

(១)-**ទុក្ខសច្ច** គឺបញ្ហាផ្សេងៗ របស់មនុស្សព្រមទាំងសព្វសត្វទាំងអស់ ជាតួបៀតបៀនដុតរោល ឱ្យដល់ជីវិតសព្វសត្វគ្រប់



ទីកន្លែង ។

ទុក្ខ កើតឡើងដល់អ្នកណា ពេលណា ក៏ជាចំណុចដែលច្បាស់ប្រាកដដល់បុគ្គលនោះ ពេលនោះ តាមសញ្ញាសំគាល់របស់ខ្លួនរៀងៗខ្លួន ។ តាមពិតជីវិតមានទុក្ខជាធម្មតា បើលើកយកមកសម្តែងពេលណា មនុស្សយើងក៏ស្តាប់បានពេលនោះដែរ គ្រាន់តែការស្តាប់បាននោះទៅតាមបញ្ញា ដែលមានលំដាប់ថ្នាក់ផ្សេងគ្នាប៉ុណ្ណោះ ។ ទុក្ខជាសភាវៈដែលគួរខ្លាច គួររង្កៀស និងគួរឱ្យស្អុតចិត្ត ដល់មនុស្សចំនួនច្រើន គឺថាគ្រប់គ្នាខំប្រឹងគេចចេញពីទុក្ខមិនត្រូវការឱ្យខ្លួនឯងមានទុក្ខឡើយ ។

ព្រះសម្មាសម្ពុទ្ធ សម្តែងអរិយសច្ចធម៌ ដែលផ្តើមអំពីទុក្ខសច្ចៈជាដំបូង ព្រោះជាសច្ចៈដែលមានក្នុងមនុស្សសត្វទាំងអស់គ្នា គ្រប់គ្នាស្តាប់ហើយ រមែងយល់ចូលចិត្តថា ជាការពិតហើយយកចិត្តទុកដាក់ ស្រាវជ្រាវរាវរកហេតុតាមក្រោយ ដើម្បីដោះស្រាយនូវបញ្ហា ។

ព្រះអង្គទ្រង់សម្តែងអំពីទុក្ខ មិនមែនដើម្បីឱ្យគ្រប់គ្នាកើតទុក្ខក្តៅក្រហាយចិត្តនោះទេ តាមពិត នេះជាចំណុចចាប់ផ្តើមដើម្បីនឹងរំលត់ទុក្ខព្រោះការរំលត់ទុក្ខនោះ មិនមែនធ្វើបានដោយការមិនមើលទុក្ខឱ្យឃើញច្បាស់ ឬដោយការខំរត់ចេញពីទុក្ខ ទាំង

ងងឹតមិនយល់អ្វីនោះឡើយ ។

ការដែលអាចរំលត់ទុក្ខបាន គឺចម្រើនបញ្ញាឱ្យស្គាល់ទុក្ខ កំណត់ដឹងទុក្ខ ទទួលដឹងទុក្ខ ។ ការទទួលដឹងទុក្ខ មិនមែនបានសេចក្តីថា ចូលទៅរែកពុនទុក្ខ ទូលទុក្ខ ឬធ្វើខ្លួនឱ្យកើតទុក្ខនោះទេ តែនេះជាការដឹងទាន់ ធ្វើបរិញ្ញាកិច្ចដោយបញ្ញា គឺកំណត់ដឹងទុក្ខ ទើបអាចរំលត់ទុក្ខបាន ។ ព្រះអង្គទ្រង់ប្រកាសសម្តែងនូវសច្ចៈទី ១ គឺដើម្បីឱ្យពុទ្ធបរិស័ទបានយល់ដឹងចំពោះសភាវទុក្ខ (ជាតិ ជរា ព្យាធិ មរណៈ ) គឺឱ្យដឹងថា សភាវទុក្ខនោះវាជាអ្វីពិតប្រាកដ នៅត្រង់ណា មានព្រំដែនត្រឹមណា ។ កាលដែលបានយល់ដឹងច្បាស់ចំពោះទុក្ខយ៉ាងនេះ ប្រៀបដូចលោកគ្រូពេទ្យ ត្រួតពិនិត្យអាការ-រោគ បានដឹងថាជារោគអ្វី គឺដឹងសភាពពិតនៃរោគ ដូច្នោះឯង ។

ការយល់ដឹងច្បាស់លាស់ចំពោះទុក្ខ គឺជាការអស់កិច្ចនាទី ដែលត្រូវធ្វើចំពោះទុក្ខ ព្រោះបញ្ញាមិនមានតួនាទីលះបង់ទុក្ខ កម្ចាត់ទុក្ខនោះឡើយ ។ តាមពិតបញ្ញាត្រូវលះបង់នូវហេតុនៃសេចក្តីទុក្ខ ។

អង្គធម៌បរមត្ថដែលជា **ទុក្ខសច្ច** គឺលោកិយចិត្ត ៨១ ដួង និងចេតសិក ៥១ (វៀរលោភចេតសិក ដែលជាសមុទយសច្ចៈ ) ព្រមទាំងរូប ២៨ ផង ។



ចែកជា តិកមាតិកា នៃអភិធម្មសង្គណី គឺទុក្ខសច្ចៈ ដែលជាកុសលបានដល់លោកិយកុសលចិត្ត ១៧ ដួង ( ៨ + ៥ + ៤ ) ចេតសិក ៣៨ ( ១៣ + ២៥ ) ។ ទុក្ខសច្ចៈ ដែលជាអកុសលបានដល់អកុសលចិត្ត ១២ ដួង ( ៨ + ២ + ២ ) ចេតសិកសម្បយុត្ត ២៦ ( ១៣ + ១៣ វៀរលោភៈ ) ។

ទុក្ខសច្ចៈ ដែលជាអព្យាក្រឹតបានដល់ លោកិយវិបាកចិត្ត ៣២ ដួង ( ២៣ + ៩ ) កិរិយាចិត្ត ២០ ( ១១ + ៩ ) ចេតសិក ៣៥ (១៣ + ២២ វៀរវិរតិ ៣ ) រូប ២៨ ។

សារៈសំខាន់នៃការសិក្សាអរិយសច្ចទី ១ នេះ គឺ ព្រមទទួលការពិត ដែលទាក់ទងនឹងទុក្ខ តាមដែលទុក្ខនោះប្រព្រឹត្តទៅ រួចហើយសម្លឹងមើលឱ្យស្គាល់ជីវិតទៅតាមសេចក្តីពិត ។

គួរកំណត់នូវព្រំដែននៃទុក្ខសច្ចៈយ៉ាងនេះ គឺ

ជាឥន្ទ្រិយព័ទ្ធ គឺជាប់ទាក់ទងដោយឥន្ទ្រិយ ជាប់ទាក់ទងនឹងជីវិត ជាបញ្ហានៃសត្វលោក ។ ទុក្ខសច្ចៈ មិនរួមដោយអនិន្ទ្រិយព័ទ្ធឡើយ មិនមែនសុទ្ធតែជាទុក្ខ ក្នុងសេចក្តីដែលថា សង្ខារទាំងឡាយទាំងពួងជាទុក្ខ ( **សព្វេ សង្ខារា ទុក្ខា** ) ឬរបស់ណាមិនទៀង របស់នោះជាទុក្ខ ( **យទនិច្ចំ តំ ទុក្ខំ** ) នោះឡើយ ព្រោះទុក្ខក្នុងត្រៃលក្ខណ៍មានសេចក្តីទូលំទូលាយ គ្រប់

សង្ខារទាំងអស់ ។

-ជាទុក្ខដែលកើតពីកម្មក្កិលេស គឺជាបញ្ហារបស់មនុស្សសត្វទាំងអស់ បានដល់ទុក្ខដែលកើតពីតណ្ហា ។ (**កម្មក្កិលេស** = កិលេសដែលធ្វើឱ្យកើតកម្ម កម្មគឺអភិសង្ខារ ) ។

-ជាទុក្ខទាក់ទងនឹងបរិញ្ញាកិច្ច គឺកិច្ចកំណត់ដឹង ជាកិច្ចដែលពុទ្ធបរិស័ទត្រូវធ្វើចំពោះទុក្ខក្នុងអរិយសច្ចៈ គឺជាការយល់ច្បាស់ចំពោះបញ្ហាក្នុងជីវិត ។

-សង្កត់សេចក្ដីក្នុងផ្នែកដែលជាទីតាំងនៃទុក្ខ ឬជាទីទទួលរ៉ាប់រងនូវទុក្ខ មិនសំដៅសេចក្ដីត្រង់ដែលថា មានការកើតឡើងហើយ រលត់ទៅវិញ ដែលជាទុក្ខលក្ខណៈនោះឡើយ ។

(២)-**សមុទយសច្ច** គឺហេតុនៃទុក្ខ ឬហេតុនៃបញ្ហា ។

ការរំលត់ទុក្ខនោះ អាចសម្រេចបាន ដោយកម្ចាត់ហេតុរបស់វា ដូច្នេះកាលបើកំណត់បានហើយថា ទុក្ខ ឬបញ្ហារបស់ខ្លួនគឺជាអ្វី នៅត្រង់ណា ក៏ស្រាវជ្រាវរកហេតុតទៅ ដើម្បីនឹងបានធ្វើ **បហានកិច្ច** គឺកិច្ចលះបង់ ឬកម្ចាត់បង់ ។

យ៉ាងណាក៏ដោយ កាលដែលស្រាវជ្រាវរកហេតុនោះ មនុស្សយើងច្រើនតែគេចចេញពីសេចក្ដីពិត ចូលចិត្តសម្លឹងមើលទៅខាងក្រៅ ឬមើលឆ្ងាយទៅផុតពីខ្លួន ផុតពីកន្លែងដែលខ្លួនរស់



នៅក្នុងបច្ចុប្បន្ន ទើបបានចេះតែឃើញខុសថា អ្វីៗជាខាងក្រៅនោះៗ បណ្ដាលនូវទុក្ខទោសឱ្យដល់ខ្លួន ឬបើថាមានការទាក់ទងនឹងខ្លួនឯង ក៏យល់ថា ជារឿងអតីត ឆ្ងាយដាច់ផុតទៅហើយ គឺផុតពីការដែលខ្លួនត្រូវទទួលខុសត្រូវ ។

អ្វីៗដែលមនុស្សយើងច្រើនតែចាត់ថា ជាហេតុនោះ ក៏បានប្រាកដមកជាលទ្ធិដែលយល់ខុស ៣ ប្រភេទ គឺ

ប្រភេទទី ១ : **បុព្វេកតវាទ** លទ្ធិកម្មចាស់ គឺប្រកាន់ថាសុខទុក្ខទាំងពួងដែលជួបប្រសព្វក្នុងបច្ចុប្បន្ននេះ ព្រោះកម្មដែលបានធ្វើហើយ ក្នុងកាលមុន ។

ប្រភេទទី ២ : **ឥស្សរនិម្មានវាទ** លទ្ធិជាម្ចាស់ គឺប្រកាន់ថា សុខទុក្ខទាំងពួងដែលជួបប្រសព្វក្នុងបច្ចុប្បន្ននេះ ព្រោះការបណ្ដាលឡើងដោយព្រះអាទិទេព ឬទេវតាដែលជាធំ ។

ប្រភេទទី ៣ : **អហេតុកវាទ** ជាលទ្ធិប្រកាន់ជោគជតាឃើញថាការសោយអារម្មណ៍ណា សុខក្ដី ទុក្ខក្ដី មិនមានអ្វីបណ្ដាលឱ្យកើតឡើងទេ គឺថាកើតឡើងឯងៗដោយអត់ហេតុ អត់បច្ច័យ ។

ព្រះពុទ្ធសាសនា បដិសេធនូវលទ្ធិទាំង ៣ នេះ ព្រោះទំនាស់នឹងច្បាប់ធម្មជាតិ ឬច្បាប់ហេតុផល ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឱ្យរកហេតុរបស់ទុក្ខ តាមច្បាប់ធម្មជាតិរបស់វា ដោយ

មើលហេតុ មើលបច្ច័យ ចាប់ផ្តើមតាំងតែពីក្នុងខ្លួនឯង បានដល់កម្ម គឺការធ្វើ ការនិយាយ ការគិតល្អ ឬអាក្រក់ ដែលបានធ្វើហើយ ឬដែលកំពុងធ្វើ ម្យ៉ាងទៀតអ្វីដែលសន្សំទុក ជាលក្ខណៈឧបនិស្ស័យ រហូតដល់ការតាំងចិត្ត ប្រាថ្នាក្នុងរបស់ទាំងឡាយ និងម្យ៉ាងទៀត នោះ គឺការមានទំនាក់ទំនងជាមួយអ្វីៗជុំវិញខ្លួន បានត្រឹមត្រូវ ឬ ភ្លាំងភ្លាត់ ។

ប្រភព ឬឫសគល់ជាទីតាំងនៃទុក្ខ ស្ថិតនៅក្នុងសភាពដ៏មានជម្រៅ គឺតណ្ហា ដែលជាតួត្រូវការប្រាថ្នាចង់បាន ធ្វើឱ្យមានភាពទុកចិត្ត ស្និទ្ធស្នាលនៅក្នុងលោក មានការរៀបចំខ្លួនទៅតាមមនោសញ្ចេតនា មានការសម្តែងចេញដោយសម្ពន្ធភាពជាមួយជីវិតនិងសង្ខារលោក មានការលិចចុះក្នុងលោក ប្រព្រឹត្តទៅដោយការមិនដឹងតាមសេចក្តីពិត មានតែនាំឱ្យស្រឡាញ់ស្អប់ គាប់ទាស់ជាដើម ។ កិលេសទាំងឡាយដែលគ្រប់គ្រងក្នុងជីវិត ដូចជាការស្រឡាញ់ស្អប់ ការភ័យខ្លាច ការច្រណែន គំនុំគុំកួន ។ល។ សុទ្ធតែមានការទាក់ទងតមកអំពីតណ្ហាទាំងអស់ ។

**តណ្ហា** មាន ៣ យ៉ាង គឺ

-**កាមតណ្ហា** : ចំណង់ក្នុងកាម បានដល់ចង់បាន ចង់យក និងចង់សេពសោយ ។



-**ភវតណ្ហា** : ចំណង់ក្នុងភព បានដល់ចង់រស់ ចង់ស្ថិតនៅ និងចង់មានជីវិតរស់នៅរហូត ។

-**វិភវតណ្ហា** : ចំណង់ក្នុងការអស់ភព បានដល់សេចក្តីប្រាថ្នានូវភាវៈសោះសូន្យ តណ្ហានេះប្រកបដោយឧច្ឆេទទិដ្ឋិ ។

ព្រះអង្គទ្រង់ត្រាស់សម្តែងនូវក្រសែនៃទុក្ខ ប្រព្រឹត្តទៅជាបដិច្ចសមុប្បាទធម៌ ជាជម្រៅនៃជីវិតដែលមានអវិជ្ជាជាមូលនៃតណ្ហា ជាទីហូរមកនៃបញ្ហា កើតបានជាទុក្ខក្នុងសង្សារវដ្ត ។

(៣)-**និរោធសច្ច** គឺទីរំលត់ទុក្ខ ឬការអស់បញ្ហា ។

នៅពេលដែលពោលអំពីទុក្ខ ឬបញ្ហា ព្រមទាំងហេតុដែលជាសភាវៈប្រព្រឹត្តទៅក្នុងជាតិ ជរា ព្យាធិ មរណៈ និងការលំបាក-លំបិន ទុក្ខសោកផ្សេងៗហើយនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រោះព្រំដួងចិត្តពុទ្ធបរិស័ទឱ្យកើតការស្រាលចិត្តឡើង ធ្វើចិត្តឱ្យមានកម្លាំងព្រោះមិនបាត់បង់នូវទីពឹង ដោយព្រះអង្គទ្រង់ត្រាស់សម្តែងនូវអរិយសច្ចទី ៣ គឺ និរោធសច្ចៈ ។

ជាការសម្តែងឱ្យឃើញថា ទុក្ខដែលប្រព្រឹត្តទៅនោះអាចរំលត់ បញ្ហាទាំងអស់អាចដោះស្រាយបាន ច្រកចេញដែលជាផ្លូវរួចផុត គឺពិតជាមាន ព្រោះតួហេតុនៃសេចក្តីទុក្ខនោះ ជាសភាវៈដែលអាចកម្ចាត់បង់ឱ្យអស់ទៅបាន ។ ទុក្ខប្រព្រឹត្តទៅបាន ព្រោះ

អាស្រ័យហេតុ កាលបើកម្ចាត់ហេតុហើយ ទុក្ខដែលជាផលក៏នឹងអស់ទៅផងដែរ ។ នៅពេលណាដែលទុក្ខរលត់អស់ បញ្ហាមិនមាន នៅពេលនោះ សុខព្រោះអស់បញ្ហា ឬសុខព្រោះប្រាសចាកទុក្ខក៏ប្រាកដឡើងឯង ។

ដោយន័យនេះ និរោធសច្ចៈ ទើបចូលមកក្នុងលំដាប់ទី ៣ ទាំងដោយលំដាប់ធម្មតានៃក្បួនរបស់ធម៌ និងទាំងដោយលំដាប់ដ៏សមរម្យ ក្នុងការសម្តែងរបស់ព្រះសម្មាសម្ពុទ្ធជួយឱ្យអ្នកស្តាប់បានយល់ និងបានផលល្អ ។

ក្នុងបិដកលេខ ៥២ ទំព័រ ១៣០ នៅក្នុង **ពាហិយសូត្រ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា **ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ** កាលឃើញរូប ត្រឹមតែឃើញ **សុតេ សុតមត្តំ ភវិស្សតិ** កាលស្តាប់ឮសំឡេង ត្រឹមតែស្តាប់ឮ **មុតេ មុតមត្តំ ភវិស្សតិ** កាលប៉ះពាល់ក្លិន រស ផោដ្ឋព្វៈ ត្រឹមតែប៉ះពាល់ **វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតីតិ** កាលដឹងច្បាស់ធម្មារម្មណ៍ ត្រឹមតែដឹងច្បាស់ ។ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។

ម្នាលពាហិយៈ ក្នុងកាលណាដែលអ្នកឃើញ ត្រឹមតែឃើញ ឮត្រឹមតែឮ ប៉ះពាល់ត្រឹមតែប៉ះពាល់ ដឹងច្បាស់ត្រឹមតែដឹងច្បាស់



**តតោ ត្វំ ពាហិយ នត្ថិ** ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមាន ។

**យតោ ត្វំ ពាហិយ នេវត្ថិ** ម្នាលពាហិយៈ ក្នុងកាលណាអ្នកមិនមាន **តតោ ត្វំ ពាហិយ នេវិធ** ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមានក្នុងលោកនេះ **នហុរំ** រមែងមិនមានក្នុងលោកខាងមុខ **ន ឧភយមន្តរេ** រមែងមិនមានក្នុងរវាងលោកទាំងពីរ **ឯសេវន្តោ ទុក្ខស្សាតិ** នេះឯងជាទីបំផុតនៃទុក្ខ ។

(៤)_**មគ្គសច្ច** គឺផ្លូវរំលត់ទុក្ខ ។

មគ្គសច្ចៈ គឺជាផ្លូវរំលត់ទុក្ខ ឬវិធីបដិបត្តិដើម្បីកម្ចាត់ហេតុនៃបញ្ហា ។ មគ្គសច្ចៈរមែងសមគួរចូលមកក្នុងលំដាប់ ចុងក្រោយទៅតាមទំនាក់ទំនងក្រុមធម៌ជាមួយគ្នា ព្រោះហេតុបានដឹងទាំងទុក្ខ ទាំងហេតុនៃទុក្ខ ទាំងទិសដៅដែលជាការអស់ទៅនៃទុក្ខ ដោយចំពោះគឺ កាលបើដឹងទិសដៅដែលនឹងទៅឱ្យដល់ ថាបានដល់អ្វី អាចប្រព្រឹត្តទៅបានយ៉ាងណា ទើបការបដិបត្តិដើម្បីឱ្យបានដល់ទិសដៅនោះ រមែងចម្រើនឡើង ។

ម្យ៉ាងទៀត ពោលដោយលំដាប់នៃទេសនា តាមធម្មតានោះ ការបដិបត្តិជាកិច្ចដែលត្រូវអាស្រ័យកម្លាំងខ្លាំងក្លា បើអ្នកបដិបត្តិ មិនឃើញគុណ ឬប្រយោជន៍នៃអ្វីដែលជាផលសម្រេចទេ

ក៏រមែងមិនមានកម្លាំងចិត្តនឹងបដិបត្តិ អាចកើតការរួញរា សង្ស័យ មិនព្រមបដិបត្តិ ប្រសិនបើបដិបត្តិ ក៏ធ្វើទៅទាំងបង្ខំ មិនអាចប្រព្រឹត្តទៅបានដោយល្អឡើយ ។ កាលដែលព្រះអង្គទ្រង់ត្រាស់សម្តែងនិរោធសច្ចៈ មុនមគ្គសច្ចៈ ក៏ព្រោះហេតុផលដូច្នេះឯង ។

កាលសម្លឹងមើលហេតុនៃទុក្ខ មនុស្សយើងចូលចិត្តសម្លឹងមើល ក្នុងភាពរសាត់អណ្តែតទៅខាងក្រៅ ឬមើលយ៉ាងឆ្ងាយផុតពីការទទួលខុសត្រូវរបស់ខ្លួន ដូចជា តាមព្រហ្មលិខិតជាដើម ។ ក៏ដូចគ្នាដែរ កាលដែលដោះស្រាយបញ្ហាទុក្ខលំបាក មនុស្សយើងក៏រមែងចូលចិត្តសម្លឹងមើលទៅខាងក្រៅដូចគ្នាដែរ គឺសម្លឹងរកការឃុំគ្រង ឱ្យខ្លួនផុតពីភារៈ ឬសូមឱ្យជួយធ្វើការដោះស្រាយជំនួសខ្លួនជាដើម ។

ពោលដោយលក្ខណៈ សភាពទាំងពីរនេះ ស្រដៀងគ្នា គឺជាការគេចមុខចេញពីសេចក្តីពិត មិនក្លាហានសម្លឹងមើលទុក្ខ ព្រមទាំងគេចចេញពីការទទួលខុសត្រូវ របៀបដូចមនុស្សដែលគេចពីភយន្តរាយ ដោយគ្រាន់តែបិទភ្នែកប៉ុណ្ណោះ គឺមិនឱ្យឃើញភ័យវិបត្តិនោះ ហើយនឹកថាបានផុតពីភ័យ ទាំងដែលខ្លួនឯងត្រូវលែងចោលទៅក្នុងវិបត្តិភយន្តរាយនោះឯង ។ របៀបដូចនេះហើយ ទើបធ្វើឱ្យកើតឧបនិស្ស័យ សង្ឃឹមបច្ច័យខាងក្រៅដូចជា



ការអង្វរករ ដល់វត្ថុស័ក្តិសិទ្ធិ បួងសួង សែនព្រេន រង់ចាំការបណ្តាលពីអាទិទេព ឬរង់ចាំជោគជតាជាដើម ។

៤៦-ត្រៃសរណគមន៍ :

**ព្រះពុទ្ធជាទីរលឹក** ធ្វើឱ្យមានភាពមាំទាំក្នុងចិត្តថា មនុស្ស គឺយើងគ្រប់គ្នានេះ មានសតិបញ្ញា មានសមត្ថភាព ដែលអាចអប់រំឱ្យចម្រើនបរិបូណ៌បាន អាចដឹងអរិយសច្ចធម៌ សម្រេចនូវការរួចផុត ជាឥស្សរៈ ប្រាសចាកទុក្ខ អណ្តែតចាកលោកធម៌ និងមានសភាពប្រណិត ខ្ពង់ខ្ពស់ សូម្បីតែទេវតា ឬព្រហ្មក៏គោរពបូជាដែរ ដូចមានព្រះបរមសាស្តាជាអង្គគំរូស្រាប់ ។ មនុស្សទាំងឡាយដែលមានការពឹងពាក់ សង្ឃឹមទេវតា និងវត្ថុស័ក្តិសិទ្ធិនោះ បើចេះហ្វឹកហាត់អប់រំខ្លួនឱ្យបានល្អហើយ ក៏មិនមានសេចក្តីបរិសុទ្ធណា ដែលទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងអស់នោះ អាចធ្វើឱ្យបានដូចជាអំពើល្អ ឬសតិបញ្ញា របស់មនុស្សខ្លួនឯងឡើយ ។

**ព្រះធម៌ជាទីរលឹក** ធ្វើឱ្យមានភាពមាំទាំក្នុងចិត្តថា សេចក្តីពិត ឬសច្ចធម៌ ជាសភាវៈដែលស្ថិតនៅជាធម្មតា អ្វីៗទាំងអស់ប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។ បើបានចេះដឹង និងយល់នូវអ្វីៗទាំងអស់ ដែលប្រព្រឹត្តទៅតាមសេចក្តីពិត ហើយនាំយកការចេះ

ដឹងមកប្រើជាប្រយោជន៍ បដិបត្តិចំពោះសភាវៈទាំងឡាយ ដោយការចេះដឹង មានការដឹងទាន់ និងធ្វើការត្រង់តួហេតុ តួបច្ច័យដូច្នោះ ក៏រមែងដោះស្រាយបញ្ហាបានល្អជាទីបំផុត ចូលដល់សច្ចធម៌ មានជីវិតដ៏ប្រសើរក្រៃលែង ។

**ព្រះសង្ឃជាទីរលឹក** ធ្វើឱ្យមានភាពមាំទាំក្នុងចិត្តថា សង្គមល្អមានធម៌ជាឫសគល់ ប្រកបដោយសមាជិកដែលមានចិត្តប្រាសចាក ឬឃ្លាតឆ្ងាយពីទុក្ខ ជាឥស្សរៈ មានសេរីភាព សូម្បីមានការចម្រើននូវសតិបញ្ញាក្នុងលំដាប់ផ្សេងៗគ្នាក៏ដោយ ក៏នៅរួមគ្នាបានដែរ មានសមភាព គឺភាពស្មើគ្នាដោយធម៌ ។ មនុស្សគ្រប់គ្នាអាចរស់នៅរួមគ្នា សាងសង្គមដូចនេះបាន ដោយការដឹងធម៌ និងការបដិបត្តិតាមធម៌ ។

បើមិនមានភាពមាំទាំក្នុងព្រះរតនត្រ័យទេ រមែងត្រូវពឹងបច្ច័យខាងក្រៅ ដូចជាការសែនព្រេន អង្វរករដល់វត្ថុស័ក្តិសិទ្ធិបន់ស្រន់ ទេវតាជាដើមតទៅ តែបើមាំទាំក្នុងព្រះរតនត្រ័យវិញ ក៏រមែងរៀនដឹងនូវគោលការណ៍ដោះស្រាយបញ្ហាទុក្ខ តាមគោលអរិយសច្ច និងបដិបត្តិតាមវិធីការនៃមគ្គក្នុងព្រះពុទ្ធសាសនា ។

បុគ្គលដែលមានសទ្ធាមាំទាំ ជឿស៊ប់ក្នុងព្រះរតនត្រ័យ ជាជំនឿប្រកបដោយបញ្ញា ទោះជាមានសំឡេងបបួលពីខាងក្រៅ ឬ



សូម្បីតែការប្រែប្រួលនៃជីវិត ដែលហៅថា រលកនៃលោកធម៌ ( សមុទ្រតែងមានរលក ជីវិតតែងមានការប្រែប្រួល ) ឬទៅតាមពាក្យអ្នកស្រុក ដែលនាំគ្នានិយាយថា « គ្រោះកាច គ្រោះជា » ជាដើម ។ ក៏មិនអាចធ្វើឱ្យញាប់ញ័របាន ។ ចិត្តរបស់គេដូចជាមនុស្សដែលមានសុខភាពល្អ មាំមួន ជួយខ្លួនឯងបានគ្រប់ពេលវេលា មិនចាំបាច់សង្ឃឹមការបណ្តាលគ្រោះជោគពីខាងក្រៅអ្វីឡើយ មានតែការទទួលផលដែលសម្រេចអំពីកម្ម ដែលបានធ្វើហើយ ដោយសេចក្តីព្យាយាមរបស់ខ្លួនតែប៉ុណ្ណោះ ។

បុគ្គលដែលមានសទ្ធាដូចពោលមកនេះ រមែងមានបញ្ញាចម្រើនដល់ថ្នាក់យល់ដឹងអំពីគោលធម៌ សម្រាប់ដោះស្រាយបញ្ហាក្នុងដំណើរចូលទៅរកទីរំលត់ទុក្ខ តាមហេតុផលនៃអរិយសច្ចធម៌យ៉ាងច្បាស់លាស់ ហើយក៏មានដំណើរបដិបត្តិកម្ចាត់ទុក្ខ តាមមាគ៌ាដែលជាអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ។

៤៧-និព្វានជាទុក្ខនិរោធ

និព្វានជាសច្ចៈឃើញបានដោយក្រ ។ ការសម្តែងអំពីព្រះនិព្វានមានច្រើនបែប :

(១) **បែបបដិសេធ** គឺមានន័យបញ្ជាក់ដល់ការលះ ការកម្ចាត់ ការដកចោល នូវភាវៈដែលមិនល្អ និងមិនជាប្រយោជន៍ផ្សេងៗ ដែលជាចំណែកនៃវដ្តៈ ។

ក្នុងបិដកលេខ ៣៦ ទំព័រ ១០៨ ព្រះសារីបុត្តឆ្លើយតបនិព្វានបញ្ហា ចំពោះជម្ពុខាទកបរិព្វាជក ថា :

**យោ ខោ អាវុសោ រាគក្ខយោ ទោសក្ខយោ**

**មោហក្ខយោ ឥទំ វុច្ចតិ និព្វានន្តិ ។**

ម្នាលអាវុសោ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ នេះហៅថា ព្រះនិព្វាន ។

ក្នុងបិដកលេខ ៣១ ទំព័រ ២៥៩ ព្រះមុសិលៈ ដ៏មានអាយុបានឆ្លើយតបបញ្ហារបស់ព្រះបវិដ្ឋៈដ៏មានអាយុថា :

ម្នាលអាវុសោ បវិដ្ឋៈ វៀរចាកការជឿ វៀរចាកការពេញចិត្ត វៀរចាកការស្តាប់ឮតៗគ្នា វៀរចាកការត្រិះរិះ ដោយអាការៈ វៀរចាកការយល់ឃើញ តាមការខិតខំពិនិត្យ ខ្ញុំព្រះករុណាក៏ដឹងយ៉ាងនោះ ឃើញយ៉ាងនោះថា **ភវនិរោធោ និព្វានន្តិ** ការរលត់ភពជាព្រះនិព្វាន ។

ក្នុងបិដកលេខ ៣៤ ទំព័រ ៧៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលរាធៈ អ្នកទាំងឡាយចូរកម្ចាយចោល ឈូសចោល



កម្ចាត់ចោលនូវរូប នូវវេទនា នូវសញ្ញា នូវសង្ខារទាំងឡាយ នូវវិញ្ញាណ ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីការអស់ទៅនៃតណ្ហា យ៉ាងនោះឯង ។

**តណ្ហក្ខយោ ហិ រាធ និព្វានន្តិ** ម្នាលរាធៈ ការអស់ទៅនៃតណ្ហា ឈ្មោះថា ព្រះនិព្វាន ។

ក្នុងបិដកលេខ ៣៥ ទំព័រ ៩៣ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវផស្សាយតនៈ ទាំង ៦ ទេ ភិក្ខុនោះឈ្មោះថា មិនបានប្រព្រឹត្តព្រហ្មចរិយៈទេ ភិក្ខុនោះឈ្មោះថាឆ្ងាយអំពីធម្មវិន័យនេះ។

កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គវិនាសចាកធម្មវិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់ដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវផស្សាយតនៈទាំង ៦ នេះឡើយ ។

ព្រះពុទ្ធ-ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញនូវចក្ខុថា នោះជារបស់អញ នោះជាអញ នោះជា

ខ្លួនរបស់អញ ដូច្នោះឬ ។

ភិក្ខុ-មិនមែនឃើញដូច្នោះទេព្រះអង្គ ។

ព្រះពុទ្ធ-ម្នាលភិក្ខុប្រពៃហើយ ម្នាលភិក្ខុក្នុងរឿងនេះ អ្នកនឹងបានឃើញនូវចក្ខុនោះ ដោយបញ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នោះមិនមែនរបស់អញ នោះមិនមែនជាអញ នោះមិនមែនជាខ្លួនរបស់អញឡើយ **ឯសេវន្តោ ទុក្ខស្ស** នោះឯងជាទីបំផុតនៃទុក្ខ ។ល។ ( សោតៈជាដើម ព្រះអង្គសម្ដែងមានន័យដូចគ្នា ) ។

មានពាក្យហៅ ព្រះនិព្វាន ផ្ទុយគ្នាអំពីវដ្ដៈដោយចំតែម្ដងដូចជាមាននៅក្នុងព្រះសូត្រខាងក្រោមនេះជាដើម ។

ក្នុងបិដកលេខ ២១ ទំព័រ ១២៩ នៅក្នុង **បាសរាសិសូត្រ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ២ ប្រការ គឺស្វែងរកមិនប្រសើរ ១ និងការស្វែងរកដ៏ប្រសើរ ១ ។

ការស្វែងរកមិនប្រសើរតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតាហើយ នៅស្វែងរករបស់ដែលមានជាតិជាធម្មតាថែមទៀត ។

ជរាជាធម្មតា ។ ព្យាធិជាធម្មតា ។ មរណៈជាធម្មតា ។ សេចក្ដីសោកជាធម្មតា ។ សេចក្ដីសៅហ្មងជាធម្មតា ។ (ជរាធម៌



ជាដើម ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងដូចជាតិធម៌ដែរ ) ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកមិនប្រសើរ។

ក្នុងទំព័រ ១៣២ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឯការស្វែងរកដ៏ប្រសើរតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួក ១ ក្នុងលោកនេះ ខ្លួនឯងមានជាតិជាធម្មតា ដឹងច្បាស់នូវទោសក្នុងជាតិធម៌ ហើយស្វែងរកនូវព្រះនិព្វាន ដែលមិនមានជាតិ មិនមានធម៌ដទៃស្មើ ជាទីក្សេមចាកយោគៈ ។ល។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្វែងរកដ៏ប្រសើរ ។

ក្នុងបិដកលេខ ៣៦ ទំព័រ ៣៤៩ **អសង្ខតវគ្គ** ព្រះដ៏មាន-ព្រះភាគទ្រង់សម្ដែងនូវព្រះនិព្វាន ថាជាអសង្ខតធម៌ រួចហើយព្រះអង្គទ្រង់សម្ដែងអំពីផ្លូវទៅកាន់អសង្ខតធម៌នោះ( អសង្ខតគាមិ-មគ្គ ) មានកាយគតាសតិ រហូតដល់ពោធិបក្ខិយធម៌ទាំង ៧ ពួក ។

នៅក្នុងអសង្ខតវគ្គនេះ ព្រះអង្គទ្រង់សម្ដែងឈ្មោះនៃព្រះនិព្វានច្រើន មានជាអាទិ៍គឺ

-**អនតធម៌** = ធម៌មិនបង្អោនទៅ , មិនត្រេកអរដោយកិលេសតណ្ហា ។

-**អនាសវធម៌** = ធម៌មិនមានអាសវៈ ៤ ។

-**សច្ចធម៌** = ធម៌ពិតដោយបរមត្ថសច្ចៈ ។

**បារធម៌** ៖ ធម៌ដែលជាត្រើយនៃវដ្តៈ ។

**និបុណធម៌** ៖ ធម៌ដ៏ល្អិតសុខុម ។

**សុទុទ្ទសធម៌**៖ធម៌ដែលសត្វឃើញបានដោយក្រក្រៃលែង។

**អជជ្ជរធម៌** ៖ ធម៌ដែលមិនគ្រាំគ្រាដោយជរា ។

**ធុវធម៌** ៖ ធម៌ដ៏ទៀងទាត់មាំទាំ ។

**អបលោកិនធម៌** ៖ ធម៌ដែលមិនមានសេចក្ដីវិនាស

**អនិទស្សនធម៌** ៖ ធម៌ដែលមើលមិនឃើញដោយចក្ខុវិញ្ញាណ ។

**និប្បបញ្ចធម៌** ៖ ធម៌ដែលគ្មានដំណើរយឺតយូរ ។

**សន្តធម៌** ៖ ធម៌ស្ងប់ ។

**អមតធម៌** ៖ ធម៌ដែលមិនស្លាប់ ។

**បណីតធម៌** ៖ ធម៌ដ៏ប្រណីតថ្លៃថ្លា ។

**សិវធម៌** ៖ ធម៌ដែលត្រជាក់ជាសុខសម្រាន្ត ។

**ខេមធម៌** ៖ ធម៌ដ៏ក្សេមក្សាន្តប្រាសចាកនូវអន្តរាយ ។

**តណ្ហក្ខយធម៌** ៖ ធម៌ជាទីក្ស័យទៅនៃតណ្ហា ។

**អច្ឆរិយធម៌** ៖ ធម៌ជាទីអស្ចារ្យ ។

**អព្ភុតធម៌** ៖ ធម៌ដែលមិនធ្លាប់មាន មិនធ្លាប់ប្រាកដ ជាធម៌ចម្លែក ។



**អនីតិកធម៌** ៖ ធម៌ដែលមិនមាននូវសេចក្ដីអន្តរាយ ។

**និព្វានធម៌** ៖ ធម៌មិនមានតណ្ហាជាគ្រឿងចាក់ស្រែះ ។

**អព្យាបជ្ឈធម៌** ៖ ធម៌មិនមានការបៀតបៀន ។

**វិរាគធម៌** ៖ ធម៌ប្រាសចាកតម្រេក ។

**សុទ្ធិធម៌** ៖ ធម៌ដ៏បរិសុទ្ធ ។

**មុត្តិធម៌** ៖ ធម៌ជាទីផុតចាកកិលេស និងផុតចាកពីភពទាំងបី ។

**អនាលយធម៌** ៖ ធម៌មិនមានអាល័យ ។

**ទីបធម៌** ៖ ធម៌ជាទីពឹង ។

**លេណធម៌** ៖ ធម៌ជាទីពួន ។

**តាណធម៌** ៖ ធម៌ជាទីដែលអាចការពារបាន ។

**សរណធម៌** ៖ ធម៌ជាទីរលឹក ។

**បរាយនធម៌** ៖ ធម៌ដែលជាទីទៅ ជាទីពឹងខាងមុខ ។

(២) **បែបឧបមា** ពាក្យឧបមាច្រើនប្រើក្នុងការបរិយាយលក្ខណៈនៃបុគ្គលបានសម្រេចនូវព្រះនិព្វាន គឺច្រើនជាងប្រើទៅក្នុងលក្ខណៈនៃព្រះនិព្វានដោយត្រង់ដូចជា ៖

ប្រៀបព្រះអរហន្ត ដូចគោនាំមុខហ្វូងគោ ហែលកាត់ក្រសែទឹកឆ្លងដល់ត្រើយ( បិដកលេខ ២២ ចូឡគោបាលសូត្រ ) ។

ដូចមនុស្សឆ្លងមហាសមុទ្រ ឬអន្លង់ទឹកធំ គេចពីអន្តរាយច្រើនយ៉ាង បានដល់ច្រាំង ហើយឡើងឈរលើគោក ( ក្នុងបិដកលេខ ៣៥ សមុទ្ទសូត្រ និងអាសីវិសូបមសូត្រ ) ។

ដូចភ្លើងរលត់ ជាឧបមាក្នុងការដែលព្រះអរហន្តបរិនិព្វាន នឹងថាព្រះអរហន្តបរិនិព្វានហើយ ទៅកើតទីណា ឬថាមិនកើតទេជាដើម សុទ្ធតែមិនត្រូវទាំងអស់ (បិដកលេខ ៣៦ វេទនា-សំយុត្ត, និងបិដកលេខ ២៤ អគ្គិវច្ឆគោត្តសូត្រ ) ។

យ៉ាងណាក៏ដោយ ពាក្យឧបមាអំពីព្រះនិព្វានដោយត្រង់ក៏មានដែរ ដូចជា ព្រះនិព្វានប្រៀបនឹងភូមិភាគដ៏រាបស្មើ គួរឱ្យរីករាយ (បិដកលេខ ៣៣ ទំព័រ ២៤៤ តិស្សសូត្រ ) ។

និព្វានដូចត្រើយនាយ មិនមានភ័យ (អាសីវិសូបមសូត្រក្នុងបិដកលេខ ៣៥ ទំព័រ ៣៩៤ ) ។

និព្វានដូចព្រះរាជសាសន៍តាមពិត (កឹសុកសូត្រ ក្នុងបិដកលេខ ៣៥ ទំព័រ ៤៣៣ ) ។

មានពាក្យហៅតាមបែបប្រៀបធៀបជាច្រើនទៀត មានជា អាទិ៍គឺ **អារោគ្យ** ការមិនមានរោគ **ទីប** កោះ , ទីដែលផុតភ័យ **លេណ** គុហា , ទីសម្រាប់ពួន , ទីកំបាំង ។ល។

ការសម្តែងអំពីព្រះនិព្វាន នៅមានច្រើនបែបទៀត ។



៤៨-ឱ្យតែចិត្តនៅក្នុងកុសល

ការខ្វះខាតក៏ត្រូវចុះថយ ការ ភ័យព្រួយក៏ត្រូវថយចុះ ។ ដូចពុទ្ធភាសិត **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ ។

៤៩-ភាវៈនៃចិត្តដែលសំខាន់ គឺចិត្តរួចផុត ។ ភាវៈនេះជាផលសម្រេចមកអំពីបញ្ញា គឺកាលបើបញ្ញាឃើញតាមសេចក្តីពិតដឹងច្បាស់នូវសង្ខារទាំងឡាយតាមពិតហើយ ទើបចិត្តរួចផុតអំពីអំណាចនៃការគ្របសង្កត់របស់កិលេស ។



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១. ឧបាសក សំរ៉ង វណ្ណី | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. លោកគ្រូ រស់ សូផាត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. នាង ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ឌុនណា |
| ១១. ឧបាសក សោម រតនៈ | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ជឹម ជំនិត | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ហាយ ច័ន្ទធរី | ១៦. លោកគ្រូ ជូ ប៊ុនយូ |
| ១៧. ឧបាសក ង៉ូវ គា | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០.ឧបាសិកា ស្រី បូរ៉ាន់ |

បើដឹងថាខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឱ្យជាការរក្សាដ៏ល្អ បណ្ឌិត គប្បីស្ងួនគ្រងនូវខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយ។



## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស. យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម ................................ ស.រ.អ.

២- ឧ.ស. ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ ........................... ស.រ.អ.

៣- ឧ.ស. ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម........................ ស.រ.អ.

៤- ឧ.ស. ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់ ............................ ស.រ.អ.

៥- ឧ.ស. វ៉ង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ.................. ស.រ.អ.

៦- ឧ.សិ. ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ .............................. ស.រ.អ.

៧- ឧ.សិ.ប៊ិត ថងខាំ + ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ .................... ស.រ.អ.

៨- ឧ.សិ. ស៊ីវ យក់លុយ ............................................................ ស.រ.អ.

៩- ឧ.ស. អ៊ុត ឆៃវ៉ាន និង ឧ.សិ.ធាន ស៊ុនលី និងបុត្រ....................... ស.រ.អ.

១០- ឧ.ស. ប្លោក ងួនថៃ ឧ.សិ.ធាន ត្រលុច និងបុត្រ ......................ស.រ.អ.

១១- ឧបាសិកា អ៊ឹង ស៊ីវន ............................................................ ស.រ.អ.

១២- ឧ.ស.សូ ហុកឡុង ឧ.សិ.កាន់ ឈីវហា ................................ ស.រ.អ.

១៣- ឧ.ស. អៀង ឆាយ និង ឧ.សិ. អៀ-កេសរ +បុត្រ ......................ស.រ.អ.

១៤- លោកតា តាន់ ឈីវហា + លោកយាយ ស៊្វ ចិន្ត្រា ......................... ស.រ.អ.

១៥- ឧ.សិ. តែ សាយជូ ព្រមទាំងកូនចៅ ......................................... ស.រ.អ.

១៦- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ ......................ស.រ.អ.

១៧- ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ................................ស.រ.អ.

១៨- ឧ.សិ. ម៉ិល យ៉ែម ............................................................ស.រ.អ.

១៩- ឧ.ស.សារឿន ឧ.សិ.លាប+ឧ.ស.ហ៊ឹស៊ុ ឧ.សិ.អាន ................. ស.រ.អ.

២០- ឧបាសក តាំង ស៊ុនម៉ាប ..................................................ស.រ.អ.

២១- លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ ............................ ស.រ.អ.

២២- លោកយាយ ពិន សាត ................................................... ស.រ.អ.

២៣- លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា ........................ ...... ស.រ.អ.

២៤- ភិក្ខុ ឈម បូ (វិជ្ជាសម្បទា )........................................... ស.រ.អ.

២៥- ឧ.ស. ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ............................ស.រ.អ.

២៦- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ..................................................... ស.រ.អ.

២៧- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា+បុត្រ.................ស.រ.អ.

២៨- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី .................................. ស.រ.អ.

២៩- ឧ.ស.ឡៅ ហោ និង ឧ.សិ.ង៉ោ ស៊ូអេង ................................ស.រ.អ.

៣០- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ .......................ស.រ.អ.

៣១- ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង .................................ស.រ.អ.

៣២- ឧ.សិ.ឧត្តមា ពេជ្រ អូន ..................................................ស.រ.អ.

៣៣- ឧ.ស.វ៉ាង សាវុធ និង ឧ.សិ.គង់ ស៊ីណាត +បុត្រ ..................ស.រ.អ.

៣៤- ភិក្ខុ ឈួម បូ (វត្តពន្លឺពុទ្ធចក្រ លោវែល ) ......................... ស.រ.អ.

៣៥- លោក ពេជ្រ សីហា និងអ្នកស្រី ថាប់ សុរត្ន័ ..........................ស.រ.អ.

៣៦- ឧ.ស.ប៊ុត ផល និង ភរិយា ..............................................ស.រ.អ.

៣៧- លោកគ្រូធម្មបណ្ឌិត អឿ សៅ .......................................... ស.រ.អ.

៣៨- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រីទ្ធារី ព្រមទាំងបុត្រ ................ ស.រ.អ.

៣៩- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា.......................... ស.រ.អ.



៤០- ឧ.សិ.ឡុង អ៊ីម ............................................................ ស.រ.អ.

៤១- ឧ.សិ.ច័ន្ទ ប៉ុណ្ណារី............................................................ ស.រ.អ.

៤២- ឧ.សិ.ហោ ប៊ួយ និងឧ.សិ.ហោ មួយ ហៅតាំងហ៊្គិចមួយ ................ស.រ.អ.

៤៣- លោក សំណាង យឹម និង អ្នកស្រី ឡូរ៉ា យឹម .......................... ស.រ.អ.

៤៤- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ............... ស.រ.អ.

៤៥- ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.រ៉ូច អ៊ឹម ព្រមទាំងបុត្រ ................. ស.រ.អ.

៤៦- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ................. ស.រ.អ.

៤៧- ឧ.សិ.តាំង លេខគៀវ ព្រមទាំងបុត្រ និងចៅ ........................... ស.រ.អ.

៤៨- ឧ.សិ.នួន ប៊ិច និង ឧ.សិ.រស់ សុផល ..................................... ស.រ.អ.

៤៩- ឧ.ស.ហោ លាន និង ភរិយា ................................................. ស.រ.អ.

៥០- ឧ.ស.អ៊ុន ឆៃត្រី និង ភរិយា ................................................. ស.រ.អ.

៥១- ឧ.សិ.មិល យ៉ែម និង ឧ.សិ.គួយ ឡេង ..................................... ស.រ.អ.

៥២- ឧ.សិ.ហុក ឈិន និង ឧ.សិ.ប្រាក់ អៀត ព្រមទាំងកូនចៅ ............ ស.រ.អ.

៥៣- ភិក្ខុ ឡូញ ផល្លី និង ភិក្ខុ ភឿក បូរ ........................................ អូស្ត្រាលី

៥៤- ឧ.ស.ប៊ុន ហេង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ..........................អូស្ត្រាលី

៥៥- ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ................................. អូស្ត្រាលី

៥៦- ឧ.ស.លីម ងីនសួ និង ឧ.សិ. អ៊ឹង ឆាយហួ +បុត្រ. ......................អូស្ត្រាលី

៥៧- ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង+បុត្រ ........................អូស្ត្រាលី

៥៨- ឧ.សិ. ឈ គឹមស៊ីន និង ក្រុមគ្រួសារ ........................................អូស្ត្រាលី

៥៩- ឧ.សិ. សេង សៀងឈុន ព្រមទាំងបុត្រ ................................. អូស្ត្រាលី

៦០- ឧ.សិ.សិរិត ស៊ីវ៉ន .............................................................អូស្ត្រាលី

៦១- ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ ..........................................អូស្ត្រាលី

៦២- កញ្ញា ស៊ុយ ដាណែត ........................................................អូស្ត្រាលី

៦៣- យុវជន ចាន់ ឌីណា ............................................................ អូស្ត្រាលី

៦៤- ឧ.ស.យ៉ង់ សិន និងឧ.សិ.នន់ ហេង +បុត្រ..................................អូស្ត្រាលី

៦៥- ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ................អូស្ត្រាលី

៦៦- ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ................................ អូស្ត្រាលី

៦៧- ឧ.សិ.នូ ធុច ព្រមទាំងបុត្រ និងចៅ.......................................... អូស្ត្រាលី

៦៨- យាយ ប្រាក់ខាត់ +ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ ............... អូស្ត្រាលី

៦៩- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង + បុត្រ .................. អូស្ត្រាលី

៧០- ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.៣ ស៊ីម +បុត្រនិងចៅ ....................... អូស្ត្រាលី

៧១- ឧ.ស.ឃិន ថុងអ៊ាន និង ឧ.សិ.ម៉េង គិមស៊ាន + បុត្រ....................អូស្ត្រាលី

៧២- ឧ.ស.សុខ សារឿន និង ឧ.សិ.មោក មី + បុត្រ.......................... អូស្ត្រាលី

៧៣- ឧ.សិ.យ៉ុង សុន ព្រមទាំងបុត្រ.............................................. អូស្ត្រាលី

៧៤- ឧ.ស. លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី +បុត្រ .................... អូស្ត្រាលី

៧៥- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ .......អូស្ត្រាលី

៧៦- ឧ.សិ.ម៉េង ប៊ុនធារី (ហៅស្រីពៅ) ..................................... អូស្ត្រាលី

៧៧- ឧ.សិ.ជា ឡេង ............................................................... អូស្ត្រាលី

៧៨- ឧ.ស.សាប់ ភូរិន្ទ ........................................................... អូស្ត្រាលី

៧៩- ឧ.ស.ស៊ូ យឹម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ ................. អូស្ត្រាលី

៨០- លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល ប្រមទាំងបុត្រ ........ អូស្ត្រាលី



៨១- ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ................. អូស្ត្រាលី

៨២- Mr ANARING និងអ្នកស្រី កាយ សផា +បុត្រ+ បងប្អូន ........... អល្លឺម៉ង់

៨៣- លោក យូឈួស អាស៊ីស និង អ្នកស្រី ហុក ណារី+បុត្រ ................ បារាំង

៨៤- ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ............................ បារាំង

៨៥- ឧ.ស. ឡុក ប៊ុនអ៊ីវ និងឧ.សិ.តាន់ ស៊ីវឡាង+បុត្រ........................ បារាំង

៨៦- ឧ.សិ. អ៊ឹង-ហ្គេចតេង ព្រមទាំងបុត្រ ....................................... បារាំង

៨៧- ឧ.ស. ឡោ សេងជ្រុន ឧ.សិ.ផាំង លី និងបុត្រ............................... បារាំង

៨៨- ឧ.សិ. ជា ម៉ាក់លាង ............................................................. បារាំង

៨៩- ឧ.ស.ហ្វាន់ វ៉ាន់ហួ និងឧ.សិ.ហ្វាន់ យូលាង .................................. បារាំង

៩០- ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ .............................. បារាំង

៩១- ឧ.សិ.គីម មុយ ព្រមទាំងក្រុមគ្រួសារ ......................................... បារាំង

៩២- ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ......................................... បារាំង

៩៣- ឧ.សិ.ដៀប រុន ព្រមទាំងបុត្រធីតា ............................................បារាំង

៩៤- ឧ.ស.បាន ណារិន ឧ.សិ.ហោ ចន្ធូ និងបុត្រ .................................. បារាំង

៩៥- ឧ.ស.ជីន ជុង និងភរិយា....................................................... បារាំង

៩៦- ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ .......................................... បារាំង

៩៧- ឧ.ស.ឈុត ស៊ីថន និង ឧ.សិ.អ៊ូ សុផា ព្រមទាំងបុត្រ .................. បារាំង

៩៨- ឧ.សិ.ឆាយ ស៊ន ព្រមទាំងបុត្រ+ចៅ+ចៅទួត..........................កាណាដា

៩៩- ឧ.ស.ពុធ-ប៉ោលាង ឧ.សិ. ហ៊ុន-ស៊ីវអៀង ...............................កាណាដា

១០០- Chhem Sokreth et Puth Kunthea ............................ កាណាដា

១០១- ឧ.សិ. អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ ..............................កាណាដា

១០២- ឧ.សិ. ចំណាន ព្រមទាំងក្រុមគ្រួសារ ..................................កាណាដា

១០៣- ឧ.សិ. លី វន ព្រមទាំងក្រុមគ្រួសារ .................................. កាណាដា

១០៤- ឧ.ស.ឡាវ លាងថេង ឧ.សិ.ពឹង ឈីវអ៊ាន...........................កាណាដា

១០៥- ឧ.សិ.លាន មុិច .......................................................... កាណាដា

១០៦- ឧ.សិ.តាន់ វួចឆាយ ..........................................................កាណាដា

១០៧- ឧ.ស.ហេង ជាវ និង ឧ.សិ.កាយ ហួន ព្រមទាំងបុត្រ ........... កាណាដា

១០៨- ឧ.ស. យន្ត សួន ឧ.សិ. តាំង ឈុងប៊ួយ និងបុត្រ ........................ ភ.ព.

១០៩- ឧ.ស.ធ្នាំ ( ធម្ម ) ប៊ុនស្រុន និង ឧ.សិ.យ៉ែម សួស្តី+បុត្រ ............. ភ.ព.

១១០- ឧ.ស.សយ ស៊ីផាន់ណា និង ឧ.សិ.ម៉ៅ សុផល+បុត្រ ...................ភ.ព.

១១១- ឧ.សិ. ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ....................................ភ.ព.

១១២- ឧ.សិ.ស្លួន កល្យាណ ......................................................... ភ.ព.

១១៣- ឧ.សិ.ស្លួន ចរណៃ ........................................................... ភ.ព.

១១៤- ឧ.ស. យូ ម៉េង និង ឧ.សិ. ជួន សំណាង..................................ក.ព.ស.

១១៥- ឧ.ស.ម៉ៅ សុគន្ធ និង ឧ.សិ.អ៊ឹង យ៉េកហួយ និងបុត្រ ................. ភ.ព.

១១៦- ឯ.ឧ.អ៊ិត ប្រាំង និង លោកជំទាវ ញ៉ែម សេដ្ឋា +បុត្រ ....................ភ.ព.

១១៧- ឯ.ឧ.ចែម វីឌ្យ៉ា និង លោកជំទាវ សុខា ស៊ូលីវណ្ណ+បុត្រ .................ភ.ព.

១១៨- ឧកញ៉ា សេង ឆាយអ៊ួរ និង ឧ.សិ.កាំង ហ្គិចណៃ+បុត្រ ..................ភ.ព.

១១៩- ឧ.សិ.ប៉ក់ សូត្រសុភាព ព្រមទាំងបុត្រ .......................................ភ.ព.

១២០- ឧ.ស.ប៉ុល នាង និង ឧ.សិ.គ្រៀល ស៊ីយ៉ា +បុត្រ ............................ភ.ព.

១២១- ឧកញ៉ា ស៊ិន សុខា និង លោកជំទាវ សុខា ផល្លី +បុត្រ ....................ភ.ព.

១២២- ឧ.សិ.ហេង ស៊ីវខេង និងម្តាយឈ្មោះ អៀង ហ្គិច ................. កណ្តាល



១២៣- ឧ.ស.យឹម ស៊ីមុន្នី និង ឧ.សិ.យូ ប៉ូលីន និងបុត្រ ............................ភ.ព.

១២៤- ឧ.ស.ឡាយ សុខុម និង ឧ.សិ.សួន ចន្ថា និងបុត្រ ..........................ភ.ព.

១២៥- ឧ.ស.ងឹម ញាណ និង ឧ.សិ. កាំង ប៉ូលីន និងបុត្រ .................... ក.ព.ស.

១២៦- ឧ.សិ. ប៉ូអាន ស៊ីវុត្ថា ...........................................................ភ.ព.

១២៧- ឧ.សិ. ប៉ូ ផាវ៉ាណ ............................................................. ភ.ព.

១២៨- ឧ.សិ. ម៉ៅ សុន្ថា ............................................................... ភ.ព.

១២៩- ឧ.សិ. សាក់ ស៊ាងអេង ព្រមទាំងបុត្រ ......................................ភ.ព.

១៣០- ឧ.ស. ស៊ីវ សៅរ៍ និង ឧ.សិ. ស្រៀង វួចលាង ............................ ភ.ព.

១៣១- ឧ.ស.អ៊ុក សាម៉ាណារ៉ា ឧ.សិ.ហ៊ាប តេង និងបុត្រ......................... ភ.ព.

១៣២- ឧ.ស. ម៉ៅ ស្រ៊ិន ឧ.សិ. ទូច ស៊ីនហ៊ាន និងបុត្រ............................ ភ.ព.

១៣៣- ឧ.ស. ម៉ែន សឿន ឧ.សិ. អៀង ណារី និងបុត្រ ........................ ភ.ព.

១៣៤- ឧ.សិ. សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ...............................ភ.ព.

១៣៥- លោក សែន សុវណ្ណារិទ្ធ និងភរិយា ........................................... ភ.ព.

១៣៦- ឧ.សិ. តាន់ ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប ..........................ស.រ.

១៣៧- ឧ.សិ.ជុំ ឆាយ, ឧ.សិ.ជុំ ណារ៉ា+ជុំ ពិសិដ្ឋ+ជុំ សុជាតិ .................... ភ.ព.

១៣៨- ឧ.សិ. ស៊ីវ យក់លី ............................................................. ភ.ព.

១៣៩- ឧ.ស. ជាន យ៉ែត និង ឧ.សិ. សុក ចេង ព្រមទាំងបុត្រ ..................ភ.ព.

១៤០- ឧ.ស. សោម រតនៈ និង ឧ.សិ. ស៊ិប វណ្ណា + បុត្រ......................... ព.វ.

១៤១- ឧ.ស.ហេងសម្បូរវឌ្ឍ ឧ.សិ.ស៊ិនគន្ធា+មាតាហេងបូរីស្រីនាថ............. ភ.ព.

១៤២- យុវជន ជា សុភ័ក្រ្ត និងមាតាបិតា ........................................... ភ.ព.

១៤៣- ឧ.សិ.ហ៊ុយ សុខម៉ា និងស្វាមី ព្រមទាំងបុត្រ ...............................ភ.ព.

១៤៤- ឧ.សិ. វណ្ណ មុនី ព្រមទាំងបុត្រ និងចៅ ...................................... ភ.ព.

១៤៥- ឧ.ស.តៅ ឃាង និង ឧ.សិ. ឈុន លន និងកូនចៅ ...................... ភ.ព.

១៤៦- ឧ.សិ. សុខ ភួង និង ឧ.សិ. សុខ ផៃ ........................................... ភ.ព.

១៤៧- ឧ.សិ. អ៊ុក លន់ និងក្រុមវេន ព្រមទាំងបុត្រ .............................. ភ.ព.

១៤៨- ឧ.សិ. គង់ ម៉ៃ ព្រមទាំងបុត្រ និងចៅ ........................................ ភ.ព.

១៤៩- ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ .................................................. ភ.ព.

១៥០- ឧ.សិ.មុំ ទូច និងកូនឧ.សិ.សាមុល គីមធន់ ........................ ភ.ព.

១៥១- ឧ.ស.ម៉ៅ វ៉ាន និង ឧ.សិ.ធន់ សំបូរ ព្រមទាំងបុត្រ.......................... ភ.ព.

១៥២- លោក ម៉េង ហ៊ា អ្នកស្រី ម៉ាន ស៊ីសុថា និងបុត្រ ............................ភ.ព.

១៥៣- ឧ.ស.ចៅ ហ្វា និង ឧ.សិ.ឡា គីមសាន និងបុត្រ ............................ភ.ព.

១៥៤- ឧ.សិ.វឿន គង់+ស្វាមី និង លោក ប្រាក់ ខេមរិន្ទ+ភរិយា................. ភ.ព.

១៥៥- ឧ.សិ.ឯម សុខឃីម និង ស្វាមី ព្រមទាំងបុត្រ ............................. ភ.ព.

១៥៦- លោកយាយ ប៊ុន យ៉ុាំ ព្រមទាំងកូន និងចៅ ................................. ភ.ព.

១៥៧- ឧ.ស.កាន់ រ៉ាត់ និង ឧ.សិ.កែវកល្យាណ+ក.កាន់សុថារ័ត្ន................ ភ.ព.

១៥៨- ឧ.សិ.អ៊ិតឆេងស៊ី ក្រុមវេនថ្ងៃ២កើតវត្តព្រះពុទ្ធមានបុណ្យ .............. ភ.ព.

១៥៩- ក្រុមព្រែកខ្ចិត ព្រែកលាប និងទួលគោក ... ................................ ភ.ព.

១៦០- ក្រុមចាបម៉ុងឡេង+ឈាងហុង វេន៩កើតសំពៅមាស ................... ភ.ព.

១៦១- ឧ.ស.ហេង ឆៃទិត ឧ.សិ.រស់ ម៉ាលី ព្រមទាំងបុត្រ ....................... ភ.ព.

១៦២- ឧ.ស.ឡាយ ហ៊ុយទ្រៀង ឧ.សិ.លាក ណាក់ និងបុត្រ .....................ភ.ព.

១៦៣- ឧ.ស.តូច ផាន់ណាស៊ី និង ឧ.សិ.សុខ ច័ន្ទណារិទ្ធ+បុត្រ.....................

ភ.ព.



១៦៤- ឧ.ស.សួរ សារឹម និង ឧ.សិ.បុង ផល្លី ព្រមទាំងបុត្រ ...................... ភ.ព.

១៦៥- ឧ.សិ.ហែម វណ្ណា និង ឧ.សិ.ហែម វុឌ្ឍី +បុត្រ ............................. ភ.ព.

១៦៦- ឧ.ស.យ៉ុាំ ស្រេន ឧ.សិ.អ៊ុល សេងលាង និងបុត្រ.......................... ភ.ព.

១៦៧- ឧ.ស.ស៊ីន វ៉ា+យានថៃ+ឧ.ស.ស៊ីនម៉េងស្រ៊ុន+បូជុំស៊ីន .................. ភ.ព.

១៦៨- ឧ.សិ.ជា សុណារី ..................................................................

ភ.ព.

១៦៩- ឧ.ស.ភាវ សាន និង ឧ.សិ.ប៉ក់ សុបុណ្យ+បុត្រ..............................ភ.ព.

១៧០- ឧ.ស.ម៉ួង យឿនវណ្ណៈ និង ឧ.សិ.ប៉ក់ សូត្រសុន្ទី+បុត្រ.....................ភ.ព.

១៧១- ឧ.ស.ស៊ឹម សុង និង ឧ.សិ.ឆៃ គាង +ពុទ្ធបរិស័ទផ្សារកអណ្តើក ........ ព.វ.

១៧២- លោក រឿង សេដ្ឋា និងអ្នកស្រី នាង ជួនអេង ព្រមទាំងបុត្រ ......... ភ.ព.

១៧៣- លោក ស៊ា រស់ និងអ្នកស្រី ញ៉េប ដារ៉េត ព្រមទាំងបុត្រ ............... ភ.ព.

១៧៤- ឧ.សិ.ឈួន គីមនី និងបងប្អូន កូនក្មួយ ........................................ ភ.ព.

១៧៥- ឧ.សិ.ត្រី ណៃប៊ួយ ព្រមទាំងបុត្រ .............................................

ភ.ព.

១៧៦- ឧ.សិ.ច្រឹង គីមស្រ៊ុ ព្រមទាំងបុត្រ ..............................................ភ.ព.

១៧៧- ឧ.ស.ម៉ៅ ផុន និងមាតា យស សម្បត្តិ .........................................ភ.ព.

១៧៨- ឧ.ស.ម៉ៅ សយ និងឧ.សិ.គង់ ចំរើន +បុត្រ .................................ភ.ព.

១៧៩- ឧ.សិ.ហ៊ុយ ព្រឿងគិមស្រ៊ាង +បុត្រ និងចៅ................................. ភ.ព.

១៨០- ក្រុមឧ.ស. មួង -យេន វត្តសំពៅមាស ......................................ភ.ព.

១៨១- ឧ.សិ.ថៅ ហៀក ព្រមទាំងបុត្រ ..................................................ភ.ព.

១៨២- ឧ.ស.ខៀវ ជៀប និង ភរិយា ព្រមទាំងបុត្រ +ចៅ ........................ ភ.ព.

១៨៣- ឧ.សិ.តាំង លីគាង និង ស្វាមី ព្រមទាំងបុត្រ +ចៅ ....................... ភ.ព.
១៨៤- ឧ.សិ.ឈឹម ផលវិទ្យា ........................................................... ភ.ព.
១៨៥- ឧ.សិ.កាំង ប៉ោទាង និង ឧ.ស.ហេ អេន +កូនចៅ ........................ ភ.ព.
១៨៦- ឧ.សិ.លឹម មួយគា លោក យុន ឈុន្នី+អ្នកស្រី ទី មុំ .......................
ភ.ព.
១៨៧- ឧ.ស.បេង ហុងសុជាតិដារិដ ឧ.សិ.ប៉ក់ សុខបូផាន+បុត្រី................ ភ.ព.
១៨៨- ឧ.សិ.លឹម អេង ព្រមទាំងបុត្រ ............................................. ភ.ព.
១៨៩- ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គឹមអេង + បុត្រ.............................. ប.ប.
១៩០- លោក លាភ ឆាយ អ្នកស្រី ហែម ពៅ + បុត្រ.......................... ភ.ព.
១៩១- លោក ម៉េង សាខន និង ឧ.សិ.ចាន់ សុខា + បុត្រ......................... ភ.ព.
១៩២- ឧ.សិ.យាន ច័ន្ទលី ................................................................ ភ.ព.
១៩៣- ឧ.សិ.លឹម វ៉ូចហ៊ាង ព្រមទាំងបុត្រ និងចៅ ................................ ភ.ព.
១៩៤- ឧ.ស.ស្រូ ងាម និង ឧ.សិ.ហ៊ួង ម៉ន .......................................... ភ.ព.
១៩៥- ឧ.សិ.យឹម សាវ៉ាត និង ឧ.សិ.លី ហ្គេចឡាង+ស្វាមី+បុត្រ.............. ភ.ព.
១៩៦- ឧ.ស. ស៊ុយ ជូ និង ឧ.សិ. តាំង ទ្សេង ...................................... ភ.ព.
១៩៧- ឧ.សិ.រស់ សេរី និង ឧ.សិ.សឿ ចន្ថា.......................................... ភ.ព.
១៩៨- ឧ.សិ.វៀល យ៉ុន ព្រមទាំងបុត្រ .............................................. ភ.ព.
១៩៩- ឧ.ស.សុខ សារឿន ឧ.សិ.ទូច ម៉ុម ហៅយឹម និងបុត្រ .................. ភ.ព.
២០០- ឧ.ស.គង់ សៀងហៃ និង ឧ.សិ.ប៉ក់ សូត្រតារាភិឌិន+បុត្រ............. ភ.ព.
២០១- ឯកឧត្តម សុខ សុខា និង លោកជំទាវ ចាន់ លាង +បុត្រ .. ............ ភ.ព.
២០២- ឯកឧត្តម ឯម ប៊ុនសាត និង លោកជំទាវ នូ ចន្ថា+បុត្រ ... ............ ភ.ព.



២០៣- ឧ.ស.ជ្រា បេង និង ឧ.សិ.គ្រិត គីម ព្រមទាំងបុត្រ ......... ............ ភ.ព.
២០៤- ឧ.សិ.ហ៊ុយ រ៉ាវី និង ស្វាមី ព្រមទាំងបុត្រ .................................. ភ.ព.
២០៥- ឧ.សិ.ប៊ូ សៀកហ៊ុន ព្រមទាំងបុត្រ និងចៅ ................................ ភ.ព.
២០៦- វេជ្ជ.ហ៊ាន រ៉ាវី និង ឧ.សិ.ម៉ូវ លាង ព្រមទាំងបុត្រ ........................ ភ.ព.
២០៧- ឧ.ស.ម៉ូវ ធីម និង ឧ.សិ.ហ៊ាន ណៃយឹម ព្រមទាំងបុត្រ ................. ភ.ព.
២០៨- ឧ.ស.ហ៊ាន រ៉ាវឿន និង ឧ.សិ.ប៉ែន បុប្ផា ព្រមទាំងបុត្រ ................. ភ.ព.
២០៩- ឧ.ស.ង៉ែត ផេង និង ឧ.សិ.ហៅ ហេង +បុត្រផេង បូរ៉ា ................. ភ.ព.
២១០- ឧ.សិ. ថៃ នាថ ព្រមទាំងបុត្រ និងចៅ ...................................... ភ.ព.
២១១- ឧ.ស.រ៉ៃន សារ៉ូន និង ឧ.សិ.តូច លីណារ៉ា ព្រមទាំងបុត្រ ................ ភ.ព.
២១២- លោក ជា សារ៉ាយ និង អ្នកស្រី អ៊ុំ សុផានី +បុត្រ+ចៅ ................. ភ.ព.
២១៣- ឧ.ស.មាស ខេង និង ឧ.សិ.មួរ វ៉ូច ព្រមទាំងកូនចៅ .................... ភ.ព.
២១៤- ឧ.ស.ឃុត គឹមថន + ឧ.ស.ព្រុំ សុន និង ភរិយា .......................... ភ.ព.
២១៥- ឧ.សិ. គីម សុខុន និងបុត្រ .................................................. ភ.ព.
២១៦- ឧ.សិ.ឯម សុខន និងបុត្រ និង ឧ.សិ.សុខ សាអ៊ិក ........................ ភ.ព.
២១៧- ឧ.សិ.អ៊ូ ស៊ីណាត +ឧ.ស.ឡឹង ជី និង ឧ.សិ.អ៊ូ ប៊ុននី +កូនចៅ ........ ភ.ព.
២១៨- ឧ.សិ.គឹម ឆេង ព្រមទាំងកូនចៅ ............................................. ភ.ព.
២១៩- ឧ.សិ.ជូ ឆេងហោ ................................................................. ភ.ព.
២២០- ឧ.សិ.លី ឡៃហ៊ាង ព្រមទាំងបុត្រ និងចៅ .................................. ភ.ព.
២២១- ឧ.ស.ថាច់ លី និង ឧ.សិ.ភៀង ភៀង ....................................... ភ.ព.
២២២- Mr.JONATHAN BALK and Mss.BUNNA KEO BALK ........... ភ.ព.
២២៣- ឧ.សិ.ព្រុំ សុភាព ................................................................. ភ.ព.

២២៤- លោក សីក ធឿន+ឧ.ស.វុទ្ធី សម និង ឧ.សិ.គឹម អេង ................. ភ.ព.

២២៥- លោក ស្រេង ហេង និង ឧ.សិ.កែវ រស្មី ព្រមទាំងបុត្រ ................. ភ.ព.

២២៦- ឧ.ស.នុត វន្ថា និង ឧ.សិ.ម៉ៅ សុភា និង ស្វាមី ព្រមទាំងបុត្រ ..... ភ.ព.

២២៧- ឧ.សិ.អ៊ូ សំណាង និង ឧ.សិ.ឡាច ផន ព្រមទាំងបុត្រ ................... ភ.ព.

២២៨- ឧ.ស.ជា សុខុម និង ឧ.សិ.អ៊ុន ពូន ............................................ ?

២២៩- ឧ.ស.ឡាយ សេង និង ឧ.សិ.ម៉ែន វណ្ណា ព្រមទាំងកូនចៅ ............ ភ.ព.

២៣០- ឧ.សិ.ជុំ ស៊ីម៉ុន និងបុត្រ ពេជ្រ សុឃុន ..................................... ភ.ព.

២៣១- ឧ.ស.ស៊ា បូរ៉ា និង ឧ.សិ.ប៉ុល បុទម +បុត្រ ស៊ា ស៊ូជីង ................ ភ.ព.

២៣២- ឧ.ស.គង់ ហេង និង ឧ.សិ.ធាវ ស៊ីប ព្រមទាំងកូនចៅ ................. ភ.ព.

២៣៣- ឧ.សិ.ហ៊ុន ហេង ................................................................. ភ.ព.

២៣៤- ឧ.ស.ទី គៀង និង ភរិយា ព្រមទាំងបុត្រ .................................. ភ.ព.

២៣៥- ក្រុមលោកតា ម៉ោង វត្តទួលទំពូង ............................................ ភ.ព.

២៣៦- ឧ.សិ.តោ ឡោ ព្រមទាំងកូនចៅ ............................................. ភ.ព.

២៣៧- ក្រុមវេនចង្ហាន់សង្ឃ ,១កើតសំពៅមាស ,៦កើតចំបក់មានជ័យ,
១១កើតសុវណ្ណបទុម,៦រោចនិគ្រោធវ៉ន,១០រោចវេឡុវ៉ន................ភ.ព

២៣៨- មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិ៍សាត់...... ............ព.ស.

២៣៩- ក្រុមពុទ្ធបរិស័ទស្រុកមង្គលបូរី+សិរីសោភ័ណ .......................... ប.ម.ជ.

២៤០- ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ................................ប្រទេសអូស្ត្រាលី

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈



# I

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសមាគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -04h50 mn | -FM 98 MHz |
| | -05h00 mn | -FM 99 MHz |
| | -05h30 mn | -FM 96 MHz |
| | -12h10 mn | -FM 96 MHz |
| | -18h00 mn | -FM 95 MHz |
| | -19h00 mn | -AM 918 KHz |
| | -20h00 mn | -FM 98 MHz |
| | -20h30 mn | -FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn | -FM 92 MHz |
| | -13h00 mn | -FM 92 MHz |
| | -17h30 mn | -FM100.5MHz |
| ខេត្តបាត់ដំបង | -05h30 mn | -FM103.2MHz |
| | -06h00 mn | -FM 92.7MHz |
| | -18h00 mn | -FM 91 MHz |
| | -18h30 mn | -FM 92.7MHz |
| | -19h30 mn | -FM103.2MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5MHz |

**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទានឈ្នះអស់ទានទាំងពួង ។**

## II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-05h30 mn<br>-18h30 mn | -FM 98 MHz<br>-FM 105.5 MHz<br>-FM 100.5 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h00 mn | -FM 96.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តឧត្តរមានជ័យ | -05h00 mn<br>-19h00 mn | -FM 90.25MHz |
| ខេត្តស្ទឹងត្រែង | -18h30 mn | -FM100.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |
| ខេត្តក្រចេះ | -05h30 mn | -FM 98.5 MHz |
| ខេត្តរតនគីរី | -18h30 mn | -FM 89.5 MHz |
| ខេត្តតាកែវ | -17h00 mn | -FM 92.5 MHz |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ។



## សៀវភៅដែលរៀបរៀងដោយ
## ខ្ញុំព្រះករុណា ខ្ញុំបាទ
## ✍ ប៊ុត-សាវង្ស ✍

១. ជំនួយសតិភាគទី ១៣
២. ជំនួយសតិភាគទី ១ ដល់ភាគទី ១២
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ ៤ ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣ គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក
១០. ម៉ែ !!!
១១. វិធីរម្ងាប់សេចក្តីក្រោធ
១២. សុខចិត្ត និងគុណភាពនៃជីវិត
១៣. មេរៀនជីវិត
១៤. ពាក្យពេចន៍ម៉ែឪ
១៥. បទពិចារណា
១៦. ពន្លឺធម៌ព្រះពុទ្ធ
១៧. បារមីភាគទី ១ និងខ្លឹមសារខ្លីៗ

៨. បារមីភាគទី ២ និងខ្លឹមសារខ្លីៗ

១៩. ៤៨ ធម្មទស្សន៍

២០. ស្ត្រីក្នុងព្រះពុទ្ធសាសនា

២១. ឧបមាភាសិត ៤៩

**សូមអនុមោទនាធម្មទាន !**

**បោះពុម្ពបោះពុម្ពជាធម្មទាន ៣០.០០០**
**ក្បាល ក្នុងតម្លៃ ១៨.៦០០ ដុល្លារ**
**រោងពុម្ព មិត្តភាពកម្ពុជា-ជប៉ុន**



## ដំណឹងអនុមោទនា

**ព.ស.២៥៤៩**

ចំនួនគម្ពីរព្រះត្រៃបិដកដែលពុទ្ធបរិស័ទជូនមកសម្រាប់ធ្វើជាធម្មទានតម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ១៥៩ ចប់ ។

ចាប់ពីថ្ងៃ ១ រោច ខែអស្សុជ ព.ស.២៥៤៨ មកដល់
ថ្ងៃ ៧កើត ខែជេស្ឋ ព.ស.២៥៤៩ (រយៈពេល ៧ ខែ ២២ ថ្ងៃ)
ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស
ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៤៤៥ បុណ្យ
បានប្រាក់បូជាព្រះធម៌ចំនួន ៣៤៦.៦៨០.០០០៛
(បីរយសែសិបប្រាំមួយលាន ប្រាំមួយរយប៉ែតសិបពាន់រៀល)
និង ១២.៣៤៨ ដុល្លារអាមេរិក
សរុបទាំងអស់ត្រូវជា ៩៩.០១៨ ដុល្លារអាមេរិក
ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន
៤៤.៦៦០.០០០ ៛ + ៧៣០ ដុល្លារអាមេរិក ។
ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ៦.០៧៥ ដុល្លារអាមេរិក ។

សូមអនុមោទនា !!!

# ដំណឹងអនុមោទនា

## ព.ស.២៥៥០

ចំនួនគម្ពីរព្រះត្រៃបិដកដែលពុទ្ធបរិស័ទជូនសម្រាប់ធ្វើជាធម្មទានតម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ៣៦១ ចប់ ។

ប្រាក់បូជាព្រះធម៌នៅអាមេរិក និងកាណាដា រយៈពេល ៣ខែ បាន ៨៥.២១០ ដុល្លារ ក្នុងនោះថែមប្រាក់បច្ច័យបួន ១០.១៤០ដុល្លារ ។

ចាប់ពីថ្ងៃ ៩ រោច ខែភទ្របទ ព.ស.២៥៤៩ មកដល់

ថ្ងៃ ៥រោច ខែជេស្ឋ ព.ស.២៥៥០ (រយៈពេល ៨ ខែ ២៦ ថ្ងៃ)

ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស

ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៤៧៩ បុណ្យ

បានប្រាក់បូជាព្រះធម៌ចំនួន ៣៩៧.៨៤៤.០០០៛

(បីរយកៅសិបប្រាំពីរលាន ប្រាំបីរយសែសិបបួនពាន់រៀល)

ស្មើនឹង ៩៩.៤៦១ ដុល្លារអាមេរិក

ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន

៥៥.៨២២.០០០ ៛ ស្មើនឹង ១៣.៩៥៥ ដុល្លារអាមេរិក ។

ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ១០.០៧០ ដុល្លារអាមេរិក (ចំណូល ១.២១៧ ដុល្លារ)។

សូមអនុមោទនា !!!



# ដំណឹងអនុមោទនា

## ព.ស.២៥៥១

ចំនួនគម្ពីរព្រះត្រៃបិដកដែលពុទ្ធបរិស័ទជូនសម្រាប់ធ្វើជាធម្មទានតម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ៥២០ ចប់ ។

ប្រាក់បូជាព្រះធម៌នៅប្រទេសអូស្ត្រាលី ក្នុងរយៈពេល ២៩ ថ្ងៃ បាន ២០.០០០ $ AUS. ក្នុងនោះថែមប្រាក់បច្ច័យបួន ២.៣៩០ $ AUS. ។

ចាប់ពីថ្ងៃ ៦ រោច ខែជេស្ឋ ព.ស.២៥៥០ មកដល់

ថ្ងៃ ៣ រោច ខែបឋមាសាឍ ព.ស.២៥៥១ (រយៈពេល ១២ ខែ ២៧ ថ្ងៃ)

ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស

ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៦៥០ បុណ្យ

បានប្រាក់បូជាព្រះធម៌ចំនួន ៥៥៨.៣០០.០០០៛

(ប្រាំរយហាសិបប្រាំបីលាន បីរយពាន់រៀល)

ស្មើនឹង ១៣៦.១៧០ ដុល្លារអាមេរិក

ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន

៥៦.២៨០.០០០ ៛ ស្មើនឹង ១៣.៧២៧ ដុល្លារអាមេរិក ។

ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ៧.៦០២ ដុល្លារអាមេរិក (ពុទ្ធបរិស័ទចូលរួម ១៥៣៤ ដុល្លារ)។

សូមអនុមោទនា !!!

## ដំណឹងអនុមោទនា

### ព.ស.២៥៥២

ចំនួនគម្ពីរព្រះត្រៃបិដកដែលពុទ្ធបរិស័ទជូនសម្រាប់ធ្វើជាធម្មទាន តម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ៧១៤ ចប់ ។

ចាប់ពីថ្ងៃ ៩ កើត ខែទុតិយាសាឍ ព.ស.២៥៥១ មកដល់ ថ្ងៃ ១២ រោច ខែជេស្ឋ ព.ស.២៥៥២ (រយៈពេល ១១ ខែ ១៨ ថ្ងៃ) ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៥៩៨ បុណ្យ បានប្រាក់បូជាព្រះធម៌ចំនួន ៦៧០.៤៥០.០០០៛ (ប្រាំមួយរយចិតសិបលាន បួនរយហាសិបពាន់រៀល) ស្មើនឹង ១៦៧.៥១២ ដុល្លារអាមេរិក ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន ៧៨.៥៧០.០០០ ៛ ស្មើនឹង ១៩.៦៤២ ដុល្លារអាមេរិក ។ ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមករៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន ៤.៥៦០ ដុល្លារអាមេរិក (ពុទ្ធបរិស័ទចូលរួម ១០៥៧ ដុល្លារ)។

សូមអនុមោទនា !!!

ប្រារព្ធព្រះមហាមោគ្គល្លានត្ថេរ មានបុព្វកម្មវាយសម្លាប់ឪពុកម្តាយ



យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ
អថវស្ស អគារានិ អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយដែលមិនមានអាជ្ញាប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត (ឆ្កួត)១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

# ពាក្យប្រារព្ធ

សម្មាទិដ្ឋិ កើតមកអំពីការស្តាប់ព្រះធម៌ និងការសិក្សារៀនសូត្រដោយល្អ ព្រមទាំងចំណុចសំខាន់មួយទៀត គឺយោនិសោមនសិការ ។

សម្មាទិដ្ឋិ គឺជាការយល់ត្រូវ តាមហេតុផលពិត យល់ត្រូវក្នុងសច្ចធម៌ ។ សម្មាទិដ្ឋិយល់ត្រូវក្នុងជីវិត ដែលមានតែបរមត្ថធម៌ ជាធម៌ដែលអាស្រ័យបច្ច័យកើតឡើង ហើយរលត់ទៅវិញ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងអំពីខន្ធ អាយតនៈ ធាតុ ពួកកាយ ពួកវេទនា ពួកចិត្ត និងពួកធម៌ រួមមកគឺនាមរូប ដើម្បីឱ្យសត្វលោកបានដឹង មិនមែនដើម្បីមិនឱ្យដឹងទេ ។ ការបានដឹងត្រឹមត្រូវនូវធម៌ក្នុងជីវិត ដែលកំពុងមាន កំពុងប្រាកដ ជាបរមត្ថ មិនមែនសត្វ គ្រាន់តែជាសង្ខារ នេះជាសម្មាទិដ្ឋិ ។

ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្តែងឱ្យដឹង គឺជាធម៌ដែលមានស្រេចស្រាប់គ្រប់គ្នាទាំងអស់ ព្រះអង្គទ្រង់ត្រាស់ឱ្យមានសតិសម្បជញ្ញៈ ដើម្បីកុំឱ្យវង្វេងជាមួយនឹងជីវិតខ្លួនឯង ។

សម្មាទិដ្ឋិ ដោះស្រាយបញ្ហា ដែលជាទុក្ខក្នុងចិត្ត ជាមួយនឹងធម៌បច្ចុប្បន្ន ដែលធម៌បច្ចុប្បន្ននេះ ជាអារម្មណ៍របស់សម្មាទិដ្ឋិ



ហ្នឹងឯង ។ ការដែលមិនជាប់ចិត្តជាមួយនឹងអ្វីៗ ដែលធ្លាប់សុខ ធ្លាប់ស្រួល ធ្លាប់សប្បាយ គឺព្រមក្នុងចិត្តឱ្យអ្វីៗនោះកន្លងទៅតាមធម្មតា ហើយប្រឈមមុខជាមួយនឹងធម៌បច្ចុប្បន្ន មិនប្រកាន់ មិនចាប់យក ថែមទាំងមិនត្រូវការធម៌អ្វីទាំងអស់ក្នុងអនាគត នេះជាសម្មាទិដ្ឋិដ៏រឹងមាំ ប្រព្រឹត្តទៅរកការអស់អាសវក្កិលេសទាំងពួង ។

នៅក្នុងសៀវភៅនេះ គ្រាន់តែលើកយកធម៌បន្តិចបន្តួចមកបញ្ជាក់ ឱ្យឃើញលក្ខណៈនៃសម្មាទិដ្ឋិប៉ុណ្ណោះ ។ សូមពុទ្ធបរិស័ទព្យាយាមសិក្សាព្រះធម៌ក្នុងព្រះត្រៃបិដក ឱ្យបានត្រឹមត្រូវផងចុះ ខិតខំព្យាយាមឱ្យបានយល់ត្រូវ ចំពោះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឱ្យដឹង ហើយមានប្រក្រតីចម្រើនសេចក្តីដឹង ឱ្យបានរឿយៗតទៅ ព្រោះនេះជាផ្លូវតែមួយគត់សម្រាប់ការរួចផុតចាកទុក្ខទាំងពួង ។

**ដោយចំណាងល្អដ៏ក្រៃលែង**

ថ្ងៃ១០កើត ខែអាសាឍ ព. ស. ២៥៥២

# សារបណ្ណ

ឈ្មោះអត្ថបទ ទំព័រ

## សម្មាទិដ្ឋិ


- **កច្ចានគោត្តសូត្រ**.............................................១
  - អដ្ឋកថា កច្ចានគោត្តសូត្រ.............................. ៤
  - បឋមសុរិយូបមសូត្រ....................................៨
  - នៅក្នុងមហាចត្តារីសកសូត្រ............................. ៩
  - ក្នុងអដ្ឋកថាមហាចត្តារីសកសូត្រ..................... ១២
  - នៅខាងចុងមហាចត្តារីសកសូត្រ..................... ១៤
  - នៅក្នុងសុកសូត្រ.........................................១៦
  - អបរា ឯកធម្មាទិបាលិ...................................១៧
  - សម្មាទិដ្ឋិអង្គមគ្គ.........................................១៨
- **សម្មាទិដ្ឋិសូត្រ**...............................................១៩
  - អដ្ឋកថាសម្មាទិដ្ឋិសូត្រ.................................២២
  - អរិយសច្ចក្នុងកម្មបថ...................................២៥
- **សម្មាទិដ្ឋិសូត្រ (ត)**...........................................៣០
  - អដ្ឋកថា............................................ ៣២
  - កថាពណ៌នាអាហារវារៈ............................. ៣៤
  - កវឡិង្ការាហារជាដើម...............................៣៦
  - ភ័យក្នុងអាហារ ៤ ..................................... ៣៩
- **បុត្តមំសសូត្រ**.....................................................៤២
  - អដ្ឋកថាបុត្តមំសសូត្រ....................................៤៨
  - ការកំណត់ដឹងក្នុងកវឡីការាហារ..................... ៥១
  - ការកំណត់ដឹងក្នុងផស្សាហារ......................... ៦៨
  - ការកំណត់ដឹងក្នុងមនោសញ្ចេតនាហារ............. ៧១
  - ការកំណត់ដឹងក្នុងវិញ្ញាណាហារ.......................៧២
- **ទ្វយតានុបស្សនាសូត្រ**.......................................... ៧៥
- **អាសីវិសូបមសូត្រ**..............................................៨២
- **ធម៌គួរយល់ដឹង** ( ៤៩ ទស្សនៈ )........................... ៨៩